ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំបន្ទាយចក្រី ស្រុកព្រះស្ដេច ខេត្តព្រៃវែង ឆ្នាំ២០១៧ ដល់ ២០៣២




រៀបចំដោយ :ក្រុមហ៊ុនផ្តល់សេវាកម្ម SBK R&D

សម្របសម្រួលដោយ : ក្រុមការងារសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកព្រះស្ដេច

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត (PIO)

ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា(RGC), ADB_Loan, GAFSP_Grant និងSCF_ADB

## មាតិកា


**អារម្ភកថា** ............ 7

**សេចក្តីផ្តើម** ............ 8

**ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំបន្ទាយចក្រី** ............ 10

**១.១. ស្ថានភាពឃុំ** ............ 10

**១.១.១.ទីតាំងរដ្ឋបាលឃុំ** ............ 10

**១.១.២.ប្រជាសាស្ត្រ** ............ 13

ក. ចំនួនប្រជាជន ............ 13

ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន ............ 15

គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ............ 15

ឃ. របររកទទួលទាន ............ 16

ង. ចំណូលស្រុក និងចំណាកស្រុក ............ 17

**១.១.៣. ស្ថានភាពសេដ្ឋកិច្ច** ............ 18

ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ............ 18

ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ............ 19

គ. ស្ថានភាពបំណុល អត្រាការប្រាក់ ............ 22

ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ ............ 22

ង. ជំនួយពីប្រភពផ្សេងៗ ............ 22

**១.១.៤.ស្ថានភាពសិក្សាធិការ** ............ 22

ក. ស្ថានភាពអប់រំ ............ 22

ខ. ស្ថានភាពអក្ខរកម្ម ............ 24

គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តសិក្សាទៅថ្នាក់ខ្ពស់ទៀត ............ 25

**១.១.៥.ស្ថានភាពសុខាភិបាល** ............ 25

**១.១.៦.ស្ថានភាពយេនឌ័រ** ............ 27

**១.២. ស្ថានភាពភូមិសាស្ត្រ** ............ 30

**១.២.១.ទីតាំងភូមិសាស្ត្រ** ............ 30

**១.២.២.អាកាសធាតុ** ............ 33

**១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន** ............ 34

**១.២.៤.បរិក្ខាសាធារណៈ** ........ 37
ក. ស្ថានភាពប្រើប្រាស់អគ្គិសនី........ 37
ខ. ប្រព័ន្ធទឹកស្អាត........ 38
**១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន**........ 39
**១.៣.១.ស្ថានភាពកាន់កាប់ និងគ្រប់គ្រងដី** ........ 39
ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ ........ 41
ខ. ដីកសិកម្ម ........ 42
គ. ផ្ទៃទឹក........ 43
**១.៣.២.ផលិតកម្មកសិកម្ម** ........ 44
ក. ផលិតកម្មដំណាំស្បៀង........ 44
ខ. ផលិតកម្មដំណាំរួមផ្សំ........ 45
គ. ផលិតកម្មដំណាំឧស្សាហកម្ម........ 46
**១.៣.៣ ធនធានធម្មជាតិ** ........ 46
ក. ធនធានព្រៃឈើ........ 46
ខ. ធនធានជលផល ........ 47
គ. ធនធានរ៉ែ........ 48
**១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល**........ 48
**១.៤.១. ទីផ្សារ និងតម្លៃកសិផល អនុផលព្រៃឈើ និងផលនេសាទ** ........ 48
**១.៤.២. ខ្សែសង្វាក់ និងចរាចរផលិតផល**........ 48
**១.៤.៣. ឱកាស និងឧបសគ្គនៃទីផ្សារ និងខ្សែសង្វាក់ផលិតផល** ........ 49
**ជំពូក ២÷ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គ សម្រាប់អនាគត**........52
**២.១. តម្រូវការសម្រាប់អនាគត**........52
**២.១.១.ផែនការអភិវឌ្ឍឃុំ** ........ 52
ក. ផែនការអភិវឌ្ឍឃុំ៥ឆ្នាំ (២០១៧-២០២២)........ 52
ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត........ 57
**២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២**........ 57
**២.១.៣.តម្រូវការដីធ្លីជាមូលដ្ឋាន**........ 58
ក. តម្រូវការដីលំនៅឋាន........ 58

ខ. ដីកសិកម្ម ........ 60
គ. ដីព្រៃឈើ ........ 61
ឃ. ធនធានទឹក ........ 61
ង. ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត ........ 62
ង.១. វិស័យអប់រំ ........ 62
ង.២. វិស័យសុខាភិបាល ........ 64
ង.៣. អគ្គិសនី ........ 64
ង.៤. ទីលានចាក់សំរាម ........ 64
ង.៥. ដីកប់ខ្មោច ........ 65
ង.៦. ស្រះ និងអណ្តូងទឹក ........ 65
**២.៣. ការប្រឈម** ........ 66
**២.៣.១.ការប្រឈមដោយធម្មជាតិ** ........ 66
ក. កំណើនប្រជាជន ........ 66
ខ. គ្រោះធម្មជាតិ ការវិចវិលនៃធម្មជាតិ ........ 66
**២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តភាព** ........ 67
**២.៤. ឱកាស** ........ 67
**២.៤.១.អំណោយផលពីធម្មជាតិ** ........ 67
**២.៤.២. បច្ចេកវិទ្យាថ្មី** ........ 68
**២.៤.៣. គម្រោងវិនិយោគ** ........ 68
**២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ** ........ 68
**ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២** ........ 73
**៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង** ........ 73
**៣.១.១.តម្រូវការដីតាមប្រភេទ** ........ 73
**៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល** ........ 74
**៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់** ........ 75
**៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ** ........ 75
**៣.២.២. ផែនទីប្រើប្រាស់ដីអនាគត** ........ 76
**៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត** ........ 78

ក. ដីលំនៅឋានភូមិ ........ 78
ខ. ដីលំនៅឋាន ទីប្រជុំជន ........ 78
គ. ដីស្រែប្រាំង និងស្រែវស្សា ........ 79
ឃ. ទន្លេ ........ 79
**៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព** ........ 80
**៣.៤.១. កត្តាចាំចាច់សម្រាប់ធានានិរន្តរភាព** ........ 80
ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម ........ 81
ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត ........ 82
**៣.៤.២. គម្រោងគាំទ្រចាំបាច់សម្រាប់គាំទ្រនិរន្តរភាព** ........ 83
**៣.៥. សេចក្តីសន្និដ្ឋានរួមលើផែនការប្រើប្រាស់ដីអនាគត** (**២០១៧ ដល់២០៣២**) ........ 84

## បញ្ជីរូបភាព ដ្យាក្រាម តារាង ផែនទី

រូបភាពទី១: វត្ត ........ 16
រូបភាពទី២: សាលារៀន ........ 23
រូបភាពទី៣: អគ្គីសនី ........ 25
រូបភាពទី៤: សុខាភិបាល ........ 26
រូបភាពទី៥: សកម្មភាពយេនឌ័រ ........ 30
រូបភាពទី៦: ប្រឡាយ ........ 32
រូបភាពទី៧: ស្ថានភាពបណ្តាញផ្លូវក្នុងឃុំបន្ទាយចក្រី ........ 36
រូបភាពទី៨: បណ្តាញអគ្គិសនី ........ 38
រូបភាពទី៩: បណ្តាញទឹក ........ 39
រូបភាពទី១០: ដីលំនៅឋាន ទីប្រជុំជន ........ 43
រូបភាពទី១១: ដីលំនៅឋាន ភូមិ ........ 43
រូបភាពទី១២: ដីស្រែវស្សា ........ 44
រូបភាពទី១៣: ទន្លេ ........ 45
រូបភាពទី១៤: ផលិតផលដំណាំស្មៀង ........ 47
រូបភាពទី១៥: ដំណាំរួមផ្សំ ........ 48
រូបភាពទី១៦: ការដឹកជញ្ជូន ........ 51

## ដ្យាក្រាម

ដ្យាក្រាមទី១: ដំណើរការរៀបចំផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ ........ 9
ដ្យាក្រាមទី២: ភាគរយនៃប្រភពចំណូលចម្បង និងបន្ទាប់បន្សំ ........ 19

ដ្យាក្រាមទី៣: ខ្សែសង្វាក់តម្លៃ 52
ដ្យាក្រាមទី៤: ខ្សែសង្វាក់តម្លៃ 53

## តារាង

តារាងទី១: ស្ថានភាពទូទៅនៃឃុំ 10
តារាងទី២: ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិឆ្នាំ២០១៧ 13
តារាងទី៣: ស្ថិតិប្រជាជនឆ្នាំ២០១៧ តាមក្រុមអាយុ 14
តារាងទី៤: ស្ថិតិប្រជាពលរដ្ឋ 15
តារាងទី៥: មុររបរ 17
តារាងទី៦: ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៧ 18
តារាងទី៧: ស្ថិតិប្រជាជនចំណាកស្រុកក្នុងឆ្នាំ២០១៧ 18
តារាងទី៨: ចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ២០១៧ 19
តារាងទី៩: ចំណូល និងចំណាយចម្បងមធ្យមក្នុងគ្រួសារប្រចាំឆ្នាំ 21
តារាងទី១០: ស្ថានភាពអត្តការប្រាក់ 22
តារាងទី១១: ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឆ្នាំ២០១៧ 24
តារាងទី១២: ស្ថិតិអ្នកមិនចេះអក្សរ 24
តារាងទី១៣: ស្ថិតិអ្នកបន្តការសិក្សាថ្នាក់ខ្ពស់ 25
តារាងទី១៤: ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់ប៉ុស្តិ៍សុខភាព 27
តារាងទី១៥: ការវិភាគតួនាទីយេនឌ័រក្នុងឃុំបន្ទាយចក្រី 28
តារាងទី១៦: ពំនុះកាត់ទទឹងឃុំបន្ទាយចក្រី 33
តារាងទី១៧: បរិមាណទឹកភ្លៀងស្រុកព្រះស្តេច 34
តារាងទី១៨: ស្ថិតិគ្រួសារដែលប្រើប្រាស់បណ្តាញអគ្គិសនី 38
តារាងទី១៩: ស្ថិតិគ្រួសារដែលប្រើប្រាស់បណ្តាញទឹក 42
តារាងទី២០: តារាងរាយលម្អិតតាមប្រភេទការប្រើប្រាស់ដីបច្ចុប្បន្ន 46
តារាងទី២១: តារាងអធិប្បាយពីឧបសគ្គ និងឱកាសលើដំណាំស្បៀង 48
តារាងទី២២: អធិប្បាយពីឧបសគ្គ និងឱកាសលើដំណាំស្បៀង 49
តារាងទី២៣: អធិប្បាយពីឧបសគ្គ និងឱកាសធនធានព្រៃឈើ 49
តារាងទី២៤: តារាងអធិប្បាយពីឧបសគ្គ និងឱកាស 50
តារាងទី២៥: ស្ថិតិផលិតផលស្រូវ និងតម្លៃ 54
តារាងទី២៦: ការកំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ 55
តារាងទី២៧: ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប(០៥ឆ្នាំ) 61
តារាងទី២៨: ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ 62

តារាងទី២៩: តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ 63
តារាងទី៣១: តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២ 65
តារាងទី៣២: តម្រូវការដីសម្រាប់សេវាអប់រំក្នុងឆ្នាំ២០៣២ 68
តារាងទី៣៣: បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/ មូលហេតុ/ ដំណោះស្រាយ) 73
តារាងទី៣៤: ការប្រើប្រាស់ដីនាពេលអនាគត 80

## ផែនទី

ផែនទី១: បង្ហាញទីតាំងឃុំបន្ទាយចក្រី ស្រុកព្រះស្តេច 11
ផែនទី២: ព្រំប្រទល់រដ្ឋបាលឃុំបន្ទាយចក្រី 12
ផែនទី៣: រយៈកម្ពស់ដីនៅក្នុងឃុំបន្ទាយចក្រី ស្រុកព្រះស្តេច 31
ផែនទី៤: តំបន់កំណត់តំបន់គ្រោះបរិស្ថានឃុំបន្ទាយចក្រី 32
ផែនទី៥: ប្រព័ន្ធធារាសាស្ត្របច្ចុប្បន្នឃុំបន្ទាយចក្រី 33
ផែនទី៦: ហេដ្ឋារចនាសម្ព័ន្ធឃុំបន្ទាយចក្រី ស្រុកព្រះស្តេច 37
ផែនទី៧: ប្រើប្រាស់ដីបច្ចុប្បន្នសាមញ្ញ 40
ផែនទី៨: ប្រើប្រាស់ដីបច្ចុប្បន្នលម្អិត 41
ផែនទី៩: គម្រោងវិនិយោគ ឆ្នាំ 60
ផែនទី១០: បញ្ហា មូលហេតុ និងដំណោះស្រាយ 76
ផែនទី១១: ផែនទីប្រើប្រាស់ដីនាពេលអនាគត 81

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺជាឧបករណ៍មួយដ៏សំខាន់ ក្នុងការជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់ ក៏ដូចជាដល់ភាគីពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដីដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះក្រោយពេលពេលមានផែនការប្រើប្រាស់ដីនេះអាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដីនឹងមានមូល-ដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់នេះទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ថ្នាក់មូលដ្ឋានដោយធ្វើសមាហរណកម្ម ផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី ខេត្ត តាមនីតិវិធីដូចដែលធ្លាប់អនុវត្ត ក្នុងការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចកន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសម្រេច។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយស សូមបង្ហាញនូវរបាយការណ៍បច្ចេកទេសពីផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី មានចក្ខុវិស័យរហូតដល់ឆ្នាំ ២០៣២ ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល កម្ពុជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីកសិកម្ម និងសន្តិសុខ ស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា។ ម្យ៉ាងទៀតសូមថ្លែងអំណរគុណដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានសម្រប-សម្រួលបច្ចេកទេសដល់ក្រុមហ៊ុនផ្ដល់សេវាកម្ម ក្នុងការសិក្សារៀបចំផែនការនេះតាមរយៈរដ្ឋបាលខេត្តព្រៃវែង និងរដ្ឋបាលស្រុកព្រះស្ដេច ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោងនិងភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនៅក្នុង ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំនេះ។ ខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថាផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី នេះនឹងបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំប្រកបដោយចីរភាព និងចំគោលដៅធ្ងន់ធ្ងរនោះទេថែមទាំងត្រូវបានប្រើប្រាស់ ដោយមានការចូលរួមនិងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់៕

ថ្ងៃអង្គារ២កើត ខែមិគសិរ ឆ្នាំជូត ទោ ស័ក ព.ស.២៥៦៤

ធ្វើនៅឃុំបន្ទាយចក្រី ថ្ងៃទី១៧ ខែវិច្ឆិកាឆ្នាំ២០២០

ប្រធានក្រុមប្រឹក្សាឃុំ និងជា

មេឃុំបន្ទាយចក្រី

នូ សាម្អួន

# សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូល រដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែកនិងគ្រប់វិស័យ ក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយ។

ឃុំបន្ទាយចក្រី ជាឃុំមួយក្នុងចំណោមឃុំចំនួន ១១ ស្ថិតក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង គឺជាតំបន់ជនបទមានផ្ទៃដីសរុបចំនួន ៨ ៣១៣ ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹងឃុំអង្គរាជ្យ និងឃុំសេនារាជឧត្តម ខាងកើតជាប់នឹងឃុំពាមមន្ទារ ស្រុកកំពង់ត្របែក ខាងត្បូងឈៀងខាងកើតជាប់នឹងប្រទេសវៀតណាម ខាងលិចជាប់នឹងឃុំព្រះស្តេច ដែលមានប្រជាជនសរុបចំនួន ១៦ ០៩២នាក់ ក្នុងនោះស្ត្រីមាន ៨ ២៦០ នាក់ ហើយមានប្រជាពលរដ្ឋ ៩០% ជាកសិករ។ ឃុំបន្ទាយចក្រី មានផ្ទៃដីស្រែ សរុបទំហំ ៦ ៥២៩ហិកតា គឺជាផ្ទៃដីដែលមានទំហំធំទូលាយមានវិសាលភាពស្រូបអស់ ៧៨,៥៥% នៃផ្ទៃដីសរុបរបស់ឃុំដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍ឃុំប្រកបដោយចីរភាព។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍឃុំបន្ទាយចក្រីប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តព្រៃវែង និងស្រុកព្រះស្តេច ព្រមទាំងក្រុមប្រឹក្សាឃុំបន្ទាយចក្រី ក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី ដោយក្រុមហ៊ុន SBK R&D និងមានការគ្រប់គ្រងគាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIO) និងអង្គភាព អនុវត្តគម្រោងថ្នាក់ជាតិ (NIO) នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ព្រមទាំងមានការគាំទ្រនឹងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី និងកម្មវិធីកសិកម្ម និងសន្តិសុខ ស្បៀង ពិភពលោក(GAFSP) ដែលបានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍន៍ឃុំ ពាក់ព័ន្ធការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំផ្ទាល់ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ដែលក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍ឃុំធ្វើឱ្យជីវភាពប្រជាពលរដ្ឋ

មានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រជាពិសេសប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំបន្ទាយចក្រីឱ្យអស់សក្តានុពល ដែលមានក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើន ដែលនៅសល់ពីការហូបចុកនៅពេលអនាគត ឆ្លើយតបបានទៅនឹងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលតាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី នេះធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍឃុំនៅតាមអាណត្តិនីមួយៗ របស់ខ្លួន។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រីត្រូវបានរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ លើកត្តាភូមិសាស្ត្រសេដ្ឋកិច្ចសង្គមកិច្ចវប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ច្បាប់ភូមិបាលច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ ស្តីពី ទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើច្បាប់ស្តីពីជលផលច្បាប់ស្តីពីផ្លូវថ្នល់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើត គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានីខេត្ត ក្រុងស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានីក្រុង និងទីប្រជុំជន។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិតសម្រាប់ការរៀបចំនិងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់និងឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ដែលមានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម។

ដ្យាក្រាមទី១÷ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់




**សំគាល់÷** ប្រអប់បង្ហាញទិហិការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំបន្ទាយចក្រី

## ១.១. ស្ថានភាពឃុំ

កាលពីបុរាណមានស្តេច មួយព្រះអង្គ ព្រះនាមចក្រី គង់នៅទួលវិហារ ស្ថិតនៅភូមិកគោជិតនឹងមានព្រំប្រទល់ជាប់ប្រទេសវៀតណាម។ តក្រោយមកទៀតក្នុងកំឡុងឆ្នាំ ១៩៥១ ក្នុងតំបន់នេះមានប្រជាជនមករស់នៅកាន់តែច្រើនហើយក៏បានបង្កើតជាឃុំមួយដែលបានដាក់ឈ្មោះថាចក្រី ដោយយោងតាមប្រវត្តិរបស់ស្តេចចក្រីដែលធ្លាប់គង់នៅក្នុងតំបន់នេះ រយៈពេលកាន់តែយូរៗទៅប្រជាជនក៏បានហៅថាបន្ទាយចក្រីរហូតមកដល់សព្វថ្ងៃនេះទៅ។

### ១.១.១.ទីតាំងរដ្ឋបាលឃុំ

ឃុំបន្ទាយចក្រីជាឃុំមួយក្នុងចំណោមឃុំទាំង ១១ ស្ថិតនៅក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង មានចម្ងាយពីសាលាស្រុកព្រះស្តេចប្រមាណ ១៦ គីឡូម៉ែត្រ ប៉ែកខាងត្បូង។ ឃុំបន្ទាយចក្រីផ្ទៃដីសរុប ៨ ៣១៣ ហិកតា និងមានភូមិចំណុះចំនួន ២០ ភូមិគឺៈ ភូមិរកាជួរទី១ ភូមិរកាជួរទី២ ភូមិរកាជួទី៣ ភូមិជៃតា ភូមិម្រេញ ភូមិពោធិ៍រិយំ ភូមិកគោ ភូមិងែកងក ភូមិប្រោះស្វា ភូមិដីវិស្លាប់ ភូមិសំពោង ភូមិតាអឹម ភូមិបឹងកំពតភូមិប្របុសរលួយ ភូមិមុន្នីសិលា ភូមិអំពិល ភូមិមពីងពង់ ភូមិឬស្សីជុក ភូមិពោធិ៍ និងភូមិពោធិ៍ជ្រែក។ ឃុំនេះមានព្រំប្រទល់ជាប់នឹង÷

- ខាងជើងទល់នឹងឃុំអង្គរាជ្យ ស្រុកព្រះស្តេច និងឃុំសេនារាជឧត្តម ស្រុកព្រះស្តេច
- ខាងកើតទល់នឹងឃុំពាមមន្ទារ ស្រុកកំពង់ត្របែក
- ខាងលិចជាប់នឹងឃុំបឹងដោល ស្រុកព្រះស្តេច និងឃុំព្រះស្តេច ស្រុកព្រះស្តេច
- ខាងត្បូងជាប់នឹងប្រទេសវៀតណាម។

តារាងទី១÷ ស្ថានភាពទូទៅនៃឃុំ

| ខេត្ត | ព្រៃវែង | លេខកូដខេត្តៈ១៤ |
|---|---|---|
| ស្រុក/ខណ្ឌ | ព្រះស្តេច | លេខកូដស្រុកៈ១៤០៩ |
| ឃុំ/សង្កាត់ | បន្ទាយចក្រី | លេខកូដឃុំៈ ១៤០៩០២ |
| ចំនួនភូមិៈ ២០ | ភូមិរកាជួទី១ | លេខកូដភូមិៈ ១៤០៩០២០១ |
| | ភូមិរកាជួទី២ | លេខកូដភូមិៈ ១៤០៩០២០២ |
| | ភូមិរកាជួទី៣ | លេខកូដភូមិៈ ១៤០៩០២០៣ |
| | ភូមិជៃតា | លេខកូដភូមិៈ ១៤០៩០២០៤ |
| | ភូមិម្រេញ | លេខកូដភូមិៈ ១៤០៩០២០៥ |
| | ភូមិពោធិ៍រិយំ | លេខកូដភូមិៈ ១៤០៩០២០៦ |

| | | |
|---|---|---|
| | ភូមិកគោ | លេខកូដភូមិៈ ១៤០៩០២០៧ |
| | ភូមិវែងកងក | លេខកូដភូមិៈ ១៤០៩០២០៨ |
| | ភូមិប្រោះស្វា | លេខកូដភូមិៈ ១៤០៩០២០៩ |
| | ភូមិដីរីស្លាប់ | លេខកូដភូមិៈ ១៤០៩០២១០ |
| | ភូមិសំពោង | លេខកូដភូមិៈ ១៤០៩០២១១ |
| | ភូមិតាអឹម | លេខកូដភូមិៈ ១៤០៩០២១២ |
| | ភូមិបឹងកំពត | លេខកូដភូមិៈ ១៤០៩០២១៣ |
| | ភូមិប្របុសរលួយ | លេខកូដភូមិៈ ១៤០៩០២១៤ |
| | ភូមិមុន្នីសិលា | លេខកូដភូមិៈ ១៤០៩០២១៥ |
| | ភូមិអំពិល | លេខកូដភូមិៈ ១៤០៩០២១៦ |
| | ភូមិពីងពង់ | លេខកូដភូមិៈ ១៤០៩០២១៧ |
| | ភូមិឬស្សីជុក | លេខកូដភូមិៈ ១៤០៩០២១៨ |
| | ភូមិពោធិ៍ | លេខកូដភូមិៈ ១៤០៩០២១៩ |
| | ភូមិពោធិ៍ជ្រែក | លេខកូដភូមិៈ ១៤០៩០២២០ |

ប្រភព÷ *ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

## ផែនទី១÷ ទីតាំងឃុំបន្ទាយចក្រី ស្រុកព្រះស្តេច



## ផែនទី២÷ ព្រំប្រទល់រដ្ឋបាលឃុំបន្ទាយចក្រី ស្រុកព្រះស្ដេច



### ១.១.២. ប្រជាសាស្ត្រ

#### ក. ចំនួនប្រជាជន

យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំបន្ទាយចក្រី បានឱ្យដឹងថាក្នុងឆ្នាំ២០១៧ មានប្រជាជនសរុបចំនួន ១៦ ០៩២ នាក់ ក្នុងនោះស្ត្រីមានចំនួន ៨ ២៦០នាក់ និងមានគ្រួសារសរុបចំនួន ៣ ៩១១ គ្រួសារ ក្នុងនោះប្រជាជនអាយុ ១៨ ឡើងមានចំនួន ៩ ៧៥៣ នាក់ ដោយស្ត្រីមានចំនួន ៤ ៩៦៤ នាក់ និងបានឱ្យដឹងទៀតថាក្នុងឃុំបន្ទាយចក្រី ភូមិដែលមានប្រជាជនច្រើនជាងគេគឺ ភូមិកគោ មានប្រជាជនចំនួន ១ ៧១២ នាក់ ស្រីចំនួន ៩១៧នាក់ ក្នុងនោះមាន ៤៣២ គ្រួសារ ស្មើនឹង ១១%។ ចំណែកភូមិមានប្រជាជនតិចជាងគេគឺ ភូមិពីងពង់ មានចំនួន ៣៨៣ នាក់ ស្រី ១៩៦នាក់ ក្នុងនោះមានគ្រួសារសរុបចំនួន ៨០ នាក់ស្មើនឹង ២%។ ទន្ទឹមនេះក៏សង្កេតឃើញប្រជាជននៅក្នុងឃុំ ស្ត្រីមានចំនួនច្រើនជាងបុរសដូចមានក្នុងតារាងដែលក្រុមការងារបានរៀបចំសង្ខេបខាងក្រោម។

តារាងទី២÷ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិឆ្នាំ២០១៧

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | គិតជា% | ចំនួនមនុស្ស | | ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | សរុប | ស្រី |
| ១ | ភូមិរកាជួទី១ | ១៦០ | ៣,៤៧ | ៥៥៨ | ២៧៩ | ៣១០ | ១៥៨ |
| ២ | ភូមិរកាជួទី២ | ១៥៣ | ៣,៨២ | ៦១៥ | ២៩៤ | ៤០៥ | ១៩៤ |
| ៣ | ភូមិរកាជួទី៣ | ១៧៩ | ៤,១៤ | ៦៦៦ | ៣៥១ | ៤១៣ | ២១១ |
| ៤ | ភូមិដែធា | ៣៣៩ | ៩,២០ | ១ ៤៨០ | ៧៧៥ | ៩១៩ | ៤៨៤ |
| ៥ | ភូមិម្រេញ | ១៦៣ | ៥,៥៦ | ៨៩៥ | ៣៣៨ | ៦៧០ | ២២៨ |
| ៦ | ភូមិពោធិ៍រំយំ | ១២១ | ៣,១៩ | ៥១៤ | ២៦៩ | ៣៥៩ | ១៩២ |
| ៧ | ភូមិកគោ | ៤៣២ | ១០,៦៤ | ១ ៧១២ | ៩១៧ | ៩៧៦ | ៤៩១ |
| ៨ | ភូមិងែកងក | ៣០១ | ៧,៤៨ | ១ ២០៣ | ៦១៤ | ៦២៥ | ៣៣៦ |
| ៩ | ភូមិប្រោះស្វា | ៣៥៩ | ៩.០៨ | ១ ៤៦១ | ៨០២ | ៧៣៩ | ៣៩៦ |
| ១០ | ភូមិដំរីស្លាប់ | ២៤៥ | ៦,០៣ | ៩៧១ | ៤៨៩ | ៥៩៧ | ៣០៨ |
| ១១ | ភូមិសំពោង | ១៤៨ | ៣,៧៣ | ៦០០ | ៣១២ | ៤០៤ | ២០៦ |
| ១២ | ភូមិតាអឹម | ១៤០ | ២,៦៧ | ៤៣០ | ២០៣ | ២៦៣ | ១១៤ |
| ១៣ | ភូមិបឹងកំពត | ១៦២ | ៤,៥៩ | ៧៣៩ | ៣៧៧ | ៤៨៧ | ២៥៩ |
| ១៤ | ភូមិប្របុសរលួយ | ៣០៥ | ៧,៤៩ | ១២០៦ | ៦៣៤ | ៧៤៦ | ៤១១ |
| ១៥ | ភូមិមុន្នីសិលា | ១៣៤ | ៣,៦៣ | ៥៨៤ | ៣០៤ | ៣៦៣ | ១៨៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦ | ភូមិអំពិល | ៩៦ | ២,៤៣ | ៣៩១ | ១៩៦ | ២៤៣ | ១១៩ |
| ១៧ | ភូមិពីងពង់ | ៨០ | ២,៣៨ | ៣៨៣ | ២១១ | ១៣៤ | ៧២ |
| ១៨ | ភូមិឬស្សីជុំក | ១២៥ | ៣,៦៩ | ៥៩៣ | ៣១២ | ៣៨៧ | ២១៤ |
| ១៩ | ភូមិពោធិ៍ | ១៣៥ | ៣,១៩ | ៥១៤ | ២៩០ | ៣០៧ | ១៨២ |
| ២០ | ភូមិពោធិ៍ជ្រែក | ១៣៤ | ៣,៥៩ | ៥៧៧ | ២៩៣ | ៤០៦ | ២០១ |
| | | ៣ ៩១១ | ១០០ | ១៦ ០៩២ | ៨ ២៦០ | ៩ ៧៥៣ | ៤ ៩៦៤ |

ប្រភព÷*ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

តាមរយៈពតិមានក្នុងតារាងទី ២និងទី៣ បានឱ្យដឹងពីវ័យរបស់ប្រជាពលរដ្ឋទៅតាមក្រុមអាយុ ដែលក្នុងនោះមានប្រជាពលរដ្ឋអាយុចាប់ពី ២៥ ឆ្នាំ ដល់ ៦០ ឆ្នាំ មានចំនួន ៦ ៣៧២នាក់ គឺស្មើប្រហាក់ប្រហែលនឹង៤៨% នៃប្រជាពលរដ្ឋសរុបដែលជាមនុស្សពេញកម្លាំងពលកម្ម ក្រៅពីនេះអាយុពីកើត ដល់អាយុ ២៤ឆ្នាំ មានចំនួន ៥ ៦៥០ នាក់ ស្មើប្រហាក់ប្រហែលនឹង ៤៣% និងប្រជាពលរដ្ឋមាន អាយុពី ៦១ ឆ្នាំឡើង មាន មានចំនួន ១ ២៥២ នាក់ ស្មើប្រហាក់ប្រហែលនឹង ០៩%។ ដូច្នេះឃើញថា អ្នកពេញកម្លាំងពលកម្មមួយនាក់ រកចំណូល បានជាមធ្យមត្រូវចិញ្ចឹមបន្ថែមពីរនាក់ទៀត។

.តារាងទី៣÷ស្ថិតិប្រជាជនឆ្នាំ២០១៧ តាមក្រុមអាយុ

| តាមក្រុមអាយុ | សរុប | ប្រុស | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| អាយុ០-២ឆ្នាំ | ៩១០ | ៤៥៦ | ៤៥៤ | កុមារ |
| អាយុពី៣-៤ឆ្នាំ | ៣២៣ | ១៥២ | ១៧១ | អាយុចូលមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៣២៤ | ១៤៤ | ១៨០ | អាយុចូលមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៣៦៧ | ១៧៦ | ១៩១ | អាយុចូលសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ១ ៥១២ | ៧៤១ | ៧៧១ | អាយុចូលសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ៥៥៩ | ២៥២ | ៣០៧ | អាយុចូលបឋម |
| អាយុពី១២-១៤ឆ្នាំ | ៤១៣ | ២១៣ | ២០០ | អាយុចូលអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ២៤៧ | ១៥០ | ៩៧ | អាយុចូលបឋម |
| អាយុពី១៥-១៧ឆ្នាំ | ៤៦៧ | ២១២ | ២៥៥ | អាយុចូលអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ១៧៤ | ៨៩ | ៨៥ | អាយុចូលវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ២៧១ | ១៨៣ | ៨៨ | អាយុចូលវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ៨៣ | ២៥ | ៥៨ | អាយុចូលសកលវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ២ ៥៨១ | ១ ២៧៥ | ១ ៣០៦ | អាយុពេញពលកម្ម |

| | | | | |
|---|---|---|---|---|
| អាយុពី៣៦-៤៥ឆ្នាំ | ១ ៩៤៦ | ៩២០ | ១ ០២៦ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦០ឆ្នាំ | ១ ៨៤៥ | ៩០៧ | ៩៣៨ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំ | ១ ២៥២ | ៦២៣ | ៦២៩ | អាយុចូលនិវត្តន៍ |
| សរុប | ១៣ ២៧៤ | ៦ ៥១៨ | ៦ ៧៥៦ | |

ប្រភព÷*ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

### ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំបន្ទាយចក្រី ក្នុងឆ្នាំ ២០១៧ នៅក្នុងឃុំបន្ទាយចក្រី មានអត្រាកំណើនប្រជាជនទៅតាមឆ្នាំមិនដូចគ្នាទេ ដោយចាប់សង្កេតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ឃើញថាកំណើនមធ្យមប្រចាំឆ្នាំ ១,៥២៥ %។ នៅក្នុងក្នុងឃុំបន្ទាយចក្រី មានដង់ស៊ីតេប្រជាជនជាមធ្យម ១៩៣នាក់/គ.ម$^{២}$ ដោយការរស់នៅរបស់ប្រជាជនប្រមូលផ្តុំនៅលើទីតាំងស្មើរតែរាយស្មើគ្រប់ទិសទូទាំងឃុំ ប៉ុន្តែសង្កេតឃើញមានការរស់នៅប្រមូលផ្តុំកុះករច្រើនជាងគេ នៅក្នុងតំបន់លំនៅឋានក្នុងឃុំស្ថិតនៅក្នុងភូមិកគោ។

តារាងទី៤÷ស្ថិតិប្រជាពលរដ្ឋ

| ចំនួន | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម (%) |
|---|---|---|---|---|---|---|
| ប្រជាជនសរុប | ១៥ ២៦០ | ១៥ ៣៤៧ | ១៥ ៩២៥ | ១៥ ៥៨៧ | ១៦ ០៩២ | |
| កំណើនមធ្យម(%) | | ១ | ៤ | -២,១ | ៣,២ | ១,៥២៥ |

*ប្រភព÷ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

### គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំបន្ទាយចក្រី មានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ ហើយប្រជាជនភាគច្រើន នៅក្នុងឃុំគោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរដូចជាពិធីរៀបមង្គលការ ប្រារព្ធពិធីបុណ្យទាននៅតាមវត្តអារាម និងនិមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិន ដូចជាពិធីសែនព្រេនដូនតា ពិធីបញ្ចុះសព និងភាគតិចបំផុតមានទំនៀមទម្លាប់បែបសាសនាគ្រីស្តដូចជាមានប្រារព្ធពិធីចូលព្រះ វិហារគ្រីស្តនៅរៀង រាល់ថ្ងៃអាទិត្យជាដើម។ល។ និយាយរួមប្រជាជនក្នុងឃុំបន្ទាយចក្រី តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀង មកតាមជំនឿបែបខ្មែរ និងបែបចិន។

រូបភាពទី១÷ វត្ត



វត្តចក្រីសិរិមង្គល

**ឃ. របររកទទួលទាន**

យោងតាមឯកសារ ព័ត៌មានស្ថានភាពឃុំស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឃុំបន្ទាយចក្រី បានឱ្យដឹងថាក្នុងឆ្នាំ ២០១៧ ប្រជាពលរដ្ឋភាគច្រើនលើសលប់ក្នុងឃុំបន្ទាយចក្រី មានមុខរបរចម្បងធ្វើស្រែ គឺមានចំនួនរហូត ដល់ ៥ ១២៩ នាក់ ដែលមានប្រមាណ ៧៩% នៃប្រជាពលរដ្ឋប្រកបរបររកស៊ី ក្រៅពីនេះមានដូចជា ដឹកជញ្ជូនលក់ដូរឬធ្វើជំនួញ ស៊ីឈ្នួល វិស័យឯកជន មន្ត្រីរាជការ ប៉ូលីស ទាហាន និងតិចជាង គេ គឺចិញ្ចឹមសត្វ។ ចំណែកមុខរបរបន្ទាប់បន្សំ មានតែប្រជាពលរដ្ឋតិចតួច ដែលចិញ្ចឹមសត្វ លក់ដូរ ដឹកជញ្ជូន វិស័យឯកជន និងស៊ីឈ្នួលប៉ុន្តែប្រជាពលរដ្ឋភាគច្រើនធ្វើស្រែ ដែលចំនួនប្រមាណតែ ១ ២៨៥ នាក់ គឺស្មើនឹង ៨៩% ដូចមានក្នុងតារាងសង្ខេបទី ៥ ខាងក្រោម។ ដូច្នេះបានបង្ហាញឱ្យឃើញថាប្រជាពលរដ្ឋភាគច្រើនក្រៅតែពីធ្វើស្រែរួចដែលជាមុខរបរចម្បង ក៏មានរកមុខរបរបន្ទាប់បន្សំបន្ថែមដូចជា ការចិញ្ចឹមសត្វ មានសត្វគោ ក្របី ជ្រូក មាន់ ទា ជា លក្ខណៈគ្រួសារ ដោយនៅក្នុងឃុំមិនទាន់មានចិញ្ចឹមជាលក្ខណៈកសិដ្ឋាននៅឡើយទេ។

តារាងទី៥÷ មុខរបរ

| បរិយាយ | មុខរបរចម្បង | | មុខរបរបន្ទាប់បន្សំ | |
|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី |
| **ក. កសិកម្ម** | | | | |
| ធ្វើស្រែ | ៥ ១២៩ | ២ ៣៤៣ | ១ ២៨៥ | ៦៥០ |
| **ខ. ចិញ្ចឹមសត្វ** | | | | |
| ចិញ្ចឹមសត្វ | ១០ | ៥ | 0 | 0 |
| **គ. សេវាកម្ម** | | | | |
| លក់ដូរឬធ្វើជំនួញ | ១១៩ | ៥៣ | ២៤ | ០៧ |
| ជាងជួសជុល | ២០ | ០៣ | ០៥ | ០ |
| វិស័យដឹកជញ្ជូន | ១២ | ០១ | ០៥ | ០ |
| ស៊ីឈ្នួល(កសិកម្ម និងកម្មករសំណង់) | ៧០៦ | ២៥៩ | ៨០ | ៣០ |
| វិស័យឯកជន(បុគ្គលិកកម្មកររោងចក្រ) និងអង្គការ | ៤៣៣ | ២៧៣ | ៣៧ | ២៩ |
| មន្ត្រីរាជការ ប៉ូលីស ទាហាន | ២៨ | ០៤ | ០ | ០ |
| សរុប | ៦ ៤៥៧ | ២ ៩៤១ | ១ ៤៣៦ | ៧១៦ |

ប្រភព÷*ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

### ង. ចំណូលស្រុក និងចំណាកស្រុក

យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចឃុំបន្ទាយចក្រី បានឱ្យដឹងថាក្នុងឆ្នាំ ២០១៧ មានប្រជាពលរដ្ឋផ្លាស់ទីចំណូលស្រុកអចិន្ត្រៃយ៍មានចំនួន ០៨ គ្រួសារ ត្រូវជា ៣៧នាក់ និងចំណាកស្រុកអចិន្ត្រៃយ៍មានចំនួន ១៣ គ្រួសារត្រូវជា ៥៥ នាក់។ ដូច្នេះពិនិត្យឃើញចំនួនគ្រួសារចំណូលស្រុកនិងចំណាកស្រុកអចិន្ត្រៃយ៍មានការខុសគ្នាសឹងតែ ២ដង។ ចំណែកចំណូលស្រុកតាមរដូវកាលពុំមាននោះទេ តែឃើញមានចំណាកស្រុកតាមរដូវកាលដែលសុទ្ធជាពលករចំណាកស្រុកមានសរុបចំនួន ២ ៥៩៥ នាក់ ដែលក្នុងនោះចំណាកស្រុកក្នុងប្រទេសមានតែចំនួន ២ ២៨១ នាក់ និង ចំណាកស្រុកក្រៅប្រទេសមានចំនួន ៣១៤ នាក់ គឺតិចជាងចំណាកស្រុកក្នុងប្រទេសប្រហែល ៧ ដង។ សរុប មកនៅក្នុងឆ្នាំ ២០១៧ក្នុងឃុំបន្ទាយចក្រី ឃើញមានចំណាកស្រុកទាំងទៅក្រៅប្រទេស និងក្នុងប្រទេសមានចំនួន រហូតដល់ ៣ ៣៥៤ នាក់ គឺស្មើប្រហាក់ប្រហែល ៥៣% នៃមនុស្សពេញកម្លាំងនៅក្នុងឃុំ (មនុស្សពេញកម្លាំងក្នុងឃុំមាន ចំនួន ៦ ៣៧២ នាក់ដូចបានអធិប្បាយខាងលើ) មានន័យថានៅក្នុងឃុំបន្ទាយចក្រី បាត់អស់កម្លាំងពលកម្មលើសពាក់កណ្តាលដែលទៅធ្វើការនៅក្រៅឃុំ។ ព័ត៌មានខាងលើនេះដូចមានសង្ខេបក្នុងតារាងខាងក្រោម។

តារាងទី៦÷ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជន២០១៧ | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ០៨ | ៣៧ | ១៤ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ១៣ | ៥៥ | ២៣ |
| សរុប | | ២១ | ៩២ | ៣៧ |

*ប្រភព÷ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

តារាងទី៧÷ស្ថិតិប្រជាជនចំណាកស្រុកក្នុងឆ្នាំ២០១៧

| ល.រ | បរិយាយ | ចំនួនប្រជាជន | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ២ ៩០១ | ១ ៣០៥ |
| ២ | ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ៤៥៣ | ១៤៧ |
| សរុប | | ៣ ៣៥៤ | ១ ៤៥២ |

*ប្រភព÷ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

មូលហេតុដែលនាំឱ្យប្រជាពលរដ្ឋធ្វើការចំណាកស្រុកដ៏ច្រើនបែបនេះ ដោយសារតែ÷

- គ្មានដីបង្កបង្កើនផល អ្នកខ្លះមានដីតិចតួច
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប
- កូនច្រើនមានការខ្វះខាត។

### ១.១.៣. ស្ថានភាពសេដ្ឋកិច្ច

#### ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ឃុំបន្ទាយចក្រី បានឱ្យដឹងថាឆ្នាំ ២០១៧ នៅក្នុងឃុំបន្ទាយចក្រី ប្រជាពលរដ្ឋមានប្រភពចំណូលចម្បងបានមកពីរបរកសិកម្ម ដែលមានចំនួនរហូតដល់ ៧៩% សេវាកម្មមានចំនួន ២០% ចិញ្ចឹមសត្វមានតិចតួចបំផុតគឺ ១% និងពុំមានសិប្បកម្មនោះទេ។ ចំណែកចំណូលបន្ទាប់បន្សំពីរបរកសិកម្មមាន ៨៩% សេវាកម្ម ១១% និងមិនមានចិញ្ចឹមសត្វនោះទេ ដូចមានសង្ខេបតាមដ្យាក្រាមខាងក្រោម។ ប៉ុន្តែបើពិនិត្យលើ មុខរបររកទទួលទាន ក្នុងដ្យាក្រាមទី ១ ខាងក្រោមឃើញមុខរបរចម្បងលើកសិកម្ម (ធ្វើស្រែ) មាន ៧៩% និងសេវាកម្ម ២០% ចំណែកមុខរបរបន្ទាប់បន្សំលើកសិកម្ម (ដាំដំណាំនិងចិញ្ចឹមសត្វ)មាន៨៩%។ តែតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធ

ក្សេត្រ-បរិស្ថានត្រង់ចំណុចការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថាគ្រួសារ ដែលមាន ជីវភាព គ្រាន់បើ និងមធ្យមមានប្រភពចំណូលទី១គឺស្រូវ ប្រភពចំណូលទី២គឺលក់ដូរ និងប្រភពចំណូលទី៣គឺ ចិញ្ចឹម សត្វ។ ចំណែកគ្រួសារក្រីក្រ២មានប្រភពចំណូលទី១ គឺលក់ពលកម្ម ប្រភពចំណូលទី២គឺស្រូវ និង ប្រភពចំណូលទី៣គឺត្រកួន ស្លែ ត្រប់ និងត្រសក់ ដោយឡែកគ្រួសារក្រីក្រ ១ (ក្រីក្របំផុត) មានប្រភពចំណូលទី ១ គឺលក់ពលកម្ម និងប្រភពចំណូលទី២គឺជួលដីធ្វើស្រែតែប៉ុណ្ណោះ។

ដូច្នេះបើប្រៀបធៀបព័ត៌មានពីមុខរបរទទួលទាន និងប្រភពចំណូលរបស់ប្រជាពលរដ្ឋក្នុងឃុំបន្ទាយចក្រី ពិនិត្យឃើញថា មានភាពស្របគ្នាអាចទទួលយកបាន បើទោះបីជាមានតួលេខខុសគ្នាក៏ដោយ តែមានភាពខុសគ្នាតិចតួចប៉ុណ្ណោះ (មុខរបរទទួលទានពីការធ្វើស្រែជាចម្បងមាន ៧៩% នៃប្រជាជនប្រកប របររកស៊ីសរុប ហើយប្រភពចំណូលចម្បងពីរបរកសិកម្មមានរហូតដល់ ២១%)។

ដ្យាក្រាមទី២÷ភាគរយនៃប្រភពចំណូលចម្បង និងបន្ទាប់បន្សំ




ប្រភព÷*ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

### ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

តារាងទី៨÷ ចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ២០១៧

| ចំណាត់ថ្នាក់ធនធាន | គ្រួសារ បង្គួរ/គ្រាន់បើ | គ្រួសារមធ្យម | គ្រួសារក្រ២ (ក្រ) | គ្រួសារ ក្រ១ (ក្រណាស់) | សរុប |
|---|---|---|---|---|---|
| តំបន់ ១ | ១៣% | ៥៥% | ២២% | ១០% | ១០០% |
| តំបន់ ២ | ១១% | ៥២% | ២៣% | ១៤% | ១០០% |
| តំបន់ ៣ | ១០% | ៥៥% | ២៤% | ១១% | ១០០% |

| ចំណាត់ថ្នាក់ធនធាន | គ្រួសារ បង្គួរ/គ្រាន់បើ | គ្រួសារមធ្យម | គ្រួសារក្រ២ (ក្រ) | គ្រួសារ ក្រ១ (ក្រណាស់) | សរុប |
|---|---|---|---|---|---|
| **ទូទាំងឃុំ** | **១១%** | **៥៤%** | **២៣%** | **១២%** | **១០០%** |
| ទំហំគ្រួសារ | ៤ | ៤ | ៤ | ៤ | |
| កំឡាំងពលកម្ម | ៣ | ៣ | ៣ | ៣ | |
| ដីកាន់កាប់សរុប | ៣,៣៥ | ២,៧០ | ១,៦៥ | ០,៦០ | |
| ចំនួនក្បាលដី | ៥ | ៤ | ២ | ១ | |
| ដីលំនៅដ្ឋាន | ០,៣៥ | ០,២០ | ០,១៥ | ០,១០ | |
| ដីស្រែ | ៣ | ២,៥០ | ១,៥០ | ០,៥០ | |
| ដីផ្សេងៗទី១ | ០ | ០ | ០ | ០ | |
| ដីផ្សេងៗទី២ | ០ | ០ | ០ | ០ | |
| ពូជស្រូវដាំដុះ | - អ៊ីអែ ៥០៤<br>- ជង្គង់ខ្មៅ<br>- ក្រសាំងទាប | - អ៊ីអែ ៥០៤<br>- ជង្គង់ខ្មៅ<br>- ក្រសាំងទាប | - អ៊ីអែ ៥០៤<br>- ជង្គង់ខ្មៅ<br>- ក្រសាំងទាប | - អ៊ីអែ ៥០៤ | |
| ដំណាំសំខាន់ទី១ | ស្រូវ | ស្រូវ | ស្រូវ | ស្រូវ | |
| ដំណាំសំខាន់ទី២ | ឈើហូបផ្លែ | ឈើហូបផ្លែ | ឈើហូបផ្លែ | ០ | |
| ដំណាំសំខាន់ទី៣ | បន្លែ | បន្លែ | ០ | ០ | |
| ការចិញ្ចឹមត្រី | ០ | ០ | ០ | ០ | |
| ចំនួនគោ ក្របី | ៣ | ៣ | ២ | ០ | |
| ចំនួនជ្រូក | ៦ | ៣ | ១ | ០ | |
| ទីកន្លែងនេសាទ | វាលស្រែ, ប្រឡាយ | វាលស្រែ,ប្រឡាយ | វាលស្រែ, ប្រឡាយ | វាលស្រែ, ប្រឡាយ | |
| ឧបករណ៍នេសាទ | សំណាញ់ មង | សំណាញ់ មង | សំណាញ់ មង | មង សន្ទូច | |
| ប្រភពចំណូលទី១ | ស្រូវ | ស្រូវ | លក់ពលកម្ម | លក់ពលកម្ម | |
| ប្រភពចំណូលទី២ | លក់ដូរ | លក់ដូរ | ស្រូវ | ជួលដីធ្វើស្រែ | |
| ប្រភពចំណូលទី៣ | សត្វ | សត្វ | ត្រកួន ,ស្លែ,ត្រប់, | ០ | |
| ការងារក្រៅកសិកម្ម | លក់ចាប់ហួយ ឥណទាន | លក់ពលកម្ម កម្មករ | លក់ពលកម្ម កម្មករ | ចំណាកស្រុក កម្មករ | |

| ចំណាត់ថ្នាក់ធនធាន | គ្រួសារ បង្គួរ/គ្រាន់បើ | គ្រួសារមធ្យម | គ្រួសារក្រ២ (ក្រ) | គ្រួសារ ក្រ១ (ក្រណាស់) | សរុប |
|---|---|---|---|---|---|
| ការប្រើប្រាស់ឥណទាន | -មានប្រាក់ឱ្យខ្ចី -មានខ្ចីពីធនាគារ ពង្រីកមុខ របរ | -ខ្ចីធនាគារ -មីក្រូហិរញ្ញវត្ថុ -ខ្ចីពីឯកជន | -ខ្ចីពីឯកជន ក្នុងភូមិតិច តួច | គ្មាន | |

*ប្រភព: របាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ឃុំបន្ទាយចក្រី*

តាមតារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ ២០១៧ ប្រជាពលរដ្ឋក្នុងឃុំបន្ទាយចក្រីមានកម្រិតជីវភាពរស់នៅចែកចេញជាបួនកម្រិតគឺ ១)គ្រួសារបង្គួរ/គ្រាន់បើ មានចំនួន ១១% ដែលជាគ្រួសារមានកម្រិត ជីវភាពធូរធាជាងគេមានដីកាន់មានដីកាន់កាប់ពី ៣,៣៥ ហិកតាឡើងលើ ២)គ្រួសារមធ្យមមានចំនួន ៥៤% ជាចំនួនច្រើនជាងគេ មានដីកាន់កាប់ពី ៣,៣៥ ហិកតាដល់ ២,៧០ ហិកតា ៣) គ្រួសារក្រ២ មានចំនួន ២៣% មានដីកាន់កាប់ពី ១,៦៥ ហិកតា ដល់ ០,៦០ ហិកតា និង៤)គ្រួសារក្រ១ ដែលជាគ្រួសារក្រីក្របំផុត និងចំនួនតិចជាងគេត្រឹមតែ ១២% មានដីកាន់ កាប់ពី០,៦០ ហិកតាចុះក្រោមរហូតដល់អ្នកគ្មានដី។

តារាងទី៩÷ចំណូល និងចំណាយចម្បងមធ្យមក្នុងគ្រួសារប្រចាំឆ្នាំ

| ល.រ | ប្រភេទ | ចំណូល | ចំណាយ |
|---|---|---|---|
| ១ | កសិកម្ម | ៤ ០៥០ ០០០ | ២ ៣៥៧ ៥០០ |
| ២ | កម្មករ ជាង រោងចក្រ | ៧ ២០០ ០០០ | ០ |
| ៣ | ស្បៀងអាហារ | ០ | ៣ ៦៥០ ០០០ |
| ៤ | សម្ភារៈសិក្សា សំលៀកបំពាក់ និងថ្នាំសង្កូវ | ០ | ១ ០០០ ០០០ |
| សរុប | | ១១ ២៥០ ០០០ | ៧ ០០៧ ៥០០ |

*ប្រភព÷សម្ភាសន៍ប្រជាជន និងមេឃុំបន្ទាយចក្រី/សៀវភៅប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំបន្ទាយចក្រី*

តាមរយៈតារាងទិន្នន័យខាងលើដែលបានពីការសាកសួរទៅលើប្រជាពលរដ្ឋ និងមេឃុំផ្ទាល់បានឱ្យដឹងថាការរកចំណូលពីរបរកសិកម្ម និងសេវាកម្ម បានជាមធ្យមក្នុងមួយឆ្នាំប្រហាក់ប្រហែល ១១លានរៀល និងចំណាយទៅវិញប្រហាក់ប្រហែល ៧លានរៀល។ ទាំងនេះជាការឱ្យដឹងថា ប្រជាពលរដ្ឋនៅក្នុងឃុំបន្ទាយចក្រីជាមធ្យមមានការចំណាយតិចជាងចំណូលគឺជាសញ្ញាល្អ ដោយឃើញមានការចាយវាយ អស់ប្រហែល ៦២%នៃប្រាក់ចំណូល។

### គ. ស្ថានភាពបំណុល អត្រាការប្រាក់

យោងតាមឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ បានឱ្យដឹងថានៅក្នុងឃុំប៉ុន្មានប្រជាពលរដ្ឋជាប់បំណុលតែពីធនាគារ និងមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះ ដែលមានចំនួន ៦០២ គ្រួសារស្មើនឹងប្រមាណ១៥%។ ប៉ុន្តែតាមរបាយការណ៍ការវិភាគក្សេត្រ-បរិស្ថាន បានឱ្យដឹងថា គ្រួសារមានជីវភាពបង្គួរមានលទ្ធភាពប្រាក់ពីធនាគារ សម្រាប់យកមកចងការបន្តនិងពង្រីក មុខរបរខ្ចី ចំណែកគ្រួសារមានជីវភាពមធ្យមមានខ្ចីពីធនាគារមីក្រូហិរញ្ញវត្ថុនិងឯកជន ដោយឡែកគ្រួសារ ក្រីក្រ២ មានខ្ចីពីឯកជនបន្តក្នុងភូមិមានការប្រាក់ខ្ពស់រហូតពី ២ដល់ ២,៥% ក្នុងមួយខែ ដែលការប្រាក់ខ្ចីពីធនាគារឬពីមីក្រូហិរញ្ញវត្ថុមានត្រឹមតែ ០,៨ ដល់ ១,៥% ក្នុងមួយខែប៉ុណ្ណោះ (ដូចតារាងសង្ខេបខាងក្រោម) ព្រមទាំងគ្រួសារក្រីក្រ១ (ក្រីក្រណាស់) មិនមានលទ្ធភាពខ្ចីប្រាក់នោះទេ ដោយគ្មានទ្រព្យបញ្ចាំ មានតែលក់ពលកម្មនិងចំណាកស្រុក។

តារាងទី១០÷ស្ថានភាពអត្រាការប្រាក់

| ល.រ | ឈ្មោះធនាគារ | អត្រាការប្រាក់ |
|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ០,៨% ដល់ ១% ក្នុង១ខែ |
| ២ | ធនាគារ អេប៊ីអេ | ១,៥០% |
| ៣ | ប្រាសាក់ | ១,៥០% |

ប្រភព÷ *បុគ្គលិកធនាគារ*

### ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅ នៅក្នុងឃុំបន្ទាយចក្រីមានការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់សុទ្ធ ដើម្បីយក ទៅប្រើប្រាស់ពង្រីកមុខរបរ និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ។

### ង. ជំនួយពីប្រភពផ្សេងៗ

បើតាមការសាកសួរក្រុមប្រឹក្សាឃុំបន្ទាយចក្រីបានឱ្យដឹងថា កន្លងមកក៏ដូចបច្ចុប្បន្ន នៅក្នុងឃុំមានគ្រួសារខ្លះ មានប្រភពចំណូលបានពីបងប្អូនកូនចៅដែលរស់នៅអចិន្ត្រៃយ៍ឯប្រទេសក្រៅ និងពលករចំណាកស្រុកផ្តល់ជំនួយបន្ថែមទៀតផងដែរ។

## ១.១.៤.ស្ថានភាពសិក្សាធិការ

### ក. ស្ថានភាពអប់រំ

តាមផែនការអភិវឌ្ឍន៍ឃុំបន្ទាយចក្រី ៥ ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារកុមារី គ្រប់អាយុ ចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ

គ្រួសារដែលជាស្ត្រីមេម៉ាយ ឬក្មេងកំព្រា កុមារពិការក៏ដោយក្តី។ មកដល់ពេលបច្ចុប្បន្នវិស័យអប់រំនៅក្នុងឃុំបន្ទាយចក្រី មានការរីកចម្រើនគួរជាទីមោទនៈ អគារសិក្សាត្រូវបានសាងសង់ថ្មីៗជាច្រើន កន្លែង និងមានការកែលម្អបន្ទប់ឱ្យរៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ។

ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជាខ្វះគ្រូបង្រៀនមិនទាន់មានសាលាមត្តេយ្យសហគមន៍នៅតាមរៀនសូត្រទោះបីមានការយកចិត្តទុកដាក់ជម្រុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ។

រូបភាពទី២÷សាលារៀន



បឋមសិក្សា

តាមឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ នៃមន្ទីរផែនការខេត្ត បានបង្ហាញឱ្យដឹងថាក្នុងឆ្នាំ ២០១៧ នៅក្នុងឃុំបន្ទាយចក្រី មានសាលាមត្តេយ្យចំនួន ០៨កន្លែង និងបឋមសិក្សាមាន ០៩ កន្លែងដែរ ដូចមានក្នុងតារាងដែលក្រុមការងារបានសង្ខេបខាងក្រោម។ តាមស្ថានភាពជាក់ស្តែង សាលារៀននីមួយៗអាចផ្តល់លទ្ធភាពសមស្របដល់កុមារក្នុងការធ្វើដំណើរទៅ សាលារៀន គឺប្រហាក់ប្រហែល ៤,៥គ.ម ពីចំណុចកណ្តាលភូមិទៅសាលារៀន ហើយក៏ឆ្លើយតបទៅនឹង ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលជំរុញការកសាងសាលាបឋមសិក្សាឱ្យបានដល់ភូមិផងដែរ។ បើពិនិត្យទៅលើថ្នាក់រៀនវិញមានក្នុងតារាងទី ១១ ខាងក្រោម) ឃើញថា ចំពោះថ្នាក់មត្តេយ្យ ក្នុង ០៨ ថ្នាក់មានសិស្សចំនួន ២៤៣ នាក់ ហើយថ្នាក់បឋមក្នុង ០៩ ថ្នាក់មាន ៣ ០១០ នាក់ និងថ្នាក់អនុវិទ្យាល័យ ក្នុង០១ ថ្នាក់ មាន ៤៦៩ នាក់ គឺមានភាពសមស្របបើផ្អែកទៅលើបទដ្ឋានរបស់វិស័យអប់រំ។

តារាងទី១១÷ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១. សាលាមត្តេយ្យ | ០៨ | ០៨ | ០៨ | ២៤៣ | ១១៩ | ០៨ | ០៧ |
| ២. សាលាបឋមសិក្សា | ០៩ | ៦០ | ៨៤ | ៣ ០១០ | ១ ០៥៤ | ៥៦ | ៣១ |
| ៣. អនុវិទ្យាល័យ | ០១ | ១១ | ០៨ | ៤៦៩ | ២៤៤ | ០៨ | ០ |

*ប្រភព÷ឯកសារព័ត៌មានស្ថានភាពឃុំពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

### ខ. ស្ថានភាពអក្ខរកម្ម

ចំពោះស្ថានភាពអក្ខរកម្មនៅក្នុងឃុំអក្ខរកម្ម ពិនិត្យឃើញក្នុងឆ្នាំ២០១៧នេះ ដូចមានក្នុងតារាងទី ១២ ខាងក្រោម អ្នកមិនចេះអក្សរពេញវ័យចាប់ពីអាយុ ១៥ដល់ ៦០ឆ្នាំមានចំនួនតែ ២៩៩ នាក់ (ក្នុងនោះមានស្ត្រី ១៤០ នាក់ស្មើនឹង ៤៧% បើធៀបទៅនឹងប្រជាពលរដ្ឋក្នុងឃុំពេញ វ័យចាប់១៥ឆ្នាំ ដល់៦០ ដូចគ្នាឃើញថា អ្នកមិនចេះអក្សរមានប្រមាណតែ ២៤% (ក្នុងតារាងទី ២ ជំពូកទី ១ នៃរបាយការណ៍នេះ មានប្រជាពលរដ្ឋក្នុងឃុំបន្ទាយចក្រី វ័យចាប់ពី១៥ដល់៦០ឆ្នាំមានចំនួន ១ ២៤២ នាក់ ក្នុងឆ្នាំ២០១៧) ដែលនេះបានបង្ហាញឱ្យយើងដឹងថា អត្រាអក្ខរកម្មមនុស្សពេញវ័យនៅ ក្នុងឃុំបន្ទាយចក្រី មានរហូតដល់ ៧៦% ក្នុងឆ្នាំ២០១៧។ ចំពោះអត្រាអក្ខរកម្មនៅក្នុងប្រទេសកម្ពុជាវិញបើយោងទៅតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ បានបង្ហាញថាអត្រាអក្ខរកម្មមនុស្សពេញវ័យពី ១៥ ឆ្នាំឡើងបានកើនពី ៧៨,១% ក្នុងឆ្នាំ២០១៤ ដល់ ៨៥,៥% ក្នុងឆ្នាំ២០១៧។

តារាងទី១២÷ស្ថិតិអ្នកមិនចេះអក្សរ

| ស្ថានភាពអនក្ខរជន | សរុប | ស្រី |
|---|---|---|
| អ្នកមិនចេះអក្សរសរុបអាយុពី(១៥-១៧ឆ្នាំ) | ១០ | ០៤ |
| អ្នកមិនចេះអក្សរសរុបអាយុពី(១៨-២៤ឆ្នាំ) | ១៩ | ០៨ |
| អ្នកមិនចេះអក្សរសរុបអាយុពី( ២៥-៣៥ឆ្នាំ) | ៨០ | ៣៣ |
| អ្នកមិនចេះអក្សរសរុបអាយុពី( ៣៦-៦០ឆ្នាំ) | ១៩០ | ៩៥ |
| ***សរុបរួម*** | ***២៩៩*** | ***១៤០*** |

ប្រភព÷*ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

សរុបមក បើពិនិត្យមើលទៅលើពត៌មានខាងលើបានបង្ហាញឱ្យយើងដឹងថា ស្ថានភាពអក្ខរកម្មនៅក្នុងឃុំបន្ទាយចក្រី ក្នុងឆ្នាំ២០១៧នៅមិនទាន់មានភាពល្អប្រសើរនៅឡើយទេ ដោយមិនទាន់បានបង្កើនអត្រាអក្ខរកម្មមនុស្សពេញវ័យឱ្យកើនឡើងខ្ពស់ទេ បើប្រៀបធៀបទៅនឹងកម្រិតថ្នាក់ជាតិ។

រូបភាពទី៣÷អក្ខរកម្ម






សកម្មភាពបង្រៀនអនក្ខរជននៅក្នុងឃុំបន្ទាយចក្រី

**គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តសិក្សាទៅថ្នាក់ខ្ពស់ទៀត**

យោងតាមឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ បានឱ្យដឹងថាក្នុងឆ្នាំ២០១៧ នៅក្នុងឃុំបន្ទាយចក្រី សិស្សដែលមានលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ ដូចជាពីថ្នាក់អនុវិទ្យាល័យដែលមានចំនួន ៤៦៧នាក់ បានបន្តសិក្សាទៅវិទ្យាល័យតែចំនួន ១៧៤ នាក់ ស្មើនឹង ២៣% ហើយបន្តមកមហាវិទ្យាល័យបាន៨៣នាក់ ស្មើនឹង ១១% ដូចមានតារាងសង្ខេបដែលក្រុមការងារបានរៀបចំខាងក្រោម។ ទន្ទឹមនេះបានឱ្យដឹងទៀតថា សិស្សដែលគ្មានលទ្ធភាពបន្ត ការសិក្សាទៅថ្នាក់ខ្ពស់បានដោយសារមានកត្តាមួយចំនួនដូចជា÷ ទៅតាមឪពុក ម្តាយ ចំណាកស្រុក រកការងារធ្វើបាក់ទឹកចិត្តក្នុងការតស៊ូរៀនបន្តដោយសារភាពវែឆ្លាតមានកម្រិត និងកត្តាជីវភាពដោយត្រូវបោះបង់ការសិក្សាទៅ ប្រកបរបររកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាព។

តារាងទី១៣÷ស្ថិតិអ្នកបន្តការសិក្សាថ្នាក់ខ្ពស់

| ស្ថានភាពសិស្សអាចបន្តការសិក្សាថ្នាក់ខ្ពស់ | សរុប | ស្រី |
|---|---|---|
| អនុវិទ្យាល័យ (អាយុពី១២ ដល់ ១៧ឆ្នាំ) | ៤៦៧ | ២៥៥ |
| វិទ្យាល័យ (អាយុពី១៥ ដល់ ២៤ឆ្នាំ) | ១៧៤ | ៨៥ |
| សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ(អាយុពី១៨ ដល់ ២៤ ឆ្នាំ) | ១៤ | ០៨ |
| សកលវិទ្យាល័យ (អាយុពី១៨ ដល់ ៣៥ឆ្នាំ) | ៨៣ | ៥៨ |

*ប្រភព៖ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

សរុបមក បើពិនិត្យមើលខាងលើបានបង្ហាញឱ្យយើងឃើញថា ស្ថានភាពសិស្សបន្តការសិក្សាថ្នាក់ខ្ពស់នៅក្នុងឃុំបន្ទាយចក្រី ក្នុងឆ្នាំ២០១៧ សិស្សស្រីបានបន្តការសិក្សាលើសពាក់កណ្តាលនៃចំនួនសិស្សសរុប។

**១.១.៥.ស្ថានភាពសុខាភិបាល**

យោងតាមឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រី ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ បានឱ្យដឹងថាក្នុងឆ្នាំ២០១៧ ឃុំបន្ទាយចក្រី មានតែមណ្ឌលសុខភាព ០១ កន្លែងប៉ុណ្ណោះ ស្ថិតនៅភូមិប្របុស

រលួយ ដែលមានបុគ្គលិកពេទ្យចំនួន ០៦ នាក់ ក្នុងនោះ មានពេទ្យឆ្មបចំនួន ០៤ នាក់ បន្ទប់ចំនួន ០៤ និងគ្រែចំនួន ០៦។

ដោយឡែកតាមព័ត៌មានពីផែនការអភិវឌ្ឍន៍ឃុំបន្ទាយចក្រី ៥ ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថាឃុំបន្ទាយចក្រី មិនមានទីតាំងសម្រាលកូនដោយឆ្មបបុរាណនោះទេ ដែលនេះបានឆ្លុះបញ្ចាំងឱ្យឃើញថាប្រជាពលរដ្ឋមានការយល់ដឹងពីសុវត្ថិភាពសុខភាពរបស់ខ្លួនបានល្អប្រសើរ។ ចំពោះជំងឺដែលកាចសាហាវកើតមានដល់ប្រជាពលរដ្ឋនៅក្នុងឃុំបន្ទាយចក្រី មានជំងឺអេដស៍។ ជាក់ស្ដែងក្នុងឆ្នាំ ២០១៧ គ្រួសារ ដែលមានសមាជិកផ្ទុកមេរោគអេដស៍មានចំនួន ០៧ គ្រួសារ។ ចំណែកសុខភាពមាតានិងទារកក្នុងឆ្នាំ ២០១៧ មាន ស្ត្រីសម្រាលកូនដោយពេទ្យឆ្មប ចំនួន ៣៣០ នាក់ និងមរណៈភាពទារកមាន ០៥ នាក់។

ចំណែកការចាក់ថ្នាំបង្ការ និងអាហារូបត្ថម្ភ យោងតាមឯកសារមណ្ឌលសុខភាពមានកុមារនៅឃុំបន្ទាយចក្រី បានទទួលការចាក់ថ្នាំបង្ការជំងឺ ១០០% ហើយកុមារដែលចន្លោះពី ៩-១២ ខែ មានចំនួនសរុប ២៥៧ នាក់ ក្នុងនោះកុមារគ្រប់រូបបានចាក់ថ្នាំបង្ការ និងអាហាររូបត្ថម្ភទាំងអស់។

រូបភាពទី៤÷សុខាភិបាល




មណ្ឌលសុខភាពបន្ទាយចក្រី

យោងតាមឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រី ស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ បានឱ្យដឹងថាចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុត ត្រឹមពី៤ ទៅ ៥ គីឡូម៉ែត្រ ពីភូមិទៅមណ្ឌលសុខភាពដូចមានក្នុងតារាងសង្ខេបខាងក្រោម។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលផ្ដល់ភាពងាយស្រួល ដល់ការបញ្ជូនអ្នកជំងឺ

ទៅកាន់មណ្ឌលសុខភាពបានឆាប់រហ័សទាន់ពេលវេលា។ ប៉ុន្តែបើអ្នកជំងឺឈឺធ្ងន់តម្រូវបញ្ជូន ទៅមន្ទីរពេទ្យបង្អែកស្រុក ឬមន្ទីរពេទ្យខេត្តឱ្យមានចម្ងាយឆ្ងាយ (មានចម្ងាយ ០៧ គ.ម ទៅទីរួមស្រុក និង ៦០ គ.ម ទៅដល់ទីរួមខេត្ត) ការប្រើប្រាស់មធ្យោបាយសម្រាប់ដឹកជញ្ជូនអ្នកជំងឺដោយ ម៉ូតូ រថយន្តឈ្នួល និង រ៉ឺម៉កដែលធ្វើឱ្យការសង្គ្រោះអ្នកជំងឺមានការយឺតយ៉ាវ និងត្រូវចំណាយថវិកាច្រើនជាហេតុបង្កការលំបាកច្រើនដល់ប្រជាពលរដ្ឋ។

តារាងទី១៤÷ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | ភូមិរកាជ្ជទី១ | ១០ គ.ម | |
| ២ | ភូមិរកាជ្ជទី២ | ០៧គ.ម | |
| ៣ | ភូមិរកាជ្ជទី៣ | ១,៥ គ.ម | |
| ៤ | ភូមិជែតា | ៣,៥ គ.ម | |
| ៥ | ភូមិម្រេញ | ១,៥ គ.ម | |
| ៦ | ភូមិពោធិ៍រយំ | ៤ គ.ម | |
| ៧ | ភូមិកគោ | ១៩ គ.ម | |
| ៨ | ភូមិងែកងក | ៦ គ.ម | |
| ៩ | ភូមិប្រោះស្វា | ១២ គ.ម | |
| ១០ | ភូមិដីរស្លាប់ | ៦ គ.ម | |
| ១១ | ភូមិសំពោង | ៥ គ.ម | |
| ១២ | ភូមិតាអឹម | ២ គ.ម | |
| ១៣ | ភូមិបឹងកំពត | ១ គ.ម | |
| ១៤ | ភូមិប្របុសរលួយ | ០,៥ គ.ម | |
| ១៥ | ភូមិមុន្នីសិលា | ១,៨ គ.ម | |
| ១៦ | ភូមិអំពិល | ២,៥ គ.ម | |
| ១៧ | ភូមិពីងពង់ | ៣ គ.ម | |
| ១៨ | ភូមិឬស្សីជុក | ២ គ.ម | |
| ១៩ | ភូមិពោធិ៍ | ១ គ.ម | |
| ២០ | ភូមិពោធិ៍ជ្រែក | ៣ គ.ម | |

ប្រភព÷ *ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

### ១.១.៦.ស្ថានភាពយេនឌ័រ

តាមផែនការអភិវឌ្ឍឃុំបន្ទាយចក្រី រយៈពេល ៥ ឆ្នាំ (២០១៨-២០២២) បានឱ្យដឹងថាសមភាពការងាររបស់ស្ត្រីនិងបុរសក្នុងឃុំបន្ទាយចក្រី នាពេលបច្ចុប្បន្នគ្មានការរើសអើងឬគាបសង្កត់ទៅលើស្ត្រីនោះ

ទេ។ ផ្ទុយទៅវិញការងារយេនឌ័រកំពុងមានការគាំទ្រយ៉ាងពេញទំហឹងជាក់ស្តែង ក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងថ្នាក់ឃុំកំពុងត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការអភិវឌ្ឍឃុំក៏ដូចជាផែនការវិនិយោគផងដែរ។ ទោះជាយ៉ាងនេះក្តីបញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រី ដោយមានមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រ ខ្លះបោះបង់ការសិក្សា ដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពក្នុងគ្រួសារ អ្នកខ្លះចំណាកស្រុកទៅភ្នំពេញ ដើម្បីធ្វើ កម្មកររោងចក្រ។ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំបានសហការជាមួយ មន្ទីរកាកិយាល័យជំនាញ និងដៃគូរអភិវឌ្ឍនាទាជុំវិញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូលនិងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើតាមរយៈរបាយការណ៍នៃការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំបន្ទាយចក្រីឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រ ក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករ ក្នុងឃុំដូចជាមានលម្អិតក្នុងតារាងលម្អិតក្នុងតារាងខាងក្រោម÷

តារាងទី១៥÷ ការវិភាគតួនាទីយេនឌ័រក្នុងឃុំបន្ទាយចក្រី

| **សកម្មភាព** | **បុរស** | **ស្ត្រី** | **យោបល់បន្ថែម** |
|---|---|---|---|
| **សកម្មភាពស្រូវរដូវវស្សានិងប្រាំង** | | | |
| -រៀបចំដីលើកទី១ | ១០០% | ០% | ស្ត្រីដាំបាយនៅផ្ទះ យកទៅស្រែ |
| -រៀបចំដីលើកទី២ | ៨០% | ២០% | ស្ត្រីជួយសំអាតស្មៅ ដាំបាយនៅផ្ទះ យកទៅស្រែ |
| -ត្រាំងគ្រាប់ពូជ | ៧០% | ៣០% | ស្ត្រីជួយសំអាតគ្រាប់ពូជ និងជួយត្រាំពូជស្រូវ |
| -ព្រួសគ្រាប់ពូជ | ៨៥% | ១៥% | បុរសមានកម្លាំងព្រោះបានលឿនជាងស្ត្រី |
| -បាចជី | ៨០% | ២០% | ស្ត្រីជាអ្នកចែករំលែក និងបាចជីខ្លះៗ |
| -ការគ្រប់គ្រងទឹកក្នុងស្រែ | ៦០% | ៤០% | ស្ត្រីដាំបាយនៅផ្ទះយកទៅស្រែ |
| -បាញ់ថ្នាំស្មៅនិងថ្នាំសម្លាប់សត្វល្អិត | ៩០% | ១០% | ស្ត្រីចូលរួមចំណែកកិច្ចការនេះជាមួយបុរស |
| -ការច្រូតកាត់ | ៨០% | ២០% | ភាគច្រើនច្រូតដោយម៉ាស៊ីន(ស្ត្រីជួយដេរបាវ) |
| -ការដឹកជញ្ជូនគ្រាប់ស្រូវ | ១០០% | ០% | ប្រើដោយម៉ាស៊ីនគោយន្ត |
| -ទុកដាក់ស្រូវ | ៥០% | ៥០% | ដោយស្ត្រីជួយប្រមូលដាក់ទុកក្នុងបាវ និងដេរបាវ |
| -សម្ងួតស្រូវ | ៥០% | ៥០% | ជិតផ្ទះជួយគ្នា |
| -លក់ដូរស្រូវ | ៥០% | ៥០% | ការសម្រេចចិត្តទាំងអស់គ្នា |
| **សកម្មភាពមុខរបរចិញ្ចឹមជីវិតផ្សេងទៀត** | | | |
| -សួនបន្លែគ្រួសារ | ៣០% | ៧០% | មូលហេតុបុរសទៅធ្វើការធ្ងន់នៅខាងក្រៅ |
| -ចិញ្ចឹមជ្រូក | ២០% | ៨០% | ស្ត្រីនៅផ្ទះទំនេរជាងបុរស |

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| -ចិញ្ចឹមគោ-ក្របី | ៧០% | ៣០% | ស្ត្រីអាចរកស្មៅ |
| -ចិញ្ចឹមមាន់-ទា | ១០% | ៩០% | ស្ត្រីនៅផ្ទះទំនេរជាងបុរស |
| -រកឧស | ៩០% | ១០% | ស្ត្រីនៅចាំផ្ទះ |
| -ការនេសាទត្រី | ៩០% | ១០% | ការនេសាទនៅឆ្ងាយផ្ទះ |
| -លក់ដូរ(ជំនួញ) | ៤០% | ៦០% | បុរសចូលរួមដឹកជញ្ជូន |
| -ថែទាំប្រព័ន្ធធារាសាស្ត្រ | ៨០% | ២០% | ស្ត្រីចូលរួមជាគណៈកម្មការនិងផ្តល់គំនិត |

*ប្រភព៖របាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំបន្ទាយចក្រី ឆ្នាំ២០១៧*

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំបន្ទាយចក្រី ឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំបន្ទាយចកក្រីដូចខាងក្រោម÷

១. រាល់ការដំណោះស្រាយផ្សេងៗ បុរសមានសិទ្ធិច្រើនជាងស្ត្រីក្នុងការសម្រេចចិត្ត

២. ការងារក្នុងផ្ទះភាគច្រើនស្ត្រីជាអ្នកធ្វើ

៣. បុរសភាគច្រើនមិនទាន់ស្វែបានជួយការងារផ្ទះជំនួសស្ត្រី

៤. បុរសនៅមិនទាន់ផ្តល់ឱកាស និងឱ្យតម្លៃស្ត្រី ស្មើភាពនៅឡើយ

៥. ស្ត្រីមួយចំនួននៅទទួលរងអំពើហឹង្សាក្នុងគ្រួសារនៅឡើយ

តាមប្រភពព័តិមានដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំបន្ទាយចក្រី យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើងធ្ងន់ធរនោះទេ ជាពិសេសការងាររៀបចំដីស្រែគឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជាការងារធ្វើស្រែឃើញបុរសមានការចូលរួមច្រើនជាងស្ត្រី ឃើញការងារនេះបុរសទទួលរ៉ាប់រងទាំងស្រុង ដែលស្ត្រីមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ហើយក៏ឃើញការងារដឹកជញ្ជូនគ្រាប់ស្រូវបាញ់ថ្នាំសម្លាប់ សត្វល្អិត និងដាក់ជីច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើម គឺបុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងគ្រួសារក្នុងផ្ទះនិងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែក្នុងនោះក៏បានរកឃើញថាការសម្រេចចិត្តក្នុងគ្រួសារបុរសនៅមានសិទ្ធច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហឹង្សាក្នុងគ្រួសារនៅឡើយ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយក៏យើងឃើញកិច្ចការនេះមានអភិវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង។

រូបភាពទី៥÷សកម្មភាពយេនឌ័រ





ស្ត្រីចូលរួមជាមួយបុរសក្នុងការធ្វើផែនការប្រើប្រាស់ដីថ្នាក់ឃុំ

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១.ទីតាំងភូមិសាស្ត្រ

ឃុំបន្ទាយចក្រី ស្ថិតក្នុងស្រុកព្រះស្ដេច ខេត្តព្រៃវែង មានទីតាំងនៅចន្លោះពីអ័ក្ស X ស្មើនឹង ៥៣៨000mEដល់ ៥៤៨000mE និង អ័ក្ស Y ស្មើនឹង ១២២២000mN ដល់ ១២២000mN មានប្រព័ន្ធនិយាមការ WGS 1984 UTM Zone 48N។ សណ្ឋានដីនៅក្នុងឃុំបន្ទាយចក្រី ផ្អែកតាមរបាយ-ការណ៍ស្ដីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ បានឱ្យដឹងថាជាដីរាបស្មើ និងជំរាលតិចហើយបានចែកចេញជា 0៤ តំបន់គឺ តំបន់ទី១ ជាតំបន់ស្រែវស្សានិងបង្កើនរដូវ១ដងមានដីជាប្រភេទដីល្បាយខ្សាច់ និងដីខ្មៅ(អាចម៍កណ្ដុរ) និងតំបន់ទី២ ជាតំបន់លំនៅឋាន និងសួនបន្លែចម្រុះមានដីជាប្រភេទដីល្បាយខ្សាច់ តំបន់ទី៣ ជាតំបន់ស្រែវស្សានិងបង្កើនរដូវ២ដង ជាប្រភេទដីល្បាយខ្សាច់និង ដីខ្មៅ(អាចម៍កណ្ដុរ) និង តំបន់ទី ៤ ជាតំបន់ប្រភពទឹក។ តែបើយើងពិនិត្យទៅលើផែនទីរយៈកម្ពស់ដីនៅក្នុងឃុំបន្ទាយចក្រី ឃើញថាមានរាងជាដីទំនាបរាបស្មើ ដែលមានកម្ពស់ ៥ ម៉ែត្រស្មើគ្នានៅទូទាំងឃុំ។

ដីនៅក្នុងឃុំបន្ទាយចក្រីទាំងបួនតំបន់នេះ បច្ចុប្បន្នភាគច្រើនលើសលប់ត្រូវបានប្រើប្រាស់សម្រាប់កសិកម្មដំណាំស្រូវ និងលំនៅឋានភូមិ។

ផែនទី៣÷រយៈកម្ពស់ដីនៅក្នុងឃុំបន្ទាយចក្រី ស្រុកព្រះស្ដេច

# ផែនទីរយៈកម្ពស់ ឃុំបន្ទាយចក្រី



ផែនទី៤÷តំបន់កំណត់តំបន់កេ្សត្របរិស្ថានឃុំបន្ទាយចក្រី




*ប្រភព÷របាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ- បរិស្ថានឃុំបន្ទាយចក្រីឆ្នាំ២០១៧*

# តារាងទី១៦÷ពំនុះកាត់ទទឹងឃុំបន្ទាយចក្រី

| តំបន់ / បរិយាយ | តំបន់ I | តំបន់ II | តំបន់ IV | តំបន់ V |
|---|---|---|---|---|
| រូបថតតំណាងតំបន់កសិប្រព័ន្ធ-បរិស្ថានឃុំបន្ទាយចក្រី |  |  |  |  |
| ប្រភេទដី | ដីល្បាយខ្សាច់<br>ដីខ្មៅ(អាចម៍កណ្តុរ) | ដីល្បាយខ្សាច់ | ដីល្បាយខ្សាច់<br>ដីខ្មៅ(អាចម៍កណ្តុរ) | ដីល្បាយឥដ្ឋ |
| ជលសាស្ត្រ | គ្មានការលិចលង់ទេ | គ្មានទឹកជំនន់ | គ្មានការលិចលង់ទេ | គ្មានការលិចលង់ទេ |
| ប្រភពទឹក | - ទឹកភ្លៀង<br>- ប្រឡាយ | - ទឹកភ្លៀង<br>- ទឹកអណ្តូង | - ទឹកភ្លៀង<br>- ប្រឡាយ | - ទឹកភ្លៀង<br>- ទឹកទន្លេ |
| ការដាំដុះ | - ស្រូវកណ្តាល(ផ្ការំដួល,ក្រសាំងទាប)<br>- ស្រូវស្រាល(អ៊ីអ៊េរ ៥០៤ )<br>- ស្រូវធ្ងន់(ផង្គង់ខ្មៅ ) | - ដំណាំបន្លែ(ត្រសក់,សណ្តែកកួរ,ត្រប់,ននោង,ស្ពៃត្រគួន )<br>- ឈើហូបផ្លែ(ដូង,ចេក,ស្វាយ, ខ្នុរ) | - ស្រូវកណ្តាល(ផ្ការំដួល,ក្រសាំងទាប)<br>- ស្រូវស្រាល(អ៊ីអ៊េរ ៥០៤ )<br>- ស្រូវធ្ងន់(ផង្គង់ខ្មៅ ) | - គ្មានការដាំដុះ |
| ប្រភេទពូជស្រូវ | - ពូជអ៊ីអ៊េរ ៥០៤<br>- ពូជក្រសាំងទាប<br>- ពូជផង្គង់ខ្មៅ | - ចិញ្ចឹមសត្វ<br>- សួនបន្លែគ្រួសារ<br>- ឈើហូបផ្លែ | - ពូជអ៊ីអ៊េរ ៥០៤<br>- ពូជក្រសាំងទាប<br>- ពូជផង្គង់ខ្មៅ | - គ្មានការធ្វើស្រែ |
| សត្វ | - វាលស្មៅសត្វក្រោយប្រមូលផល | - គោ,ជ្រូក,មាន់,ទា | - វាលស្មៅសត្វក្រោយប្រមូលផល | - គ្មានការចញ្ចឹមសត្វ |
| ការប្រើប្រាស់ដី | - ស្រូវវស្សា (៥ទៅ៦បាវ)<br>- អ៊ុយរ៉េ និងដី៤ពណ៌<br>- . ស្រូវបង្កើនដូវ(៧ទៅ៨បាវ)<br>- អ៊ុយរ៉េ និងដី៤ពណ៌ | - ប្រើធម្មជាតិ និងគីមីខ្លះលើដំណាំបន្លែ | - ស្រូវវស្សា (៥ទៅ៦បាវ)<br>- អ៊ុយរ៉េ និងដី៤ពណ៌<br>- . ស្រូវប្រាំង និងបង្កើនដូវ(៦ទៅ៨បាវ)<br>អ៊ុយរ៉េ និងដី៤ពណ៌ | - គ្មានការធ្វើស្រែ |
| បញ្ហាទូទៅតាមតំបន់ | - ដង្កូវ,ជំងឺក្រា,ដង្កូវស៊ីស្លឹក ដង្កូវស៊ីរូងដើម, ជំងឺរលាកកកួរ<br>- រាំងស្ងួត<br>- ខ្វះទឹក<br>- ខ្វះប្រព័ន្ធស្រោចស្រព<br>- អណ្តូងស្រោចស្រពបូមមិន<br>- ចេញ<br>- តម្លៃស្រូវប្រែប្រួលខ្លាំង<br>- ដីចុះថយជីជាតិ<br>- ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>- ជំងឺសត្វ<br>- ធាតុចូលកសិកម្មថ្លៃ | - សត្វល្អិតបំផ្លាញលើដំណាំបន្លែ<br>- រាំងស្ងួត<br>- ខ្វះទឹកស្រោចដំណាំ<br>- ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>- ជំងឺសត្វ<br>- ធាតុចូលកសិកម្មថ្លៃ | - ដង្កូវ ,ជំងឺក្រា,ដង្កូវស៊ីស្លឹក ដង្កូវស៊ីរូងដើម,ជំងឺរលាកកកួរ<br>- រាំងស្ងួត<br>- ខ្វះទឹក<br>- ខ្វះប្រព័ន្ធស្រោចស្រព<br>- អណ្តូងស្រោចស្រពបូមមិនចេញ<br>- តម្លៃស្រូវប្រែប្រួលខ្លាំង<br>- ដីចុះថយជីជាតិ<br>- ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>- ជំងឺសត្វ<br>- ធាតុចូលកសិកម្មថ្លៃ | - គ្មានការធ្វើស្រែ<br>- អ្នកចិញ្ចឹមទាមកពីក្រៅ<br>- បាក់ច្រាំងទន្លេសីហា |
| ឱកាស | - . បង្កើនទិន្នផលស្រូវ<br>- (វស្សា ៤តោននិងប្រាំង ៦តោន)<br>- បង្កើនដូវដាំដុះ២.៣ដង<br>- កែប្រែគុណភាពដី<br>- សិក្សាពីបច្ចេកទេសកសិកម្មថ្មីៗ<br>- គៀរពង្រាបដីអោយស្មើ | - ដាំដុះដំណាំឈើហូបផ្លែ<br>- ដាំដុះដំណាំបន្លែ<br>- ចិញ្ចឹមសត្វ<br>- កែប្រែគុណភាពដី<br>- សិក្សាពីបច្ចេកទេសកសិកម្មថ្មីៗ<br>- គៀរពង្រាបដីអោយស្មើ | - . បង្កើនទិន្នផលស្រូវ<br>- (វស្សា ៤តោននិងប្រាំង ៦តោន)<br>- បង្កើនដូវដាំដុះ២.៣ដង<br>- កែប្រែគុណភាពដី<br>- សិក្សាពីបច្ចេកទេសកសិកម្មថ្មីៗ<br>- គៀរពង្រាបដីអោយស្មើ | - . ហាមឃាត់អ្នកចិញ្ចឹមទាមកពីក្រៅ<br>- ដាំកូនឈើតាមមាត់ទន្លេ<br>- ដាំស្មៅការពារការហូរច្រោះ |

ប្រភព÷*របាយការណ៍ស្តីពីការវិភាគប្រព័ន្ធកសិប្រព័ន្ធ-បរិស្ថាន ឃុំបន្ទាយចក្រី ឆ្នាំ២០១៧*

តាមការស្វែងយល់របស់ក្រុមការងារបានឱ្យដឹងថា បច្ចុប្បន្ននៅក្នុងឃុំបន្ទាយចក្រីមានប្រភពទឹកភ្លៀង និងប្រឡាយមេ ៣ខ្សែ ប្រឡាយមេទី១ គឺប្រឡាយអូរស្នាត មានចម្ងាយប្រមាណ ៧ ៥០០ម៉ែត្រ ប្រឡាយទី២ គឺប្រឡាយអន្លង់ចារ មានចម្ងាយ ៣ ៦០០ម៉ែត្រ ដែលប្រឡាយ នេះមានប្រភពទឹកមកពីដៃ ទន្លេសីហា និង ប្រឡាយទី៣ គឺប្រឡាយទួលធាតុ មានចម្ងាយប្រមាណ ៦ ៥០០ ម៉ែត្រ ប្រឡាយនេះមានប្រភពទឹកមកពី ប្រឡាយបឹងកំពក ដែលមានបណ្តាញតភ្ជាប់មកពីបឹងព្រីង កាត់តាមឃុំព្រះស្តេច ចម្ងាយប្រមាណ០៨ គីឡូម៉ែត្រ នៅក្នុងឃុំបន្ទាយចក្រី មានការប្រើប្រាស់តាមរយៈអណ្តូង ស្នប់ សម្រាប់ស្រោចស្រព និងសម្រាប់ការប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតែប៉ុណ្ណោះ។

រូបភាពទី៦÷ប្រឡាយ



ប្រឡាយមេ

ផែនទី៥÷ប្រព័ន្ធធារាសាស្ត្របច្ចុប្បន្នឃុំបន្ទាយចក្រី




## ១.២.២.អាកាសធាតុ

តាមប្រភពព័ត៌មានពីមន្ទីរធនធានទឹក និងឧត្តុនិយម ខេត្តព្រៃវែង បានឱ្យដឹងថា ស្រុកព្រះស្ដេច មាន អាកាសធាតុគឺក្ដៅហើយសើមស្មើរតែពេញមួយឆ្នាំ។ អាកាសធាតុនេះបាននាំឱ្យឃុំបន្ទាយចក្រីមានរដូវពីរ ចែកដាច់ពីគ្នាគឺរដូវវស្សា និងរដូវប្រាំង។ រដូវវស្សាចាប់ផ្ដើមពីខែឧសភា រហូតដល់ ខែតុលា ចំណែករដូវប្រាំង

វិញចាប់ផ្តើមពីខែវិច្ឆិកា រហូតដល់ ខែមេសា ហើយចន្លោះខែធ្នូទៅខែមករា គឺជាខែរងាររហើយខែ ដែលក្តៅបំផុតគឺខែមេសា។ សីតុណ្ហភាពជាមធ្យមមានកម្រិតអតិបរិមា៣ ៣,៤ អង្សា និងអប្បបរិមា ២៤,៨ អង្សាសេ ដោយឡែក ក្នុងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ ពិនិត្យឃើញមានកំដៅខុស ប្រក្រតីកើនឡើងរហូតដល់កម្រិតអតិបរិមា៣ ៩,០ អង្សាសេ។ ចំណែករំហួតជាមធ្យម ២,៩ ម.ម និង សំណើម ជាមធ្យម ៧៣% ព្រមទាំងបរិមាណទឹកភ្លៀងដូចមានក្នុងតារាងដែលក្រុមការងារបានរៀបចំខាងក្រោមគឺ បង្ហាញឱ្យឃើញថា ពីឆ្នាំ២០១២ ដល់ ២០១៧ បរិមាណទឹកភ្លៀងខ្ពស់ជាងគេគឺនៅក្នុងឆ្នាំ២០១៧ និង បរិមាណទឹកភ្លៀងដែលទាបជាងគេក្នុងឆ្នាំ២០១២ និង២០១៣។

តារាងទី១៧÷បរិមាណទឹកភ្លៀងស្រុកព្រះស្តេច

| ឆ្នាំ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| មករា | ៤៣,៨ | ០ | ០ | ០ | ០ | ០ |
| កុម្ភៈ | ១៤,៩ | ១០,២ | ០ | ០ | ០ | ២,៥ |
| មិនា | ៤៦,៧ | ០ | ១១,២ | ៣,២ | ០ | ៧៧,៥ |
| មេសា | ១៨៩.៦ | ១៦១,៧ | ៩០,៥ | ៣៣,៨ | ១០១,៣ | ១៤១,០ |
| ឧសភា | ១២៧,២ | ៥៥,៧ | ១២២,៧ | ១២៤,៣ | ២៤៥,៧ | ៣៣៧,០ |
| មិថុនា | ១១៧,៤ | ១៨៩,៣ | ២០៥,០ | ២០៧,៧ | ១៦៤,៤ | ២៣២,៧ |
| កក្កដា | ៧៨,៧ | ២០៧,៦ | ២៧៧,៤ | ១៣០,៧ | ១១៨,៧ | ២០២,៦ |
| សីហា | ៩៩,៨ | ១៣០,៨ | ៧៦,២ | ១៣,៥ | ១៥៣,៣ | ៣២២,២ |
| កញ្ញា | ១៨០,៣ | ១៧២,៨ | ៧៥,៥ | ២៤២,៨ | ១៧០,០ | ១៦៤,៤ |
| តុលា | ១៧៨,០ | ១៤០,០ | ១៧២,៦ | ១៣២,៧ | ៤៦៥,៧ | ១៧៥,៩ |
| វិច្ឆកា | ១៣២,៦ | ១១១,១ | ១៥៣,៨ | ៣៩,៥ | ១៤១,៧ | ៨១,៩ |
| ធ្នូ | ០ | ៣៧,០ | ៧២,៤ | ១៣,៣ | ២៨,៧ | ០ |

### ១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវ គោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ដែលបច្ចុប្បន្ន ឃុំបន្ទាយចក្រីមានតែប្រព័ន្ធគមនាគមន៍ផ្លូវគោកតែប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលក្នុងនោះមានផ្លូវជាតិលេខ ៣១២ ផ្លូវគ្រួសក្រហម ឬក្រាលថ្ម និងផ្លូវដីសរ ឬផ្លូវលំ គឺជាការផ្តល់ឱកាសឱ្យឃុំអាចទាញយកប្រយោជន៍ពី ការអភិវឌ្ឍន៍ តាមផ្លូវនេះ ទៅថ្ងៃអនាគតបាន។ ទន្ទឹមនេះ ឃុំបន្ទាយចក្រី នៅមានផ្លូវផ្សេងទៀតគ្រប់គ្រាន់ អាចភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំផ្សេងៗ ព្រមទាំងទីរួមខេត្តព្រៃវែងផងដែរ។ ឃុំបន្ទាយចក្រី មានផ្លូវសំខាន់ៗដូចខាងក្រោម÷

**-ផ្លូវជាតិលេខ៣១២ មានចំនួន ០១ខ្សែ និងមានប្រវែង ១២,៧៣គ.ម÷**

-តភ្ជាប់ពីឃុំអង្គររាជ្យដល់ប្រទេសវៀតណាម ឆ្លងកាត់ភូមិពោធិ៍ ភូមិប្របុសរលួយ ភូមិតាអឹម ភូមិពោធិ៍

ជ្រែក ភូមិសំពោង ភូមិដំរីស្លាប់ និងភូមិកគោ។

**-ផ្លូវគ្រួសក្រហម ឬក្រាលថ្ម មានចំនួន ០១ខ្សែ និងមានប្រវែង ៨,៦៥គ.ម÷**

-តភ្ជាប់ពីឃុំអង្គររាជ្យដល់ភូមិកគោ ឆ្លងកាត់ភូមិម្រេញ ភូមិដៃតា ភូមិងៃកងក និងភូមិកគោ ។

**-ផ្លូវដីសរ ឬផ្លូវលំ មានចំនួន ១០ខ្សែ និងមានប្រវែង ៤៤,៩គ.ម÷**

ខ្សែទី១÷ចេញពីផ្លូវជាតិលេខ៣១២រហូតដល់ផ្លូវជាតិលេខ៣១២វិញ ឆ្លងកាត់ភូមិឬស្សីជុក ភូមិពីងពង់ ភូមិអំពិល និងភូមិមុន្នីសិលា មានប្រវែង ៥,៣២គ.ម។

ខ្សែទី២÷ ចេញពីផ្លូវជាតិលេខ៣១២ឆ្ពោះទៅទិសខាងកើត ឆ្លងកាត់ភូមិមប្របុសរល្ងួយ ភូមិម្រេញ ភូមិពោធិ៍រយំ ភូមិរកាជួរទី១ និងភូមិរកាជួរទី២ មានប្រវែង ៦,៤៣គ.ម។

ខ្សែទី៣÷ អមតាមប្រឡាយទួលធាតុរហូតដល់ផ្លូវជាតិលេខ៣១២ ចេញពីឃុំបឹងដោល ឆ្លងកាត់ភូមិអំពិល ភូមិមុន្នីសិលា និងភូមិប្របុសរល្ងួយ មានប្រវែង ២គ.ម។

ខ្សែទី៤÷ ចេញពីផ្លូវជាតិលេខ៣១២ រហូតដល់ឃុំពាមមន្ទា ឆ្ពោះទៅទិសខាងកើត ឆ្លងកាត់ភូមិដំរីស្លាប់ ភូមិប្រោះស្វា ភូមិកគោ និងភូមិងៃកងក មានប្រវែង ៥,៩៣គ.ម

ខ្សែទី៥÷ចេញពីផ្លូវជាតិលេខ៣១២ ឆ្ពោះទៅទិសខាងលិច ស្ថិតក្នុងភូមិប្រោះស្វា មានប្រវែង ៣,២៨គ.ម។

ខ្សែទី៦÷ ចេញពីឃុំអង្គររាជ្យ រហូតដល់ផ្លូវជាតិលេខ៣១២ ឆ្លងកាត់ភូមិម្រេញ ភូមិដៃតា ភូមិកគោ មានប្រវែង ៥,២គ.ម។

ខ្សែទី៧÷ ចេញពីផ្លូវខ្សែទី២ រហូតដល់ភូមិកគោ ឆ្លងកាត់ភូមិពោធិ៍រយំ ភូមិដៃតា ភូមិងៃកងក និងភូមិកគោ មានប្រវែង៦,២គ.ម។

ខ្សែទី៨÷ ចេញពីឃុំបន្ទាយចក្រី រហូតដល់ប្រឡាយអូរស្មាន ឆ្លងកាត់ភូមិរកាជួរទី១ ភូមិរកាជួរទី២ និងភូមិរកាជួរទី៣ មានប្រវែង២.៦គ.ម។

ខ្សែទី៩÷ចេញពីផ្លូវខ្សែទី៥ ឆ្ពោះទៅទិសខាងត្បូងរហូតដល់ទន្លេសីហា ស្ថិតក្នុងភូមិប្រោះស្វាមានប្រវែង ២.៣គ.ម។។

ខ្សែទី១០÷ ចេញពីព្រំប្រទល់ភូមិសំពោង រហូតដល់ទន្លេសីហា ឆ្លងកាត់ភូមិដំរីស្លាប់ និងភូមិប្រោះ ស្វា មានប្រវែង៥,៧គ.ម។

រូបភាពទី៧÷ស្ថានភាពបណ្តាញផ្លូវក្នុងឃុំបន្ទាយចក្រី





ផ្លូវដីសរ ឬផ្លូវលំ (ផ្លូវចូលភូមិ)

ផែនទី៦÷ហេដ្ឋារចនាសម្ព័ន្ធឃុំបន្ទាយចក្រី ស្រុកព្រះស្តេច



### ១.២.៤.បរិក្ខាសាធារណៈ

### ក. ស្ថានភាពប្រើប្រាស់អគ្គិសនី

យោងតាមឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រី ស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ បានឱ្យដឹងថាក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋដែលបានប្រើប្រាស់បណ្ដាញអគ្គិសនីភាគច្រើននៅតំបន់លំនៅឋាន ដែលស្ថិតក្នុងភូមិបន្ទាយចក្រី ប្រមាណ ៧៥១ គ្រួសារ ស្មើនឹង ៤៩,០២ ភាគរយ។ ចំណែកប្រជាជនដែលរស់នៅឆ្ងាយពិទីប្រជុំជន ប្រើប្រាស់បន្ទះសូឡាមាន ចំនួន ៧៦៨ គ្រួសារ ស្មើនឹង ៥០,១៣ ភាគរយ។ រីឯប្រជាជនតិចតួចបានប្រើប្រាស់ឡជីវឧស្ម័នមានចំនួន ១៣ គ្រួសារ ស្មើនឹង ០,៨៥ ភាគរយ ដូចមានក្នុងតារាងសង្ខេបខាងក្រោម។

តារាងទី១៨÷ស្ថិតិគ្រួសារដែលប្រើប្រាស់បណ្ដាញអគ្គិសនី

| ល.រ | ប្រភេទ | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|---|
| ១ | ផ្ទះបំភ្លឺដោយសារបណ្ដាញអគ្គិសនី | ៧៥១ | ៤៩ |
| ២ | ផ្ទះបំភ្លឺដោយបន្ទះសូឡា | ៧៦៨ | ៥០ |
| ៣ | ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | ១៣ | ១ |

ប្រភព÷*ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

បើពិនិត្យមើលតារាងខាងលើបានបង្ហាញថា ចំនួនគ្រួសារសរុបក្នុងឃុំបន្ទាយចក្រីចំនួន ៣ ៩១១ គ្រួសារហើយចំនួនខ្នងផ្ទះដែលប្រើប្រាស់ភ្លើងបំភ្លឺក្នុងផ្ទះសរុបចំនួន ១ ៥៣២ខ្នង ដោយផ្ទះមួយចំនួនគាត់នៅជាមួយគ្នា ២ ឬ ៣ គ្រួសារ។

រូបភាពទី៧÷បណ្ដាញអគ្គិនី






បង្គោលខ្សែបណ្ដាញអគ្គិសនីក្នុងឃុំបន្ទាយចក្រី

## ខ. ប្រព័ន្ធទឹកស្អាត

យោងតាមឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ បានឱ្យដឹងថាក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋបានប្រើប្រាស់ទឹកអណ្ដូង អណ្ដូងចម្រុះ ទឹកម៉ាស៊ីនឬទឹកបរិសុទ្ធ និងឧបករណ៍ចម្រោះទឹកស្អាតនៅឃុំបន្ទាយចក្រី ជាពិសេសនៅតាមតំបន់ទីប្រជុំជន ប្រមាណ ៣ ៧៦៥ គ្រួសារ ស្មើនឹង៧៧ ភាគរយដូចមានតាមតារាងសង្ខេបខាងក្រោម។

តារាងទី១៩÷ស្ថិតិគ្រួសារដែលប្រើប្រាស់បណ្ដាញទឹក

| ល.រ | ប្រភេទ | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|---|
| ១ | ទឹកអណ្ដូងស្នប់ អណ្ដូងចម្រុះ | ៣ ៧៦៥ | ៧៧ |
| ២ | ទឹកម៉ាស៊ីនឬទឹកបរិសុទ្ធ | ៤៤៧ | ៩ |
| ៣ | ឧបករណ៍ចម្រុះទឹកស្អាត | ៧០៤ | ១៤ |

ប្រភព÷*ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៧ នៃមន្ទីរផែនការខេត្ត*

រូបភាពទី៩÷បណ្ដាញទឹក





អណ្ដូងស្នប់របស់សហគមន៍នៅក្នុងឃុំបន្ទាយចក្រី

# ១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១.ស្ថានភាពកាន់កាប់ និងគ្រប់គ្រងដី

ផែនទី៧÷ប្រើប្រាស់ដីបច្ចុប្បន្នសាមញ្ញឃុំបន្ទាយចក្រី



# ផែនទីប្រើប្រាស់ដីលម្អិត ឃុំបន្ទាយចក្រី













## សញ្ញាសម្គាល់

- សាលាឃុំ
- ព្រំប្រទល់ឃុំ( តាមការចុះបញ្ជី)

### ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន

- វត្ត
- សាលារៀន
- មណ្ឌលសុខភាព
- ផ្លូវជាតិលេខ៣១២
- ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ផ្លូវដីស ឬផ្លូវលំ
- ប្រឡាយទឹករង

### ការប្រើប្រាស់ដី

- ដីលំនៅឋានភូមិ
- ដីលំនៅឋានទីប្រជុំជន
- ដីស្រែវស្សា
- ទន្លេ

## ប្រព័ន្ធកូអរដោនេ:

ចំណោលផែនទី: UTM

តំបន់ទី: 48N

ទិន្នន័យយោង: WGS 1984

ផលីបស្វ៊ីត: WGS 1984

## ប្រភពទិន្នន័យ:

- ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាល ប្រភពពីនាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(២០១៩)
- ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត។

## បញ្ជាក់:

- ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើង នៅថ្នាក់ជាតិ និងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
- ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
- ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................. ឆ្នាំ ២០.....

គាំទ្រដោយ: ADB GAFSP

អនុវត្តដោយ:

លេខ:...............................

បានឃើញ និងឯកភាព

ធ្វើនៅឃុំបន្ទាយចក្រី ថ្ងៃ................ ខែ............ ឆ្នាំ.......... ស័ក ព.ស២៥៦...

ត្រូវនឹងថ្ងៃទី..........ខែ.................. ឆ្នាំ ២០......

មេឃុំបន្ទាយចក្រី

តារាងទី២០÷ តារាងរាយលម្អិតតាមប្រភេទការប្រើប្រាស់ដីបច្ចុប្បន្ន

| **ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមបច្ចេកទេស)** | **ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន)** | **ក្រឡាផ្ទៃ(ហិកតា)** | **ភាគរយ** | **ផ្សេង** |
|---|---|---|---|---|
| **ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **១ ៧០១** | ២០% | |
| ដីលំនៅឋាន ទីប្រជុំជន | ដីផ្សារ | ៤២ | | រួមទាំងផ្លូវនិងប្រឡាយ |
| ដីលំនៅឋាន ភូមិ | ដីភូមិ | ១ ៦៥៩ | | រួមទាំងផ្លូវនិងប្រឡាយ |
| **ខ. ដីកសិកម្ម** | | **៦ ៥៧៣** | ៧៩% | |
| ដីស្រែវស្សា | ដីស្រែ | ៦ ៥៧៣ | | រួមទាំងផ្លូវនិងប្រឡាយ |
| **គ. ផ្ទៃទឹក និងខ្សែទឹក** | | **៣៩** | ១% | |
| ទន្លេ | ផ្ទៃទឹក | ៣៩ | | ផ្ទៃទឹក |
| **សរុប** | | **៨ ៣១៣** | ១០០% | |

### ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

- **ដីលំនៅឋាន ទីប្រជុំជន**

ដីលំនៅឋាន ទីប្រជុំជន គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានដែលប្រមូលផ្តុំគ្នាច្រើន ហើយជាកន្លែងផ្តល់សេវាកម្ម ដូចជាលក់ដូរទំនិញ ជាងជួសជុល អាហារដ្ឋាន ភេសជ្ជៈដ្ឋាន សេវាសុខភាព សេវាអប់រំ។ល។ ដោយមិនសំដៅទីប្រជុំជន ដែលបានកំណត់ដោយក្រសួងផែនការនោះឡើយ ព្រមទាំងមាន ទីតាំងផ្សារណាត់លក់ដូរបន្លែ សាច់មួយកន្លែងផងដែរ។ នៅក្នុងឃុំបន្ទាយចក្រី ដីលំនៅឋាន ទីប្រជុំជនមាន បីកន្លែង ស្ថិតក្នុងភូមិគី ភូមិសំពោង ភូមិតាអឹម និងភូមិប្របុសរលួយ។ ដីលំនៅឋាន ទីប្រជុំជន គឺជាដីដែលបាន កាន់កាប់ដោយប្រជាពលរដ្ឋ(ដីកម្មសិទ្ធឯកជន) មានទំហំផ្ទៃដីចំនួន ៤២ ហិកតា ត្រូវបានចុះបញ្ជីកាន់កាប់ជា ប្រព័ន្ធរួចរាល់១០០%។

រូបភាពទី១០÷ដីលំនៅឋាន ទីប្រជុំជន





ទិដ្ឋភាពដីលំនៅឋាន ទីប្រជុំជន

–

- **ដីលំនៅឋាន ភូមិ**

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ។ នៅក្នុងឃុំ ដីលំនៅឋាន ភូមិ មាន០៥ តំបន់ប្រមូលផ្តុំភូមិគឺ តំបន់ទី១ ស្ថិតនៅតាមផ្លូវលំត្រង់ចំណុចមានចេញពីឃុំពឹងពង់ ភូមិឬស្សីផុក ភូមិអំពិល ភូមិមុន្នីសិលា តំបន់ទី២ មានចំនួន ស្ថិតនៅអមផ្លូវជាតិកៅស៊ូ គឺភូមិប្របុសរលួយ ភូមិបឹងកំពត ភូមិតាអឹម និងភូមិពោធិ៍ជ្រែក តំបន់ទី ៣ មានចំនួន៧ភូមិគឺ ភូមិម្រេញ ភូមិជែតា ភូមិពោធិរិយ៉ំ ភូមិរកាជួរ ភូមិរកាជួរទី២ ភូមិរកាជួរទី៣ និងភូមិងែកងក តំបន់ទី៤ ផ្លូវឆ្ពោះទៅប្រទេសវៀតណាម គឺភូមិប្រោះស្វា និងភូមិកគោ។ ដីលំនៅឋាន ភូមិ គឺជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធឯកជន) មានទំហំផ្ទៃដីសរុបចំនួន ១ ៦៥៩ ហិកតា ត្រូវបានចុះបញ្ជីកាន់កាប់ជាប្រព័ន្ធរួចរាល់ ១០០%។ បច្ចុប្បន្នដីនេះបានប្រើប្រាស់សម្រាប់ដីលំនៅឋានភូមិ ជាប្រភេទដីល្បាយខ្សាច់និងល្បាយខ្សាច់លាយដីខ្មៅ(អាចម៍កណ្តុរ) និងមានស្ថានភាពជាដីខ្ពស់រាបស្មើ។ ដីដែលបានកំណត់ជាដីភូមិនេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋាន ដែលបានមកពីអណ្តូងស្នប់ ប្រឡាយ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ។ នៅពេលអនាគតទីតាំងដីនេះនឹង ត្រូវរក្សាទុកជាដីលំនៅឋានភូមិដដែល ដោយសារទីតាំងនេះមានស្ថានភាពជាដី ខ្ពស់មិនលិចទឹកនៅរដូវវស្សា ហើយស្ថិតនៅជាប់តាមដងផ្លូវងាយស្រួលសចេញចូលទៅតំបន់ក្រៅឃុំ សមស្របទៅនឹងការសាងសង់លំនៅឋាន កាដាំដុះដំណាំរួមផ្សំ និងឈើហូបផ្លែ ដែលបានជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយផាសុកភាព។

រូបភាពទី១១÷ដីលំនៅឋាន ភូមិ





ទិដ្ឋភាពដីលំនៅឋាន ភូមិ

**ខ. ដីកសិកម្ម**

- **ដីស្រែវស្សា**

នៅក្នុងឃុំបន្ទាយចក្រី ដីស្រែមានវិសាលភាពគ្របដណ្តប់ស្ទើរតែពេញដែនដីរបស់ឃុំ លើកលែងតែដី តិចតួចប្រើប្រាស់ជាដីលំនៅឋានភូមិ ដីលំនៅឋានទីប្រជុំជន និងហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះ ហើយ

បច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការធ្វើកសិកម្មដំណាំស្រូវ មិនទាន់អស់សក្តានុពលនៅ ឡើយគឺធ្វើបានតែនៅរដូវវស្សាដែលពឹងផ្អែកទៅលើទឹកភ្លៀងប៉ុណ្ណោះ។ ដីស្រែវស្សាគឺជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធឯកជន) មានទំហំផ្ទៃដីចំនួន ៦ ៥៧៣ ហិកតា ជាប្រភេទដីល្បាយខ្សាច់លាយដីខ្មៅត្រូវបានចុះបញ្ជីកាន់កាប់ជាប្រព័ន្ធរួចរាល់ ១០០%។

រូបភាពទី១២÷ដីស្រែវស្សា

|  |  |  |
|---|---|---|
| វាលស្រែរដូវច្រូតកាត់ | វាលស្រែរដូវដកស្ទូង | វាលស្រែក្រោយច្រូតកាត់ |

### គ. ផ្ទៃទឹក

- **ទន្លេ**

ឃុំបន្ទាយចក្រី មានទន្លេធម្មជាតិមួយឈ្មោះសីហា ដែលមានទំហំ ៣៩ ហិកតា ជាដីសាធារណៈរបស់រដ្ឋស្ថិតនៅភូមិប្រោះស្វា និងភូមិកគោ។ បច្ចុប្បន្នមានទឹកនៅរដូវវស្សា បានផ្តល់ទឹកសម្រាប់ការស្រោចស្រពនៅពេលមានភាពរាំងស្ងួតនៅរដូវវស្សា និងផ្តល់ធនធានជល ផលសម្រាប់ការនេសាទតិចតួចជាលក្ខណៈគ្រួសារផ្គត់ផ្គង់ជាម្ហូប និងអាចលក់បានខ្លះ ចំណែកនៅរដូវប្រាំង បានរីងនៅសល់តែទឹកតាមថ្លុកតិចតួចប៉ុណ្ណោះ។

រូបភាពទី១៣÷ ទន្លេ

| |
|---|
|  |
| ទន្លេសីហា |

ពាក់ព័ន្ធបញ្ហាផ្សេងៗក្នុងការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី តាមរយៈការសម្ភាសន៍លោកមេឃុំ បានឱ្យដឹងថា មានប្រជាពលរដ្ឋក្នុងឃុំចំនួន ៣៦ គ្រួសារមិនមានដីសម្រាប់សាងសង់លំនៅឋាន និងធ្វើបរកសិកម្មឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋទាំង ៣៦ គ្រួសារនេះ មាន ២៤ គ្រួសាររស់នៅលើដីចិញ្ចើមផ្លូវ និង ០៤ គ្រួសាររស់នៅលើដីកម្មសិទ្ធរបស់គេផ្សេង ព្រមទាំងមានចំនួន ០៨ គ្រួសាររស់នៅជាមួយឪពុកម្តាយ។ ចំណែកបញ្ហាទំនាស់ក្នុងការការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី វិញពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ដោយសារដីក្នុងឃុំទាំងមូលត្រូវបានចុះបញ្ជីកាន់ កាប់ដីរួចរាល់១០០%។

### ១.៣.២.ផលិតកម្មកសិកម្ម

#### ក. ផលិតកម្មដំណាំស្បៀង

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន បានឱ្យដឹងថាបច្ចុប្បន្ននៅក្នុងឃុំបន្ទាយចក្រី មានដំណាំស្រូវជាដំណាំសំខាន់ទី ១ មានដំណាំឈើហូបផ្លែជាដំណាំសំខាន់ទី២ និងបន្លែជាដំណាំសំខាន់ទី៣។ ដំណាំស្រូវត្រូវបានផលិតនៅលើដីស្រែវស្សា និងដីស្រែលាយដីភូមិ ដែលមានទំហំសរុប ៦ ៥៧៣ ហិកតា ជាប្រភេទដីល្បាយខ្សាច់និងដីខ្មៅ នៅក្នុងតំបន់ទី ១ ជាទូទៅរកឃើញ ថាជាប្រភេទដីលំនៅឋាន ដំណាំចម្រុះនិងចិញ្ចឹមសត្វ។ ប្រជាពលរដ្ឋភាគច្រើនធ្វើស្រែតែមួយដងនៅរដូវវស្សា និងមានធ្វើស្រែបង្កើនរដូវតិចតួច (ធ្វើ២ដងក្នុងមួយឆ្នាំ) ដែលពឹងផ្អែកទៅលើប្រភពទឹកភ្លៀង ៦០% និងប្រព័ន្ធប្រឡាយ ៤០%ដោយប្រើប្រាស់ពូជស្រូវអ៊ីអ៊ែរ ៥០៤ អ៊ីអ៊ែរ ៦៦ សែនពិដោរ សែនក្រអូប ផ្ការំដួល បន្លាផ្តៅ ក្រសាំងទាប និងពូជស្រូវម៉ុងម៉ាងតិចតួច ហើយទទួលបានទិន្នផលស្រូវគិតជាមធ្យម ៣ តោន/ហិកតា។ ដូចនេះបរិមាណផលស្រូវប្រចាំឆ្នាំ ២០១៧ របស់ឃុំបន្ទាយចក្រី ប្រហែល ១៩ ៧១៩ តោន ដែលក្នុងនោះមាន ប្រមាណ ១ ២២៥ គីឡូក្រាម សម្រាប់ប្រជាពលរដ្ឋមួយនាក់។ ប៉ុន្តែដោយសារឃុំពុំមាន ទិន្នន័យអំពីផលស្រូវដែលត្រូវបានលក់ចេញក្នុងឆ្នាំ ២០១៧ តែយើងបានដឹងតាមរយៈផែនការអភិវឌ្ឍន៍វិស័យកសិកម្មខេត្តព្រៃវែង ឱ្យដឹងថាប្រជាពលរដ្ឋមួយនាក់ត្រូវការអង្ករ ១៤៣ គីឡូក្រាមសម្រាប់ហូបគ្រប់គ្រាន់ក្នុងមួយឆ្នាំ ដែលក្នុងនោះបានឱ្យដឹងទៀតថាការប្រែក្លាយពីស្រូវទៅជាអង្ករមានទម្ងន់តែ ៦៤% នៃទម្ងន់ស្រូវប៉ុណ្ណោះ ដូចនេះក្នុងឆ្នាំ២០១៧ ឃុំបន្ទាយចក្រី ត្រូវការស្រូវទុកហូបចុកមានចំនួនប្រមាណ ១ ៨៨៧ តោន និងបើតាមការវិភាគសេដ្ឋកិច្ចដំណាំស្រូវនៃការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន បានឱ្យដឹងថាក្នុងដីស្រែមួយហិកតា ត្រូវការពូជស្រូវអ៊ីអ៊ែរ (៥០៤) ចំនួន ១ ៩៧២ គីឡូក្រាម ដូច្នេះដីស្រែក្នុងឃុំទាំងអស់ ត្រូវការពូជស្រូវចំនួនប្រមាណ ១ ១០៦ តោន។ តាមការគណនាខាងលើបានឱ្យយើងសន្និដ្ឋានបានថាឃុំ បន្ទាយចក្រី មានបរិមាណផលស្រូវប្រមាណ ១៥ ៨៤៦ តោន សម្រាប់ការលក់ចេញ ដែលក្នុងនោះបានឱ្យដឹងទៀតថាស្រូវអ៊ីអ៊ែរ(៥០៤) ក្នុងមួយគីឡូក្រាមមានតម្លៃជាមធ្យម ៨០០ រៀលដែលអាចរកឃើញថាឃុំបន្ទាយចក្រី

បានចំណូលពីការលក់ស្រូវក្នុងឆ្នាំ ២០១៧ មានប្រប្រហាក់ប្រហែល ១២ ៣៥៦ លានរៀល។ បច្ចុប្បន្នឃុំបន្ទាយចក្រី ពុំទាន់មានតម្រូវការសម្រាប់ការពង្រីកផ្ទៃដីស្រោចស្រពនៅឡើយទេ។

តារាងទី២១÷តារាងអធិប្បាយពីឧបសគ្គ និងឱកាសលើដំណាំស្រៀង

| ឱកាស | ឧបសគ្គ |
|---|---|
| - មានដីស្រែធំទូលាយ<br>- ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាពនាំទឹកពីប្រភពទឹកទន្លេ បឹង មកផ្គត់ផ្គង់ការស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុងមួយឆ្នាំបាន<br>- មានប្រព័ន្ធប្រឡាយស្រាប់<br>- មានកម្លាំងពលកម្មច្រើន<br>- មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម<br>- មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។ | - ដីខ្វះជីជាតិ<br>- ភាពរាំងស្ងួត<br>- សត្វល្អិតបំផ្លាញ និងជំងឺលើដំណាំស្រូវ<br>- ប្រើប្រាស់ពូជស្រូវតាមទម្លាប់<br>- ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ<br>- ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់)<br>- ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន |

រូបភាពទី១៤÷ ផលិតផលដំណាំស្រៀង



សកម្មភាពដឹកជញ្ជូនផលស្រូវវស្សាក្រោយច្រូតកាត់បោកបែនដោយគ្រឿងយន្ត

### ខ. ផលិតកម្មដំណាំរួមផ្សំ

ដំណាំរួមផ្សំនៅក្នុងឃុំបន្ទាយចក្រីបច្ចុប្បន្ន មិនមានសក្តានុពលខ្លាំងក្លានោះទេគឺ គ្រាន់តែមានដំណាំឈើហូបផ្លែ និងបន្លែបង្គាតិចតួចដែលត្រូវបានដាំជាលក្ខណៈគ្រួសារនៅលើដីជុំវិញ លំនៅឋានក្នុងដីភូមិសម្រាប់ការហូបចុកនិងលក់ខ្លះៗតែប៉ុណ្ណោះ។ ដំណាំរួមផ្សំទាំងនោះរួមមានឈើហូប ផ្លែ ដូង ចេក ត្នោត

និងបន្លែ ត្រកួន សណ្តែក ននោង ល្ពៅ ដំឡូង ជាដើម។ ដំណាំរួមផ្សំទាំងអស់នេះ ត្រូវបានស្រោចស្រព ដោយប្រើប្រាស់ប្រភពទឹកភ្លៀង និងអណ្តូងស្នប់ទឹកក្រោមដី។

តារាងទី២២÷អធិប្បាយពីឧបសគ្គ និងឱកាសលើដំណាំស្មៀង

| ឱកាស | ឧបសគ្គ |
|---|---|
| - មានដីនៅជុំវិញលំនៅឋាន<br>- មានប្រភពទឹកភ្លៀង ទឹកស្រះ និងទឹកក្រោមដី សម្រាប់ការ ស្រោចស្រព<br>- ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃដំណាំ រួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក ដោះស្រាយ ដល់ជីវភាពរស់នៅប្រចាំថ្ងៃ កាត់បន្ថយបានលើការចំណាយ។ | - មានដីតិចតួចនៅជុំវិញលំនៅឋាន<br>- ដីខ្វះជីជាតិ<br>- ខ្វះទឹកស្រោចស្រពនៅរដូវប្រាំង<br>- ការយល់ដឹងពីបច្ចេកទេសដាំដំណាំរបស់ប្រជាពលរដ្ឋនៅមានកម្រិត ។ |

រូបភាពទី១៥÷ដំណាំរួមផ្សំ



ដំណាំចម្រុះជុំវិញលំនៅឋាន ភូមិ

### គ. ផលិតកម្មដំណាំឧស្សាហកម្ម

ដំណាំឧស្សាហកម្ម គឺជាដំណាំកសិកម្មដែលទទួលបានផលិតផលជាវត្ថុធាតុដើមយកទៅបម្រើឱ្យឧស្សាកម្ម ដែលបច្ចុប្បន្ន នៅក្នុងឃុំបន្ទាយចក្រី ពុំមានដាំដំណាំប្រភេទនេះទេ ដោយសារស្ថានភាព ដីនៅក្នុងឃុំជាវាលទំនាបសមស្របជាមួយដំណាំស្រូវ មិនអំណោយផលដល់ការដាំដំណាំឧស្សាហកម្មឡើយ។

## ១.៣.៣ ធនធានធម្មជាតិ

### ក. ធនធានព្រៃឈើ

បច្ចុប្បន្ននេះ នៅក្នុងឃុំបន្ទាយចក្រី ពុំមានដីព្រៃឈើនោះទេ តែបើតាមរបាយការណ៍ការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន បានឱ្យដឹងថា កាលពី ១០ ឆ្នាំមុន មានគ្រួសាររហូតដល់ ៩០% ប្រើប្រាស់ឧស សម្រាប់ដុតចំអិនអាហារ និងមានគ្រួសារខ្លះទៀតរុករកស្លឹកបាសសម្រាប់ហូបជាអាហារ។ ទន្ទឹមនេះ របាយការណ៍

បានឱ្យដឹងទៀតថា ក្រោយ ១០ឆ្នាំមកដល់ពេលនេះ ចំនួនគ្រួសារទៅរុករកអនុផលព្រៃឈើ មានការថយចុះ ដោយសារការកៀរផ្ទៃដីស្រែត្រូវរំលាយដំបូកក្នុងស្រែ។

តារាងទី២៣÷អធិប្បាយពីឧបសគ្គ និងឱកាសធនធានព្រៃឈើ

| ឱកាស | ឧបសគ្គ |
|---|---|
| - មានច្បាប់ស្តីពីព្រៃឈើដែលបានកំណត់ករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមដាំដើមឈើ<br>- មានការលើកទឹកចិត្តពីរាជរដ្ឋាភិបាលដល់ការចូល រួមដាំដើមឈើរបស់ប្រជាពលរដ្ឋ<br>- មានការផ្តល់នូវជំនួយបច្ចេកទេសដាំដើមឈើពី រដ្ឋបាលព្រៃឈើ។<br>- មានដីតាមដងផ្លូវសាធារណៈប្រព័ន្ធប្រឡាយ សាលារៀន មណ្ឌលសុខភាព វត្តអារាម តាមភូមិ ដែលអាចដាំដើមឈើបាន ។ | - មានការកាប់ឈើសម្រាប់ធ្វើជាឧសដុត និងប្រើប្រាស់ផ្សេងៗ<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍ នៃដើមឈើនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើនៅមិនទាន់បានពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ |

### ខ. ធនធានជលផល

តាមរបាយការណ៍ការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន បានឱ្យដឹងថា នៅក្នុងឃុំបន្ទាយចក្រី កាលពី ១០ឆ្នាំមុន មានគ្រួសារខ្លះរុករកអនុផលជីវចម្រុះដូចជា ត្រកួន កំប្លោក ព្រលិត និងបន្លែធម្មជាតិផ្សេងទៀត ព្រមទាំងត្រីស្រែសម្រាប់ហូបជាអាហារ ហើយក្រោយ១០ឆ្នាំមកដល់ពេលនេះ ចំនួនគ្រួសារទៅរុករកអនុផលទាំងនេះមានការថយចុះ ជាពិសេសត្រីស្រែ ដោយសារការប្រើប្រាស់ថ្នាំពុលនិងជីគីមី កសិកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់។

តារាងទី២៤÷តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឱកាស | ឧបសគ្គ |
|---|---|
| - មានដីស្រែធំទូលាយអំណោយផលដល់ធនធានជលផល<br>- មានប្រព័ន្ធប្រឡាយអំណោយផលដល់ធនធានជលផល<br>- មានការគាំទ្រនិងផ្សព្វផ្សាយអំពីវារីវប្បកម្មពីក្រសួងកសិកម្មជូនដល់កសិករ។ | - មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្រប នាំឱ្យមានការ ថយចុះបរិមាណត្រីស្រែ<br>- ការនេសាទខុសច្បាប់។ |

### គ. ធនធានរ៉ែ

នៅក្នុងឃុំបន្ទាយចក្រី មិនមានទិន្នន័យពីជំនាញពាក់ព័ន្ធអំពីណះអំណាងពីវត្តមានធនធានរ៉ែនៅ ក្នុងឃុំ គួរឱ្យកត់សម្គាល់បាននោះទេ គឺជាក់ស្តែងឃើញមានតែវាលស្រែគ្របដណ្តប់ស្ទើរទូទាំងឃុំប៉ុណ្ណោះ។

## ១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១. ទីផ្សារ និងតម្លៃកសិផល អនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្នឃុំបន្ទាយចក្រី មានតែផលិតផលស្រូវមួយមុខគត់ ដែលអាចផលិតបាននាំយកទៅរក ទីផ្សារ សល់ពីការហូបចុក ហើយផលិតផលស្រូវ ដែលអាចនាំទៅរកទីផ្សារមានតែពីរប្រភេទប៉ុណ្ណោះ គឺស្រូវអ៊ីអ៊ែរ ៥០៤ (IR 504) និងស្រូវផ្ការំដួល។ បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ឃុំបន្ទាយចក្រី ឆ្នាំ២០១៧ បានឱ្យដឹងថាស្រូវប្រភេទ អ៊ីអ៊ែរ៥០៤ មានទីផ្សារនៅប្រទេស វៀតណាម ដែលប្រជាពលរដ្ឋតែងតែលក់តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំមានតម្លៃត្រឹម ៨០០ រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវផ្ការំដួលមានទីផ្សារនៅក្នុងប្រទេស និងទីផ្សារក្រៅប្រទេសរួមមាន ប្រទេសវៀតណាមនិងប្រទេសថៃ ដែលប្រជាពលរដ្ឋតែងតែលក់តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំដែរតែមានតម្លៃ ១ ០០០ រៀល ក្នុងមួយគីឡូក្រាម។

តារាងទី២៥÷ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃជារៀល | ទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | អ៊ីអ៊ែរ ៥០៤ | ១ គ.ក | ៨០០ | | វៀតណាម |
| ២ | ផ្ការំដួល | ១ គ.ក | ១០០០ | | វៀតណាមថៃ |

### ១.៤.២. ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំបន្ទាយចក្រី ឆ្នាំ ២០១៧ បានឱ្យដឹងថាបច្ចុប្បន្ន នៅក្នុងឃុំបន្ទាយចក្រី ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញគឺ ត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនមានរក្សាទុកដោយខ្លួនឯង និងមានការទិញចូលតិចតួចប្រមាណ ៣០% ប៉ុណ្ណោះ ហើយមានការរៀបចំដី រួមទាំងការថែទាំមានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្ត។ ផលស្រូវដែលបានត្រូវបានហាលសម្ងួតទុកពូជ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ៣៥% ចំណែកផលស្រូវ នៅសើមដែលនៅសល់ប្រមាណ ៦០% យកទៅលក់ឱ្យឈ្មួញ នៅតាមដងផ្លូវក្នុងឃុំបានតម្លៃ១ ០០០ រៀល ក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យឈ្មួញទី២ បានតម្លៃ ១ ១០០ រៀល ក្នុងមួយគីឡូក្រាម យកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស។ ចំពោះស្រូវអ៊ី

អែរ៥០៨រិញពូជត្រូវ ទិញចូលប្រមាណ ៤០% ហើយផលស្រូវ ដែលទទួលបានត្រូវបានហាលសម្ងួតទុកពូជ និងទុកផ្គត់ផ្គង់ការ ហូបចុកប្រមាណ ២០% ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ ៨០% យកទៅលក់ឱ្យឈ្មួញនៅ តាមដងផ្លូវក្នុងឃុំបានតម្លៃត្រឹមតែ ៨០០ រៀលក្នុងមួយគីឡូក្រាម ហើយមួយចំនួនទៀតឈ្មួញបន្តយកទៅលក់ដល់ព្រំដែនវៀតណាម និងមួយចំនួនបន្តលក់ឱ្យម៉ាស៊ីនកិនស្រូវបានតម្លៃ ៨៧០ រៀលមួយគីឡូក្រាម។

រូបភាពទី១៦÷ការដឹកជញ្ជូន

|  |  |
|---|---|
| កសិករដឹកស្រូវពីស្រែទៅលក់ឱ្យឈ្មួញ | ឈ្មួញទទួលទិញស្រូវនាំចេញទៅប្រទេសវៀតណាម |

### ១.៤.៣. ឱកាស និងឧបសគ្គនៃទីផ្សារ និងខ្សែសង្វាក់ផលិតផល

តារាងទី២៦÷ អធិប្បាយពីឧបសគ្គ និងឱកាស

| ឱកាស | ឧបសគ្គ |
|---|---|
| - មានឈ្មួញមកទិញដល់កន្លែង<br>- មានសេវាកម្មជួលគ្រឿងយន្តកសិកម្ម (ភ្ជួររាស់ ច្រូតកាត់)<br>- មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ | - កសិករទិញជីពីឯកជន<br>- កសិករលក់ស្រូវឱ្យឈ្មួញកណ្ដាល<br>- ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ<br>- ឈ្មួញកណ្ដាលយកជី ថ្នាំ និងប្រេងមកបណ្ដាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់២% ក្នុងមួយខែហើយទូទាត់នៅពេលប្រមូលផល<br>- កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់<br>- ធាតុចូលកសិកម្មថ្លៃខ្ពស់ |

ដ្យាក្រាមទី៣÷ ខ្សែសង្វាក់តម្លៃ




ប្រភព÷ *របាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ឃុំបន្ទាយចក្រី ឆ្នាំ២០១៧*

ដ្យាក្រាមទី៤÷ ខ្សែសង្វាក់តម្លៃ




ប្រភព÷*របាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ- បរិស្ថាន ឃុំបន្ទាយចក្រី ឆ្នាំ២០១៧*

# ជំពូក ២÷ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គ សម្រាប់អនាគត

## ២.១. តម្រូវការសម្រាប់អនាគត

### ២.១.១.ផែនការអភិវឌ្ឍឃុំ

#### ក. ផែនការអភិវឌ្ឍឃុំ៥ឆ្នាំ (២០១៧-២០២២)

ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំយ៉ាងមានប្រសិទ្ធភាពតាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំមួយ មានរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍន៍ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់ បានការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឱ្យបានស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចឱ្យឃើញពីគោលបំណងអភិវឌ្ឍន៍ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាចង់បាន ព្រមទាំងគោលដៅអភិវឌ្ឍន៍ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បានតាមវិស័យនីមួយៗ។ ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលជាការកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍នីមួយៗខាងលើ។

ចំណែកឃុំបន្ទាយចក្រី ក្រុមប្រឹក្សាឃុំក្នុងអាណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំដូចមានខ្លឹមសារដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម÷

តារាងទី២៧÷ ការកំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវល្អសម្រាប់ធ្វើដំណើរ និងចរាចរទំនិញ | -ជួសជុលផ្លូវលំ និងក្រាលខ្សាច់ក្រួស<br>-កែលម្អផ្លូវលំជនបទ<br>-ស្ពាន ថែទាំ និងពង្រីកប្រព័ន្ធគមនាគមន៍ | -ជួលជុលផ្លូវលំដីស<br>-ជួសជុលផ្លូវក្រាលខ្សាច់ក្រួស<br>-ថែទាំផ្លូវ | |
| ២. ប្រព័ន្ធធារាសាស្ត្រ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧- | -ប្រជាពលរដ្ឋអាចមាន ប្រព័ន្ធធារាសាស្ត្រសម្រាប់ធនធានបរិមា | -ជួសជុលប្រឡាយទឹក<br>-សាងសង់ប្រព័ន្ធ | -ជីកប្រឡាយ<br>-ស្ពានប្រឡាយ | |

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើផែនទី |
|---|---|---|---|---|---|
| | ២០២២ | ណប្រភពទឹកគ្រប់គ្រាន់ | ធារាសាស្ត្របន្ថែម<br>-កែលម្អប្រព័ន្ធធារាសាស្ត្រ | ស្រោចស្រព<br>-ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ | |
| ៣.ផលិតផលដំណាំរួមផ្សំគ្រប់ប្រភេទ និងបច្ចេកទេសចិញ្ចឹមមាន់ ទា ត្រី | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -ប្រជាពលរដ្ឋទទួលបានចំណេះដឹងបន្ថែមពីការបណ្តុះបណ្តាលដំណាំនិងបន្លែគ្រប់មុខ ហើយបណ្តុះបណ្តាលចិញ្ចឹមជ្រូក ចិញ្ចឹមត្រី | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ ទា និងត្រី | -រៀនវគ្គខ្លីពីការដាំដំណាំបន្លែលក្ខណៈគ្រួសារ<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ<br>-បណ្តុះបណ្តាលបច្ចេកទេសមុន និងក្រោយប្រមូលផល | |
| ៤.ប្រជាពលរដ្ឋមុខរបរបន្ថែមដើម្បីឱ្យជីវភាពប្រសើរឡើង | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -លើកកម្ពស់ជីវភាពប្រជាពលរដ្ឋតាមរយៈការបង្កើនផលិតភាពកសិកម្ម និងពង្រីកមុខរបរ | -បង្កើនការយល់ដឹងដល់ពលរដ្ឋឱ្យទទួលបានបច្ចេកទេសកសិកម្មសមស្របដោយមានការគាំទ្រពីស្ថាប័ននានា | -បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ និងបន្លែ<br>-បណ្តុះបណ្តាលបច្ចេកទេសប្រើជីគីមី និងធ្វើជីធម្មជាតិ<br>-ផ្តល់ពូជស្រូវមានទិន្នផលខ្ពស់<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ<br>-ចាក់វ៉ាក់សាំងការពារជំងឺសត្វ<br>-ផ្តល់ពូជសត្វ<br>-រកការជួយគាំទ្រគ្រួសារក្រីក្រ<br>-ផ្តល់ឥណទានការប្រាក់ទាប<br>-បណ្តុះបណ្តាលវិជ្ជាជីវៈប្រកបមុខរបរ<br>-ផ្តល់ពូជកូនត្រី | |
| ៥.កុមារអាយុដល់វ័យសិក្សា និងយុវជនត្រូវបានចូលរៀនសូត្របញ្ចប់ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -ធ្វើយ៉ាងណាសម្រេចឱ្យបានការអប់រំជាមូលដ្ឋានរយៈពេល៩ឆ្នាំ | -ប្រមូលកុមារអាយុ ៣-៥ឆ្នាំ ឱ្យបានចូលរៀនថ្នាក់មត្តេយ្យ<br>-ប្រមូលកុមារដែលបោះបង់ការសិក្សាឱ្យបានចូលរៀនឡើងវិញអាយុ ៦-១១ឆ្នាំ | -សង់សាលាមត្តេយ្យសហគមន៍<br>-បណ្តុះបណ្តាលគ្រូមត្តេយ្យសហគមន៍<br>-ផ្តល់សំភារៈសិក្សា<br>-ឧបត្ថម្ភថវិកាដល់គ្រូមត្តេយ្យ<br>-ផ្សព្វផ្សាយពីប្រយោជន៍នៃការសិក្សាដល់ឪពុកម្តាយ<br>-រកការជួយគាំទ្រដល់សិស្សក្រីក្រ<br>-ផ្តល់អាហារូបត្ថម្ភដល់ | |

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើផែនទី |
|---|---|---|---|---|---|
| | | | | សិស្ស | |
| ៦.មណ្ឌលសុខភាព | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋតាមការផ្សព្វផ្សាយ ថែទាំ សុខភាព និង របៀបរស់នៅ ដោយសុខភាពល្អ | -លើកកម្ពស់សុខភាពប្រជាជនក្នុងឃុំ និងសុវត្ថិភាពមាតា ពេលមុន និងក្រោយប្រសូត្រ | -ផ្សព្វផ្សាយពីការថែទាំសុខភាពអនាម័យ<br>-ផ្សព្វផ្សាយជំរុញការពិនិត្យផ្ទៃពោះនៅមណ្ឌល<br>-ផ្តល់វ៉ាក់សាំងដល់ស្ត្រី និងកុមារ | |
| | | | -បង្កើនការប្រឆាំងជំងឺអេដស៍ និងជំងឺឆ្លងនានា ដោយមានការគាំទ្រពីស្ថាប័នជំនាញនានា | -សង់បង្គន់អនាម័យ<br>-ពង្រឹងបណ្តាញក្រុមទ្រទ្រង់សុខភាពភូមិ<br>-ផ្សព្វផ្សាយជំងឺឆ្លងរាតត្បាតផ្សេងៗ | |
| ៧.គ្រួសារមានចំណូលប្រសើរឡើង | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -បំណាច់ឆ្នាំ ២០១៧ ប្រជាពលរដ្ឋ ៣០%នៃគ្រួសារមិនមានមុខរបរមានចំណូលលើនឡើង។ | -បង្កើនចំណូលក្នុងគ្រួសារ | -បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំ<br>-ផ្តល់ពូជបន្លែ<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ<br>-ផ្តល់ពូជសត្វ<br>-បង្កើតក្រុមកែលម្អទុនបង្វិល | |
| ៨.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -ប្រជាពលរដ្ឋទទួលបានចំណេះដឹងពីការផ្សព្វផ្សាយច្បាប់ភូមិបាល<br>-ប្លង់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ | -បង្កើនចំណេះដឹងច្បាប់ភូមិបាល | -ផ្តល់បណ្ណកម្មសិទ្ធិដីធ្លី<br>-ផ្សព្វផ្សាយច្បាប់ភូមិបាល<br>-ជំរុញប្រជាពលរដ្ឋធ្វើរបង និងព្រំដីឱ្យបានច្បាស់លាស់ | |
| ៩. ប្រជាពលរដ្ឋមានសុខភាពល្អ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -បំណាច់អាណត្តិទី៣ ប្រជាពលរដ្ឋប្រមាណ ៩០% ក្នុងឃុំមានសុខភាពល្អ ពិសេសស្ត្រី និងកុមារ | -ជំរុញ និងបង្កើនការការពារ និងព្យាបាលសុខភាពប្រជាពលរដ្ឋ | -ផ្សព្វផ្សាយពីការថែទាំ និងអប់រំ<br>-ផ្តល់សេវាព្យាបាលដល់មូលដ្ឋាន<br>-ប្រជុំគណៈកម្មការមណ្ឌលសុខភាព<br>-ប្រជុំក្រុមទ្រទ្រង់សុខភាពភូមិទៀងទាត់<br>-ផ្តល់សំភារៈបរិក្ខារ និងដឹកជញ្ជូន<br>-ផ្សព្វផ្សាយអប់រំពេលស្ត្រីមានផ្ទៃពោះ<br>-ផ្សព្វផ្សាយពីសារៈសំខាន់នៃការឆ្លងទន្លេនៅមណ្ឌលសុខភាព | |

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្រ្តនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើផែនទី |
|---|---|---|---|---|---|
| | | | | -ផ្តល់និងទទួលវ៉ាក់សាំងការពារ<br>-ផ្តល់វ៉ាក់សាំង៨មុខដល់កុមារគ្រប់គ្រាន់<br>-ផ្សព្វផ្សាយពីកម្មវិធីពន្យាកំណើត | |
| ១០. ប្រជាពលរដ្ឋរស់នៅមានសុវត្ថិភាពពេលមានគ្រោះមហន្តរាយ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -ប្រជាពលរដ្ឋរស់នៅមានសុវត្ថិភាព មិនមានគ្រោះមហន្តរាយក្នុងចំណាច់ឆ្នាំ២០១៧ | -បង្កើនការការពារគ្រោះមហន្តរាយ | -បង្កើតគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ<br>-បង្កើតក្រុមសង្គ្រោះពេលមានគ្រោះមហន្តរាយ<br>-បណ្តុះបណ្តាលបច្ចេកទេសសង្គ្រោះ<br>-ផ្តល់សំភារៈសង្គ្រោះពេលមានមហន្តរាយ<br>-សាងសង់ទួលសុវត្ថិភាព | |
| ១១.កុមាររងគ្រោះដោយជំងឺអេដស៍ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -បំណាច់ឆ្នាំ២០១៧កុមាររងគ្រោះដោយជំងឺអេដស៍ត្រូវបានការពារគ្រប់គ្នា | -បង្កើនការការពារកុមារងាយរងគ្រោះដោយជំងឺអេដស៍ | -ផ្តល់ថ្នាំពន្យាជំងឺអេដស៍<br>-ផ្តល់ទុនសម្រាប់ប្រកបមុខរបរ<br>-ផ្តល់អាហារូបត្ថម្ភ<br>-ផ្សព្វផ្សាយទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ | |
| ១២. មានមច្ឆាជាតិនៅបន្តពូជ និងការរស់នៅមានបរិស្ថានល្អ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -នៅក្នុងមូលដ្ឋានឃុំទាំងមូលមានមច្ឆាជាតិនៅគង់វង្ស និងសំបូរទៅដោយបរិស្ថានល្អបំណាច់ឆ្នាំ២០១៧ | -ទប់ស្កាត់ ការពារមច្ឆាជាតិ និងកែលំអរបរិស្ថាន | -ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-ផ្សព្វផ្សាយការប្រើប្រាស់ជីគីមី-ថ្នាំពុលដល់បរិស្ថាន | |
| ១៣. យល់ពីច្បាប់នានាក្នុងមូលដ្ឋានឃុំកាន់តែប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ | -បំណាច់ឆ្នាំ២០១៧ចំណេះដឹង សមត្ថភាព ដឹកនាំគ្រប់គ្រង ការងាររដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈកាន់តែប្រសើរ | -បង្កើនសមត្ថភាពកិច្ចការរដ្ឋបាល និងការការពារសណ្តាប់ធ្នាប់សាធារណៈ | -បណ្តុះបណ្តាលកិច្ចការរដ្ឋបាល<br>-ផ្សព្វផ្សាយបច្បាប់ផ្សេងដល់មូលដ្ឋាន<br>-បណ្តុះបណ្តាលច្បាប់ព្រហ្មទណ្ឌ<br>-បណ្តុះបណ្តាលច្បាប់រដ្ឋប្បវេណី<br>-ផ្សព្វផ្សាយសេចក្តីណែនាំភូមិ ឃុំមានសុវត្ថិភាព<br>-រៀបចំវេទិការសាធារណៈ<br>-រៀបចំប្រជាការពារ | |
| ១៤. គ្រួសារក្នុងមូល | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ២០១៧- | -បំណាច់ឆ្នាំ២០១៧ ប្រជាពលរដ្ឋរស់នៅមានសុខ | -បង្កើនការយល់ដឹងពីសិទ្ធិ និងសមធមិយេនឌ័រ | -បណ្តុះបណ្តាលច្បាប់អំពីហឹង្សាក្នុងគ្រួសារ | |

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើផែនទី |
|---|---|---|---|---|---|
| ដ្ឋានឃុំរស់នៅមានសុភមង្គល | ២០២២ | ដុមរម្យនា ចេះគោរពសិទ្ធិគ្នា គ្មានអំពើហឹង្សានិងការរំលោភសេពសន្ថវៈពីជនខិលខូច | និងទប់ស្កាត់ការរំលោភសេពសន្ថវៈ | -ផ្សព្វផ្សាយច្បាប់អំពីហឹង្សាក្នុងគ្រួសារ<br>-បណ្តុះបណ្តាលច្បាប់សមធមិយេនដ៏រ<br>-ផ្សព្វផ្សាយច្បាប់ច្បាប់សមយេនដ៏រ<br>-បណ្តុះបណ្តាលច្បាប់កេងប្រវ័ញ្ចពលកម្មនិងការជួញ ដូរមនុស្ស<br>-ផ្សព្វផ្សាយច្បាប់ចំណាកស្រុកមានសុវត្ថិភាព<br>-បណ្តុះបណ្តាលច្បាប់ស្ត្រីក្នុងកិច្ចការសង្គម | |

## ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត

### ផែនទី៩÷គម្រោងវិនិយោគ ៥ឆ្នាំ



| | | | |
|---|---|---|---|
| ២០២២ | ៤ ៩៨៨ | ១៧ ៣១៧ | ៧ ៦៥៦ |
| ២០២៧ | ៤ ៥២៤ | ១៨ ៥៤២ | ៨ ៥៥៦ |
| ២០៣២ | ៤ ៨៣០ | ១៩ ៧៦៧ | ៩ ៤៥៦ |

តារាងទី២៩÷ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ

| ស្ថិតិតាមក្រុមអាយុ(ឆ្នាំ) | ឆ្នាំ ២០២២ (នាក់) | | ឆ្នាំ ២០២៧ (នាក់) | | ឆ្នាំ ២០៣២ (នាក់) | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| អាយុ០-២ | ១២៤៤ | ៦៧១ | ១៣០២ | ៧០៩ | ១៤៨២ | ៧៨៩ | |
| អាយុ៣-៤ | ៧៨៥ | ៤១៦ | ៨៤៦ | ៥០៦ | ៩៥០ | ៦៦២ | |
| អាយុ៥ | ៧២៩ | ២៩៤ | ៨៣៦ | ៥២០ | ៩៦៨ | ៦៤៩ | |
| អាយុ៦ | ៥០៨ | ២៤១ | ៦៨១ | ៣៥៤ | ៧៨២ | ៤០៧ | |
| អាយុ៧-១១ | ២០១៨ | ១២៨៤ | ២១៨១ | ១៣១៦ | ២២៦០ | ១៣៥៦ | |
| អាយុ១២-១៤ | ១៥៥១ | ៨៦១ | ១៦៨៤ | ៩៣១ | ១៧៥២ | ៩៦៦ | |
| អាយុ១៥-១៧ | ១៤៨២ | ៧៧៩ | ១៥០៤ | ៨២៤ | ១៦៥៤ | ៨៦៣ | |
| អាយុ១៨-២៤ | ៨៧៩ | ៣៥៨ | ៩៥៦ | ៣៩៤ | ១០៥២ | ៤៣៤ | |
| អាយុ២៥-៣៥ | ៦៨៣ | ២៤៤ | ៧៥៨ | ៣៨៤ | ៨២៥ | ៤១៧ | |
| អាយុ៣៦-៤៥ | ៣៧២១ | ២០១៥ | ៣៨៨២ | ២០៤៧ | ៣៩៥១ | ២០៨៣ | |
| អាយុ៤៦-៦០ | ១២៨៥ | ៦០២ | ១៣៦៨ | ៦៩៥ | ១៤៩៨ | ៦៦០ | |
| អាយុ៦១ឆ្នាំឡើង | ២៤៤២ | ៩៧៦ | ២៥៤៤ | ៦៣០ | ២៥៩៣ | ៥៨២ | |
| ចំនួនប្រជាពលរដ្ឋសរុប | ១៧៣១៧ | ៨៧៤១ | ១៨ ៥៤២ | ៩ ៣១០ | ១៩៧៦៧ | ៩៨៦៨ | |

## ២.១.៣.តម្រូវការដីធ្លីជាមូលដ្ឋាន

### ក. តម្រូវការដីលំនៅឋាន

ចំពោះដីភូមិសំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ។ នៅក្នុងឆ្នាំ ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ១ ៧០១ ហិកតា និងមានគ្រួសារ សរុបចំនួន ៣ ៩១១ គ្រួសារ គឺជាស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាពីការ ខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូចគឺស្មើចំនួន ៣៦ គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នមានចំនួន ២៤ គ្រួសារកំពុងរស់នៅលើដីចំណីប្រឡាយជាដីសាធារណៈ និងមានចំនួន ០៤ គ្រួសារកំពុងរស់នៅលើដីកម្មសិទ្ធរបស់អ្នកដ៏ទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុក

ដាក់ ដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ច មាននៅទីតាំងក្រៅឃុំតាមការសម្រេចរបស់គណៈ-កម្មាធិការសម្បទានដីសង្គមកិច្ច (នៅក្នុងឃុំបឹងដោលពុំមានដីឯកជនរបស់រដ្ឋ សម្រាប់គោលដៅសម្ប-ទានសង្គមកិច្ច) ព្រមទាំងមានចំនួន ០៨ គ្រួសារកំពុងរស់នៅជាមួយឪពុកម្ដាយ ដែលអាចរស់នៅស្នងបន្តពីឪពុកម្ដាយបាន។

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន÷

**១ ៧០១ ហិកតា / ៣ ៩១១គ្រួសារ = ០,៤៣ ហិកតា/ គ្រួសារ**

តែបើតាមអនុក្រឹត្យលេខ ១៩ ស្ដីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន ០,២៥ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ២៨ គ្រួសារដែលគ្មានដីពិតប្រាកដសម្រាប់លំនៅឋានដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំបន្ទាយចក្រីនេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់លំនៅឋានមួយចំនួនតាមការគណនាដូចខាងក្រោម÷

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ៣ ៦៧៥នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៤ នាក់/ គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន ០,៤៣ ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៣ ៦៧៥ នាក់ / ៤ នាក់/ គ្រួសារ = ៩១៩ គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ

**៩១៩ គ្រួសារ x ០,៤៣ ហិកតា/ គ្រួសារ = ៣៩៥ ហិកតា**

**-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំបន្ទាយចក្រីត្រូវកើនឡើងដល់ៈ**

**១ ៧០១ ហិកតា + ៣៩៥ ហិកតា = ២ ០៩៦ ហិកតា**

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ២៨ គ្រួសារតាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ

**២៨ គ្រួសារ x ០,៤៣ ហិកតា/ គ្រួសារ = ១២,០៤ ហិកតា**

តារាងទី៣០÷ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| **បរិយាយ** | **២០១៧ បច្ចុប្បន្ន** | **អនាគត ២០៣២** | **បម្រែបម្រួលតម្រូវការដី** |
|---|---|---|---|
| គ្រួសារ | ៣ ៩១១គ្រួសារ | ៤ ៧២១ គ្រួសារ | ៨១០ គ្រួសារ |
| តម្រូវការដីលំនៅឋាន | ១ ៧០១ ហិកតា | ២ ០៩៦ ហិកតា | ៣៩៥ ហិកតា |

## ខ. ដីកសិកម្ម

ចំពោះដីកសិកម្មសំដៅទៅលើដីសម្រាប់ធ្វើស្រែវស្សា និងដីចំការដំណាំតែសម្រាប់ឃុំបន្ទាយចក្រី នេះដីកសិកម្មគឺជាដីស្រែតែប៉ុណ្ណោះពីព្រោះនៅក្នុងឃុំបន្ទាយចក្រីពុំមានដីចំការឡើយ គឺមានតែដីប្រជាពលរដ្ឋដាំដំណាំរួមផ្សំតិចតួចនៅជុំវិញផ្ទះ ដែលបានចាត់ចូលជាដីភូមិរួចហើយ។ នៅក្នុងឆ្នាំ ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ **៦ ៥៧៣ហិកតា** និងមានគ្រួសារសរុបចំនួន **៣ ៩១១** គ្រួសារអាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះ សម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាព គឺជាស្ថានភាព ដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបានលើកលែងតែគ្រួសារមួយចំនួនតូចគឺ ស្មើចំនួន ២៨ គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារផ្ទាល់ខ្លួន ហើយកំពុងស៊ីឈ្នួលគេ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយជូនពួកគាត់តាមរយៈដីសម្បទាន ដីសង្គមកិច្ច ដែលមាននៅទីតាំងក្រៅឃុំ តាមការសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច (នៅក្នុងឃុំបន្ទាយចក្រី ពុំមានដីឯកជនរបស់រដ្ឋសម្រាប់គោលដៅសម្បទានសង្គមកិច្ច)។

**ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន÷**

**៦ ៥៧៣ ហិកតា / ៣ ៩១១គ្រួសារ = ១,៦៨ ហិកតា/ គ្រួសារ**

តែបើតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ ហិកតា ក្នុង ១ គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ២៨ គ្រួសារ ដែលគ្មានដីពិតប្រាកដ សម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំបន្ទាយចក្រីនេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម÷

**-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ៩១៩ គ្រួសារ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ**

**៩១៩ គ្រួសារ x ១,៦៨ ហិកតា/គ្រួសារ = ១ ៥៤៣ ហិកតា**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ**

**៦ ៥៧៣ ហិកតា + ១៥ ៤៣ហិកតា = ៨ ១១៦ ហិកតា**

-ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ២៨ គ្រួសារតាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ **២៨ គ្រួសារ x ២ ហិកតា/គ្រួសារ = ៥៦ ហិកតា**

តារាងទី៣១÷ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ៣ ៩១១ គ្រួសារ | ៤ ៧២១ គ្រួសារ | ៨១០ គ្រួសារ |
| តម្រូវការដីកសិកម្ម | ៦ ៥៧៣ ហិកតា | ៨ ១១៦ហិកតា | ១ ៥៤៣ ហិកតា |

### គ. ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល ឧស និងអនុផលនានា មានជ័រ វល្លិ៍ ឱសថ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទ តាមរយៈការប្រើប្រាស់ដោយផ្ទាល់ ឬតាមរយៈការលក់ដូរ។ ទន្ទឹមនេះ ព្រៃឈើក៏បានដើរតួយ៉ាងសំខាន់ក្នុងចំណោមតួនាទីដទៃទៀត ដូចជាទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះទឹកជំនន់ជួយការពារការហូរច្រោះដី និងបាក់ដី) ធ្វើឱ្យដីមានជីជាតិជាតំបន់ទេសចរធម្មជាតិ។ ចំណែកព្រៃលិចទឹកសាបជា ជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្រ្តចម្រុះ។

ចំពោះស្ថានភាពប្រើប្រាស់ដីនៅឃុំបន្ទាយចក្រី បច្ចុប្បន្នមិនមានដីព្រៃឈើនោះទេ។ តែទោះជាយ៉ាងណា ដោយយល់ឃើញពីសារៈសំខាន់នៃព្រៃឈើដែលមានផលប្រយោជន៍ផ្ទាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងឃុំមិនអាចខ្វះបាន ដូចបានរៀបរាប់ខាងលើ ដូចនេះក្រុមប្រឹក្សាឃុំ ជំនាញពាក់ព័ន្ធ និងប្រជាជនក្នុងឃុំគួរខិតខំយកចិត្តទុកដាក់ដល់ការដាំដើមឈើនៅតាមទីសាធារណៈដូចជាតាមដងផ្លូវប្រឡាយទឹក ទីទួលដែលទំនេរ សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាមជាដើម ។ល។ ដើម្បី ឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំ។

### ឃ. ធនធានទឹក

ឃុំបន្ទាយចក្រី ជាឃុំមានសក្តានុពលទៅលើផ្នែកកសិកម្មដំណាំស្រូវ ដែលនាំឱ្យឃុំមានគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់ខ្លួនផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវនេះ មិនអាចគេចចេញបានឡើយ។ ដូច្នេះដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើន គឺមានកត្តាទឹក ជាកត្តាសំខាន់ដែរដែលត្រូវយកចិត្តទុកដាក់ ដោយត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់ សម្រាប់ការស្រោចស្រព បានគ្រប់រដូវកាលទៅលើដីស្រែទាំងអស់ដែលឃុំមាន ដើម្បីដោះស្រាយទឹកពេល មានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវ ឱ្យទទួលបានផលិតភាពខ្ពស់ជួយផ្គត់ផ្គង់ដល់ការហូបចុក និងជំរុញការនាំចេញបង្កើន សេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការ ជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។ ដូច្នេះឃុំបន្ទាយចក្រី ដែលបច្ចុប្បន្នមានប្រព័ន្ធធារាសាស្រ្តស្រាប់គ្រប់គ្រាន់ ហើយនោះត្រូវធ្វើការស្តារ និងកែលម្អទៅលើប្រព័ន្ធធារាសាស្រ្តទាំងនោះឱ្យបាន

ប្រសើរឡើងវិញដើម្បី មានលទ្ធភាពប្រើប្រាស់ក្នុងការបង្ហូរនាំទឹកស្រោចស្រពគ្របដណ្តប់ទៅលើផ្ទៃដីស្រែក្នុងឃុំទាំងមូលបានតាមតម្រូវការ ដោយធ្វើស្រែឱ្យបានច្រើនដង (២ទៅ៣ដង) ក្នុងមួយឆ្នាំ។ ដោយឡែកទំនប់ អាងស្តុកទឹកស្តុកទុក ស្ថានភាពដីក្នុងឃុំបន្ទាយចក្រីពុំមានទីតាំងណាសមស្របដល់ការរៀបចំ បានឡើយ ដែលចាំបាច់ត្រូវស្វែងរកប្រភពទឹកពីកន្លែងផ្សេង ជាពិសេសប្រភពទឹកពីទន្លេ បឹង ដើម្បីនាំយកមកស្រោចស្រពក្នុងឃុំបានតាមរយៈប្រឡាយមេ ដែលបច្ចុប្បន្ននៅក្នុងឃុំបីខែរួចហើយ គឺប្រឡាយអូរស្វាត ប្រឡាយអន្លង់ចារ និងប្រឡាយទួលធាតុ។

ចំណែកការនេសាទ និងវារីវប្បកម្ម នៅក្នុងឃុំបច្ចុប្បន្នមានការនេសាទជាលក្ខណៈគ្រួសារតិចតួចនៅតាមប្រឡាយទឹក និងក្នុងស្រែនារដូវវស្សាតែប៉ុណ្ណោះ។ តែសម្រាប់ថ្ងៃអនាគត ប្រជាពលរដ្ឋក្នុងឃុំគួរយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រី ដែលផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋក្នុងឃុំគួរទទួលបាននូវអាហារ សម្រាប់ទ្រទ្រង់សុខភាព និងជីវិតរស់នៅបែបនេះ។ នៅក្នុងឃុំបន្ទាយចក្រី ស្ថានភាពសមស្របគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋាន ចិញ្ចឹមត្រីក្នុងស្រែ ដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែ ដែលបំផ្លាញផលស្រូវផងដែរ។

## ង. ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

### ង.១. វិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ យ៉ាងណាមិញនៅក្នុងឃុំបន្ទាយចក្រីទៅថ្ងៃអនាគត ក្នុងរយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនាក្នុងចំណុច២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែម គ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

- **មត្តេយ្យសិក្សា:**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី ៣-៥ ឆ្នាំ នឹងកើនឡើងចំនួនៈ ១ ៩១៨ នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ **៥០ នាក់**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ**

**១ ៩១៨ នាក់/៥០ នាក់/បន្ទប់= ៣៨ បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៣៨ បន្ទប់ / ៥ បន្ទប់/អគារ =៨ អគារ**

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ៣ ០៤២នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ**

**៣ ០៤២ នាក់ ÷ ៥០នាក់/បន្ទប់ = ៦០ បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៦០ បន្ទប់ ÷ ៥ បន្ទប់/អគារ = ១២ អគារ**

-តែក្នុងករណីត្រូវរៀន**២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ**

**១២ អគារ/វេន ÷ ២ វេន = ៦ អគារ**

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៧៥២នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១ ៧៥២ នាក់ ÷ ៥០ នាក់/បន្ទប់ = ៣៥បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៣៥ បន្ទប់ ÷ ៥ បន្ទប់/អគារ = ៧ អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**៧ អគារ / វេន ÷ ២ វេន = ៣ អគារ**

តារាងទី៣២÷ បម្រែបម្រួលវិស័យអប់រំក្នុងឆ្នាំ២០៣២

| **បរិយាយ** | **បច្ចុប្បន្ន២០១៧** | **អនាគត ២០៣២** | **បម្រែបម្រួល** |
|---|---|---|---|
| សាលាមត្តេយ្យ | | | |
| សិស្ស | ២៤៣ នាក់ | ១ ៩១៨ នាក់ | ១ ៦៧៥ នាក់ |
| បន្ទប់ | ០៨ បន្ទប់ | ៣៨ បន្ទប់ | ៣០ បន្ទប់ |
| អគារ | ០៨ អគារ | ០៨ អគារ | ០០ អគារ |
| សាលាបឋមសិក្សា | | | |
| សិស្ស | ៣ ០១០ នាក់ | ៣០៤២ នាក់ | ៣២ នាក់ |
| បន្ទប់ | ៦០ បន្ទប់ | ៦០ បន្ទប់ | ០ បន្ទប់ |

| | | | |
|---|---|---|---|
| អគារ | ០៩ អគារ | ៦ អគារ | ០ អគារ |
| អនុវិទ្យាល័យ | | | |
| សិស្ស | ៤៦៩ នាក់ | ១ ៧៥២ នាក់ | ១ ២៨៣ នាក់ |
| បន្ទប់ | ១១ បន្ទប់ | ៣៥ បន្ទប់ | ២៤ បន្ទប់ |
| អគារ | ០១ អគារ | ០៣ អគារ | ០២ អគារ |

### ង.២. វិស័យសុខាភិបាល

តាមការស្រាវជ្រាវរកឃើញដែលបានរៀបរាប់ក្នុងជំពូកទី ១ នៃរបាយការណ៍នេះបានឱ្យដឹងថានៅក្នុងឃុំបន្ទាយចក្រី មានមណ្ឌលសុខភាពមួយកន្លែង ដែលមានលទ្ធភាពផ្តល់សេវាកម្មក្នុងការព្យាបាលជូនប្រជាពលរដ្ឋក្នុងឃុំសមស្របតាមគោលការណ៍របស់វិស័យសុខាភិបាល ហើយទៅថ្ងៃអនាគត១៥ ឆ្នាំទៅ មុខនឹងមិនមានផែនការបង្កើនបន្ថែមមណ្ឌលសុខភាពនោះទេ ដោយគ្រាន់តែជំរុញការផ្តល់សេវាកម្មពីមណ្ឌលសុខភាពមួយនេះជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំឱ្យបានប្រសើរឡើងតែប៉ុណ្ណោះ ហើយក៏នឹងអាចផ្តល់លទ្ធភាពឱ្យមានគ្លីនិចឯកជនបំពេញបន្ថែមទៀតផងដែរ។

### ង.៣. អគ្គិសនី

អគ្គិសនីមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសំបូររុងរឿង ដូចជាជួយដោះស្រាយបញ្ហានិងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខសុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងការកម្សាន្តផងដែរ។

ចំពោះស្ថានភាពការប្រើប្រាស់អគ្គិសនីនៅក្នុងឃុំបន្ទាយចក្រីបច្ចុប្បន្ន មានគ្រួសារប្រជាពលរដ្ឋប្រមាណ ១៩,២០% ប៉ុណ្ណោះដែលបានតភ្ជាប់បណ្តាញអគ្គិសនីរដ្ឋប្រើប្រាស់ នៅសល់គ្រួសារប្រមាណតែ ៨០,៨% ដែលមិនទាន់បានទទួលសេវាកម្មនេះនៅឡើយ។ ដូច្នេះនៅពេលអនាគត ១៥ ឆ្នាំទៅមុខ នឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំបន្ទាយចក្រីត្រូវខិតខំយកចិត្តទុកដាក់ ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនីតភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារ បានប្រើប្រាស់ ។

### ង.៤. ទីលានចាក់សំរាម

សំរាម គឺជារបស់អ្វីដែលធ្លាក់ក្បែរខ្លួនមនុស្ស ឬធ្លាក់ទៅកន្លែងផ្សេង។ ដូច្នេះសំរាមគឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងជាការបង្កើតកន្លែងគរមួយផ្សេងទៀតប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ មានគំនរសំរាម នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាង ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជា

ទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ ដែលនៅពេលនោះ មានលេចឡើងនូវជំងឺរាគត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត។

ចំពោះសំរាមនៅក្នុងឃុំបន្ទាយចក្រី បច្ចុប្បន្នប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរ ផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោលដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ-ឃុំ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកទីតាំងនៅក្នុងឃុំដែលនៅ ដាច់ដោយឡែកឆ្ងាយពីភូមិ ធ្វើទីលានចាក់សំរាមមួយកន្លែង ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទិកយកទៅកែច្នៃផលិតឡើងវិញ ចំណែកសំរាមពីផ្ទះបាយនិងស្លឹកឈើផ្សេងពី ប្លាស្ទិកអាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់ក្នុងការបង្កើនគុណភាពដីដាំដុះ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទិកឱ្យអស់ពីភូមិ ឃុំ។

### ង.៥. ដីកប់ខ្មោច

ជាទូទៅពិធីបូជាសពមានពីបែបគឺពិធីដុតសព និងកប់សពរក្សាក្នុងដី ដែលពិធីទាំងពីរនេះពិធីកប់សពត្រូវការប្រើប្រាស់ដីដែលធ្វើឱ្យមានការបាត់បង់ដីសម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍន៍ក្នុងសហគមន៍ដែលមនុស្សរស់នៅ។ នៅក្នុងឃុំបន្ទាយចក្រី បច្ចុប្បន្នក៏មានប្រើពិធីទាំងពីរនេះដែរ ហើយការប្រើប្រាស់ដីនៅក្នុងឃុំបនេះក៏មានតម្រូវការកាន់តែច្រើនឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋទៅអនាគត ដែលចាំបាច់ អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំ ត្រូវខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធី បូជាសពនេះដែល នឹងកើតឡើងជាបន្តបន្ទាប់ ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសពដោយកប់ក្នុងដី ហើយជំនួសមកវិញដោយ ការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិដែលជាជម្រើសល្អ បំផុត។

### ង.៦. ស្រះ និងអណ្តូងទឹក

ទឹកគឺជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាព ដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត។ នៅក្នុងឃុំបន្ទាយចក្រី បច្ចុប្បន្នមានការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូងដូចបានរៀបរាប់ក្នុងជំពូក ទី១ នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថាចំនួនស្រះទឹកនិងអណ្តូងទាំងអស់នេះមិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋក្នុងរយៈពេល ១៥ ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំបន្ទាយចក្រី ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សារក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗ

ខ្លួន សម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំងដែលខ្សត់ទឹកហើយថែមពីលើ នេះទៀតក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះ ប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត។

## ២.៣. ការប្រឈម

### ២.៣.១.ការប្រឈមដោយធម្មជាតិ

### ក. កំណើនប្រជាជន

បច្ចុប្បន្ននៅក្នុងឃុំបន្ទាយចក្រី បានរកឃើញថាមានការកើនឡើងចំនួនប្រជាជនជាមធ្យមប្រចាំ ឆ្នាំ ១,៥២៥%។ដូច្នេះទៅថ្ងៃអនាគតបើផ្អែកទៅកំណើន ដែលបានរកឃើញនេះប្រជាពលរដ្ឋក្នុងឃុំបន្ទាយចក្រីនឹងមានការកើនឡើងបន្ថែមទៀត ដែលនឹងនាំឱ្យមានបញ្ហាប្រឈមមួយចំនួនដូចជា÷

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកដោះស្រាយ ដោយនៅក្នុងឃុំពុំមានដីសល់ទំនេរសម្រាប់ បំពេញការខ្វះខាតនេះ

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយគ្រូពេទ្យ ឧបករណ៍និងសម្ភារៈពេទ្យ និងថ្នាំពេទ្យបន្ថែម

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយផ្គត់ផ្គង់បន្ថែម

### ខ. គ្រោះធម្មជាតិ ការវិចវិលនៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងឃុំបន្ទាយចក្រី បានរកឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិកើតឡើង ដូចជាគ្រោះរាំងស្ងួតហើយដីធ្លីដែលជាធនធានធម្មជាតិកម្រក៏មានភាពវិចវិលទៅៗ ដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិ ដោយសារការប្រើប្រាស់ជីគីមីនិងថ្នាំសម្លាប់សត្វល្អិតលើដំណាំស្រូវ ដែលទាំងនេះជាការប្រើប្រាស់ដីខុសទំនងមិនសមស្របទៅនឹងបច្ចេកទេសកសិកម្ម។ ទន្ទឹមនេះមានការថយចុះនិងបាត់បង់ធនធានមច្ឆាជាតិ ដោយការប្រើប្រាស់ឧបករណ៍ឆក់ដែលជាការនេសាទខុសច្បាប់ ដែលទៅថ្ងៃអនាគតនៅតែជួប ប្រទះនូវបញ្ហាប្រឈមនេះដដែល បើមិនមានដំណោះស្រាយទប់ទល់នឹងគ្រោះរាំងស្ងួត និងមានការកែ ប្រែឥរិយាបថក្នុងការប្រើប្រាស់ដីធ្លី សម្រាប់កសិកម្មឱ្យបានសមស្របទេនោះ។

### ២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍន៍នានា ពាក់ព័ន្ធការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយតែងនាំមកការរីកចម្រើនជានិច្ចតែផ្ទុយទៅវិញបើគម្រោងអភិវឌ្ឍន៍ទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធានដែលមាន វានឹងនាំមកនូវផលប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននូវពេលអនាគត ដោយមិនអាចធានាចិរភាពនៃគម្រោងទាំងនោះដល់កូនចៅជំនាន់ក្រោយក្នុងតំបន់នោះបានឡើយ ដូចជាស្ថានភាពនៅក្នុងឃុំបន្ទាយចក្រី ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចបានរៀបរាប់ក្នុងជំពូកទី១នៃរបាយការណ៍នេះបានឱ្យដឹងថាឃុំបន្ទាយចក្រីមានស្ថានភាពភូមិសាស្ត្រជាវាលទំនាបមានធនធានដីអំណោយផលដល់ដំណាំស្រូវ ដែលជាសក្តានុពលដល់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ។ ដូចនេះឃុំបន្ទាយចក្រីគួរជៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍទាំងឡាយណាដែលនាំឱ្យមានផល ប៉ះពាល់ដល់ការបាត់បង់ដីស្រែដែលខ្លួនមាន ធ្វើឱ្យឃុំមានការថយចុះឱកាសអភិវឌ្ឍន៍ ដូចជាគម្រោងចាក់ លុបដីស្រែបង្កកទុកលក់ ឬពុះដីឡូតិ៍លក់ដើម្បីកេងផលចំណេញពីឈ្មួញគម្រោងជីកយកអាចម៍ដី យកលក់ជាដើមលើកលែងតែគម្រោងណាដែលពាក់ព័ន្ធ ដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្មដូចជា កសិដ្ឋានផលិតពូជស្រូវស្រែគម្រូផលិតជីទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនឹងនេះក៏នៅមានគម្រោងអភិវឌ្ឍន៍ដល់ការរស់នៅនិងបរិស្ថាន ដែលគួរជៀសវាងផងដែរដូចជាគម្រោងបង្កើត សិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់។ ទន្ទឹមនឹងការប្រឈមដោយការអភិវឌ្ឍខាងលើដែលត្រូវជៀសវាងក៏នៅមានការប្រឈមទៅ និងអំពើអនាធិបតេយ្យដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ ប្រជាពលរដ្ឋក្នុងឃុំផងដែរ ដូចជាការស្នាក់លើដីនៅតាមមាត់ប្រឡាយ តាមចិញ្ចើម ផ្លូវសាធារណៈ ការទន្ទ្រានដីទួលសាធារណៈ ធ្វើស្រែបំពានលើប្រឡាយ ការនេសាទ ខុសច្បាប់ជាដើម។

## ២.៤. ឱកាស

### ២.៤.១.អំណោយផលពីធម្មជាតិ

នៅក្នុងលោកយើងនេះ ធម្មជាតិបានផ្តល់នូវធនធានដ៏មានសារសំខាន់សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាងដែលមនុស្សចង់ធ្វើ ដូចជាមនុស្សប្រើដីនឹងទឹកសម្រាប់ការដាំដំណាំឈើធ្វើអុសដុតសម្រាប់ផ្តល់កំដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែង។ល។ សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ចំណែកនៅក្នុងឃុំបន្ទាយចក្រី យើងផ្តោតសំខាន់ ទៅធនធានដីដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍន៍ឃុំដូចបានរកឃើញ និងរៀបរាប់នៅក្នុង ជំពូកទី ១ នៃរបាយការណ៍នេះដូចខាងក្រោម÷

- ស្ថានភាពដីជាវាលទំនាប អំណោយផលដល់ការដាំដុះដំណាំស្រូវ

- នៅមិនឆ្ងាយប៉ុន្មានពីប្រភពទឹក អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវបាន
- អាកាសធាតុ ក្តៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ

### ២.៤.២. បច្ចេកវិទ្យាថ្មី

ជីវិតរស់នៅដែលយើងកំពុងទទួលបានប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍន៍ ផ្នែកបច្ចេកវិទ្យា។ បច្ចេកវិទ្យាថ្មីធ្វើឱ្យមានការផ្លាស់ប្តូរបានប្រសើរឡើងនៃជីវិតរស់នៅរបស់យើង ដែលអ្វីៗបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា។

បច្ចុប្បន្នឃុំបន្ទាយចក្រី ដែលមានសក្តានុពលខ្លាំងពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ ហើយនាពេលអនាគត ក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំស្រូវដដែលដែរនោះ នឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ ដើម្បីជួយជំរុញឱ្យមានការកើនឡើងផលិតផលស្រូវ ដោះស្រាយបាននូវសន្តិសុខស្បៀង និងប្រាក់ចំណូលកាន់តែខ្ពស់នាំឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ក្នុងពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់។ តាមរយៈបច្ចេកវិទ្យាថ្មីនឹងនាំឱ្យប្រជាពលរដ្ឋ មានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់ សម័យសម្រាប់ការផលិតដំណាំស្រូវ ដែលរួមមានដូចជា÷ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ដ្រូនបាញ់ថ្នាំសម្លាប់ សត្វល្អិតនិងដាក់ជី ម៉ាស៊ីនច្រូតកាត់និងបោកបែនព្រមទាំងដឹកជញ្ជូនជាដើម។ល។

### ២.៤.៣. គម្រោងវិនិយោគ

នាពេលអនាគត ឃុំបន្ទាយចក្រី ដែលមានសក្តានុពលទៅលើដំណាំស្រូវ នឹងនាំឱ្យមានគម្រោងវិនិយោគ ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ ដូចជាគម្រោងបង្កើតកសិដ្ឋានកសិកម្ម ដើម្បីជំរុញផលិតកម្ម ដំណាំស្រូវគម្រោងវិនិយោគទៅលើការកែច្នៃផលិតផលស្រូវ ដើម្បីនាំចេញដែលនឹងផ្តល់ការងារបន្ថែមដល់ ប្រជាពលរដ្ឋបង្កើនប្រាក់ចំណូលបានកាន់តែខ្ពស់ នាំឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង កាត់បន្ថយបាន នូវភាពក្រីក្រស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

## ២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកតាមការរកឃើញនៅក្នុងជំពូកទី ១ នៃរបាយការណ៍នេះអាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហាដែលកើតមាននៅក្នុងឃុំបន្ទាយចក្រី មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយបញ្ហា

ទាំងអស់នេះដោយមានបង្ហាញអំពីទីតាំងដែលកើតមានបញ្ហានៅក្នុងតារាង ព្រមទាំងកំណត់បាននូវទីតាំងបញ្ហានៅក្នុងផែនទីទៀតផងដែរ ដូចមាននៅខាងក្រោមនេះ÷

# ផែនទីបញ្ហា មូលហេតុ ដំណោះស្រាយ ឃុំបន្ទាយចក្រី




**ប្រព័ន្ធកូអរដោនេ:**

ចំណោលផែនទី: UTM

តំបន់ទី: 48N

ទិន្នន័យយោង: WGS 1984

អេលីបសូអ៊ីត: WGS 1984

**ប្រភពទិន្នន័យ:**

- ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាល ប្រភពពីនាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(២០១៩)
- ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត។

**បញ្ជាក់:**

- ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងនៅថ្នាក់ជាតិ និងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
- ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
- ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................... ឆ្នាំ ២០.....


គាំទ្រដោយ: ADB GAFSP

អនុវត្តដោយ:

## តារាងទី៣៣÷បញ្ហាប្រឈម និងសក្តានុពល (ផ្នែកលើការវិភាគ បញ្ហា/ មូលហេតុ/ ដំណោះស្រាយ)

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១-ទិន្នផលស្រូវទាប  | ដីស្រែ | ក-ដីថយចុះជីជាតិ | ក-១-បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ |
| | | ខ-ខ្វះបច្ចេកទេសប្រើប្រាស់ជី | ខ-១-ផ្តល់ពូជស្រូវទិន្នផលខ្ពស់ |
| | | គ-ប្រើប្រាស់ជីគីមីលើកម្រិត | គ-១-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជី |
| | | ឃ-រាំងស្ងួត | ឃ-១-រកទីតាំងធ្វើអាងស្តុកទឹក |
| ២-ខ្វះទឹកស្រោចស្រព  | ដីប្រឡាយ | ក-បឹងរាក់ | ក-១-ជីក ឬស្តារបឹង |
| | | ខ-អូររាក់ | ខ-១-ស្តារអូរ |
| | | គ-ខ្វះប្រព័ន្ធស្រោចស្រព | គ- ១-សាងសង់ទ្វារទឹក<br>គ-២- រៀបចំគណកម្មការប្រើប្រាស់ទឹក |
| ៣-ផ្លូវរងការខូចខាតពិបាកធ្វើដំណើរ  | -លំនៅឋានទីប្រជុំជន<br>-លំនៅឋានភូមិ-វាល ស្រែ | ក-ទឹកជំនន់ជន់ដាច់ | ក-១-សង់ទំនប់ |
| | | ខ-ឡានដឹកធូន់លើលទម្ងន់ | ខ-១-ដាក់ប៉ារ៉ាស |
| ៤-សត្វមានជំងឺ | ក្នុងឃុំ | ក- ខ្វះបច្ចេកទេសចិញ្ចឹម | ក-១- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ |
| | | ខ- ខ្វះថ្នាំការពារនិងព្យាបាល | ខ-១- ផ្តល់ថ្នាំការពារ និងព្យាបាល<br>ខ-២-ផ្តល់ពូជសត្វ |
| ៥- កុមារអាយុ៣-៥ឆ្នាំ មិនបានចូលរៀន | ក្នុងឃុំ | ក- គ្មានថ្នាក់មត្តេយ្យ | ក-១- សាងសង់សាលាមត្តេយ្យសហគមន៍<br>ក-២- បណ្តុះបណ្តាលគ្រូមត្តេយ្យសហគមន៍<br>ក-៣- ផ្តល់សំភារៈសិក្សា<br>ក-៤- ឧបត្ថម្ភថវិការដល់គ្រូមត្តេយ្យសហគមន៍ |
| ៦- កុមារអាយុ៦-១១ឆ្នាំមិនចូលរៀន | ក្នុងឃុំ | ក- ជីវភាពគ្រួសារក្រីក្រ | ក-១- ផ្សព្វផ្សាយពីសារប្រយោជន៍នៃការសិក្សា<br>ក-២- រកដៃគូជួយគាំទ្រសិស្សក្រីក្រ<br>ក-៣- ផ្តល់អាហាររូបត្ថម្ភដល់សិស្ស |
| ៧- សុខភាពប្រជាពលរដ្ឋ | ក្នុងឃុំ | ក- ខ្វះការយល់ដឹងពីការថែទាំសុខភាព និងអនាម័យ | ក-១- ផ្សព្វផ្សាយពីការថែទាំសុខភាព និងអនាម័យ<br>ក-២- ផ្សព្វផ្សាយពីការប្រើប្រាស់សេវាសុខភាព<br>ក-៣- សង់បង្គន់អនាម័យ |
| ៨- កុមារនៅតែរងគ្រោះដោយសារផ្ទុកមេរោគអេដស៍ | ក្នុងឃុំ | ក- ខ្វះការឧបត្ថម្ភគាំពារ និងការទប់ស្កាត់ | ក-១- ផ្តល់ថ្នាំពន្យាជំងឺអេដស៍<br>ក-២- ផ្តល់ទុនសម្រាប់ប្រកបមុខរបរ<br>ក-៣- ផ្តល់អាហាររូបត្ថម្ភ<br>ក-៤- ផ្សព្វផ្សាយទប់ស្កាត់ការរីករាលដាល |
| ៩- សុខភាពមាតា | ក្នុងឃុំ | ក- ខ្វះការយល់ដឹងពីការថែ | ក-១- បង្កើនការព្យាបាល និងថែទាំដល |

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| និងទារក | | ទាំសុខភាព មាតានិងទារក | មូលដ្ឋាន<br>ក-ខ- ពង្រឹងបណ្តាញទ្រទ្រង់សុខភាពភូមិ<br>ក-៣- ផ្សព្វផ្សាយការពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព<br>ក-៤- ផ្សព្វផ្សាយពីជំងឺឆ្លងផ្សេងៗ<br>ក-៥- ផ្តល់វ៉ាក់សាំងដល់ស្ត្រី និងកុមារ |
| ១០- ជីវភាពប្រជាពលរដ្ឋមួយចំនួននៅមានកម្រិត | ក្នុងឃុំ | ក- ដីបង្កបង្កើនផលតិច និងខ្វះគ្មានដី | ក-១- ផ្តល់ឥណទានការប្រាក់ទាប<br>ក-២- រកដៃគូជួយគាំទ្រគ្រួសារក្រីក្រ |
| | | ខ- គ្មានជំនាញបច្ចេកទេសប្រកបមុខរបរ | ខ-១- បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរកទីផ្សារការងារ |
| ១១- គ្រោះមហន្តរាយ | គ្រប់ភូមិ | ក-ទឹកជំនន់ | ក-១- រកទីទួលសុវត្ថិភាព និងជម្រក |
| | | ខ-ខ្យល់ព្យុះ | ខ-១- ត្រៀមមធ្យោបាយជួយអន្តរាគមន៍ |
| | | គ-រាំងស្ងួត | គ-១-ដាំដើមឈើ |
| | | ឃ-ឡើងកំដៅ | ឃ-១- ត្រៀមទប់ស្កាត់មុខសញ្ញាគ្រោះមហន្តរាយ |
| ១២- ធនធានធម្មជាតិថយចុះ និងការបំពុលបរិស្ថាន | ក្នុងឃុំ | ក- ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ក-១- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ |
| | | ខ- កាប់ឆ្ការជម្រកត្រីពង | ខ-១- ទប់ស្កាត់ការកាប់ឆ្ការជម្រកត្រីពង<br>ខ-២- ផ្សព្វផ្សាយច្បាប់ជលផល |
| | | គ- ប្រើថ្នាំគីមី និងថ្នាំពុល | គ-១- ផ្សព្វផ្សាយការប្រើប្រាស់ថ្នាំគីមីតាមបច្ចេកទេស<br>គ-២- កាត់បន្ថយការប្រើថ្នាំពុល |
| | | ឃ- ចោលកាកសំណល់ពាលវាលពាលកាល | ឃ-១- តាមទីផ្សារនិងគ្រួសារមានធុងសំរាម |

# ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២

## ៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១.តម្រូវការដីតាមប្រភេទ

នៅពេលអនាគតរហូតដល់ឆ្នាំ ២០៣២ នៅក្នុងឃុំបន្ទាយចក្រីនឹងមានការកើនឡើង ចំនួនប្រជាជន ១៩ ៣៣២ នាក់ ដែលត្រូវនឹងចំនួន ៤ ៧២១ គ្រួសារ និងបច្ចុប្បន្នមានអ្នកគ្មាន ដីលំនៅឋាន និងដីកសិកម្មពិតប្រាកដ ដែលត្រូវដោះស្រាយទៅអនាគតចំនួន ២៨ គ្រួសារ ។ ដោយសារកំណើនប្រជា-ពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែមសម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំបន្ទាយចក្រីទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក២ខាង លើនៃរបាយការណ៍នេះ ។ តែដោយសារទំហំផ្ទៃដីដែលត្រូវបានប្រើប្រាស់បច្ចុប្បន្ននៅក្នុងឃុំ ពុំមានប្រែប្រួលកើនឡើងស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដើម្បីដោះស្រាយបានតាមតម្រូវការដី សម្រាប់លំនៅឋាននិងដីស្រែបន្ថែមនោះ គឺជាដំណោះស្រាយសមស្របដីសម្រាប់លំនៅឋានត្រូវប្រើប្រាស់ ដីភូមិលំនៅឋានដែលមានស្រាប់ ពីព្រោះស្ថានភាពការតាំងលំនៅឋានបច្ចុប្បន្ន មិនទាន់មានភាពចង្អៀត ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបាន សម្រាប់រយៈពេល១៥ឆ្នាំទៅ មុខហើយម្យ៉ាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួល ដល់ការផ្គត់ ផ្គង់ទឹកស្អាត ភ្លើងនិងសេវាសង្គមផ្សេងៗទៀតដូចជា សេវាអប់រំ សេវាសុខភាព ជាដើម។ល។ តែទោះជាយ៉ាងណា ជៀសក៏មិនផុតពីការពង្រីកដីលំនៅឋានភូមិមួយកន្លែង ក្នុងឃុំស្ថិតនៅក្នុងភូមិប្របុសរលួយ និងភូមិម្រេញបានឡើយ។ ការពង្រីកដីលំនៅឋានភូមិនេះនឹងនាំឱ្យប៉ះពាល់ដល់ដីស្រែ ដែលជាមូលដ្ឋាន ដ៏មានសក្តានុពល សម្រាប់ការអភិវឌ្ឍន៍ឃុំជៀសមិនផុតឡើយតែមានបរិមាណតែ៣១ហិកតា ដែលជាចំនួនតិចតួចប៉ុណ្ណោះ។

ចំពោះដីស្រែ ដែលមិនត្រឹមតែបានពង្រីកបន្ថែមតាមការគិតគូរខាងលើនោះទេ តែត្រូវទទួលរងការបាត់បង់ខ្លះថែមទៀតសម្រាប់ផ្គត់ផ្គង់ដល់ការពង្រីកដីលំនៅឋានភូមិ។ ជាដំណោះស្រាយគឺ ត្រូវតែគិតគូរពិចារណាដោយយកចិត្តទុកដាក់ តាមរយៈការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្ម ដំណាំស្រូវដោយត្រូវធ្វើស្រែបង្កើនរដូវឱ្យបានពី២ទៅ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទន្ទឹមនេះ ទៅថ្ងៃអនាគតក៏មាន តម្រូវការដីសម្រាប់ឈាបនដ្ឋានមួយកន្លែងផងដែរ ដែលជាការសមស្របគួររៀបចំនៅតាមវត្តអារាម ដើម្បីជៀសវាងបានពីការបាត់បង់ប្រភេទដីផ្សេងៗទៀត។

### ៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគតធនធានដីនៅក្នុងឃុំបន្ទាយចក្រី នៅតែរក្សាទំហំក្រឡាផ្ទៃសរុប ៨ ៣១៣ ហិកតា ហើយមានការប្រើប្រាស់សម្រាប់លំនៅឋាន(រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) និងផ្ទៃបឹងដូចការប្រើប្រាស់ដីបច្ចុប្បន្នដដែល ដោយគ្រាន់តែ មានការប្រែប្រួលតិចតួចពីដីកសិកម្មទៅជាដីសាងសង់ ដើម្បីសម្រួលដល់ការពង្រីកដីលំនៅឋានភូមិឆ្លើយតបទៅនឹងការរីកចម្រើនក្នុងឃុំប៉ុណ្ណោះ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយ អំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ។ ជាទូទៅធនធានដីនៅក្នុងឃុំបន្ទាយចក្រី មានសក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ ដោយសារដីនៅក្នុងឃុំមានទីតាំងភូមិសាស្ត្រអំណោយផលពីធម្មជាតិដូចបានរៀបរាប់ក្នុងជំពូកទី២ខាងលើ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំបន្ទាយចក្រី ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវជាចម្បង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពលនៃដីហើយក៏ជាការគាប់ជួន ដែលភាពអំណោយផលពីធនធានដីនៅក្នុងឃុំសមស្រប ទៅលើវិស័យកសិកម្មដំណាំស្រូវនេះ ក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងតួនាទីវិស័យកសិកម្មក្នុងការបង្កើតការងារ ការធានាសន្តិសុខ ស្បៀងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទដែលមានចែងក្នុងមុំទី១ចតុកោណទី៤ នៃយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤មានការរបស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋ-សភាដែលជាការផ្តល់ឱកាសដ៏ ល្អដល់អាចអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំរីកចម្រើនបាន តាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំ ស្រូវនៅលើផ្ទៃដីកសិកម្មដ៏ធំ ល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូលដើម្បីបង្កើនទិន្នផលស្រូវដែលជាដំណាំដ៏មានសារៈសំខាន់ សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាន និងការនាំចេញទៅលក់ នៅទីផ្សារដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈសកម្ម-ភាព ធ្វើពាណិជ្ជកម្មនាំអង្ករចេញរបស់រាជរដ្ឋាភិបាល។

ចំណែកដីដែលមានទំហំតិចតួច ដែលបានកំណត់ការប្រើប្រាស់ដីសម្រាប់សាងសង់លំនៅឋាន នៅលើដីខ្ពស់ជាប់តាមដងផ្លូវ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរចេញ-ចូលនិងងាយស្រួល ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំបានប្រកបដោយផាសុកភាព ព្រមទាំងដីប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ ។ ស្ថានភាពដីដែលត្រូវប្រើប្រាស់ទាំងនោះមានដីលំនៅឋាន និងដីកសិកម្ម ជាកម្មសិទ្ធិរបស់ឯកជន។

ចំណែកដីបឹង ប្រព័ន្ធធារាសាស្ត្រនិងហេដ្ឋារចនាសម្ព័ន្ធជាដីកម្មសិទ្ធិរបស់រដ្ឋ ដែលទាំងអស់គ្នាត្រូវការពារថែទាំឱ្យបានគង់វង្សសម្រាប់បម្រើឱ្យជាផលប្រយោជន៍សាធារណៈ ដោយមិនត្រូវឱ្យមានការរំលោភកាន់កាប់ប្រើប្រាស់បម្រើផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួនបានឡើយ។

## ៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅការកំណត់តំបន់ប្រើប្រាស់ដីបានផ្តោតសំខាន់លើមុខងារប្រើប្រាស់សម្រាប់ ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម កំសាន្ត ព្រៃឈើ ។ល។ ហើយការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ដោយត្រូវតែប្រាកដថាដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ ហើយនោះត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់មុន តាមរយៈការរក្សាជីវភាពរស់លាស់ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុតចំពោះមនុស្សជំនាន់ក្រោយ ។ ឧទាហរណ៍ដូចជាការផ្លាស់ប្តូរពីដីព្រៃឈើរេចរិលទៅជាដីសម្រាប់កសិកម្ម វានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍ តែត្រូវបានកើតឡើងជំនួសដោយវាលស្រែសម្រាប់ផលិតកម្មស្រូវដែលជាចំណីអាហារមិនអាចខ្វះបាន ដែលទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀតនៅលើទីតាំងដីដដែល ។

យ៉ាងណាមិញក្នុងរយៈពេល ១៥ឆ្នាំ ទៅមុខរហូតដល់ឆ្នាំ២០៣២ ការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រីត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយឆ្លើយតបទៅនឹងកំណើនប្រជាជន ដូចបានរៀបរាប់ខាងលើ ជាពិសេសគឺការដោះស្រាយក្នុងការបែងចែកការប្រើប្រាស់ដីធ្លី ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជន ដោយឈរលើស្មារតីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ដីធ្លីនៅក្នុងឃុំ។ បញ្ហាដែលត្រូវដោះស្រាយខាងលើនេះ យើងសង្កេតឃើញមានការដោះស្រាយដីសម្រាប់ការពង្រីកដីលំនៅឋានភូមិតែប៉ុណ្ណោះ ហើយការដោះស្រាយនេះត្រូវបានសម្រេចចិត្តកំណត់យកដីស្រែដែលមាននៅ ក្នុងភូមិប្របុសរលួយនិងភូមិម្រេញតាមទិសនៃការពង្រីកដីលំនៅឋានភូមិនោះ ដែលនឹងនាំឱ្យមានការប្រែប្រួលថយចុះបរិមាណផ្ទៃដី ស្រែមួយភាគតូចទៅជាដីលំនៅឋានភូមិ ការថយចុះផ្ទៃដីស្រែដែលជាមូលដ្ឋានដ៏រឹងមាំនៃការអភិវឌ្ឍន៍ឃុំបន្ទាយចក្រី វានឹងនាំឱ្យមានការថយចុះផលិតផលស្រូវ ដែលជាប្រភពចំណូលដ៏សំខាន់ សម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ តែបរិមាណផ្ទៃដីសម្រាប់ដៅ លំនៅឋាន ភូមិមានការកើនឡើងដែលជាតម្រូវការចាំបាច់សម្រាប់ដោះស្រាយការស្នាក់នៅរបស់ប្រជាពលរដ្ឋជា អាទិភាពមិនអាចខ្វះបាន និងម្យ៉ាងវិញទៀតទីប្រជុំជន នេះគឺជាមជ្ឈមណ្ឌលផ្តល់សេវាកម្មដែលជាអាទិភាពមិនអាចខ្វះបាន

ដែរក្នុងការដោះស្រាយ ជូនដល់ប្រជាពលរដ្ឋក្នុងឃុំក៏ដូចជាតំបន់ជុំវិញផ្សេងៗទៀត ដែលនៅជិតក្បែរខ្លួន ដោយសារតែទៅថ្ងៃអនាគតដីលំនៅឋានភូមិ នឹងកាន់តែពង្រីកខ្លួនឡើងស្របទៅកំណើនប្រជាពលរដ្ឋនឹងការរីកចម្រើនលូតលាស់របស់ឃុំ។

តារាងទី៣៤÷ការប្រើប្រាស់ដីនាពេលអនាគត

| ល.រ | ការប្រើប្រាស់ដីធ្លី | ផ្ទៃដីបច្ចុប្បន្ន | ផ្ទៃដី១៥ឆ្នាំក្រោយ | បម្រែបម្រួល |
|---|---|---|---|---|
| ១ | ដីលំនៅឋាន ភូមិ | ១ ៦៥៩ | ១ ៦៥៩ | 0 |
| ២ | ដីស្រែប្រាំងនិងស្រែវស្សា | 0 | ៦ ៥៤២ | ៦ ៥៤២ |
| ៣ | ដីលំនៅឋានទីប្រជុំជន | ៤២ | ៧៣ | ៣១ |
| ៤ | ដីស្រែវស្សា | ៦ ៥៧៣ | 0 | -៦ ៥៧៣ |
| ៥ | ទន្លេ | ៣៩ | ៣៩ | 0 |
| | សរុបរួម | ៨ ៣១៣ | ៨ ៣១៣ | 0 |

### ៣.២.២. ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដីនាពេលអនាគតតនៅក្នុងឃុំបន្ទាយចក្រី គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីសមស្របមួយ តាមរយៈការវាយតម្លៃបែប សាមញ្ញទៅលើធនធានដី រយៈកម្ពស់ ទីជំរាល ធនធានទឹក ការកាន់កាប់ដី និងសក្ដានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្នធ្វើជាមូលដ្ឋាន ក្នុងការគិតពិចារណាដូចមានមានរំលេចឱ្យឃើញនៅក្នុងតារាងទី៣៤ខាងលើនេះ ដោយមានភ្ជាប់នូវផែនទីប្រើប្រាស់ដីនាពេលអនាគតមួយដូចខាងក្រោម ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធភាព តាមរយៈការបង្ហាញយ៉ាងពិស្ដារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ។ ចំណែកនៅខាងក្រោមផែនទីប្រើប្រាស់ដីនាពេលអនាគត ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់នៅលើផែនទីនេះផងដែរ។

# ផែនទីការប្រើប្រាស់ដីអនាគត ឃុំបន្ទាយចក្រី ឆ្នាំ២០១៧-២០៣២













## សញ្ញាសម្គាល់

- សាលាឃុំ
- ព្រំប្រទល់ឃុំ( តាមការចុះបញ្ជី)

### គម្រោងវិនិយោគ

- ជុសជុលផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ជុសជុលផ្លូវលំ និងក្រាលថ្ម
- ស្តារប្រឡាយ

### ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន

- វត្ត
- សាលារៀន
- មណ្ឌលសុខភាព
- ផ្លូវជាតិលេខ៣១២

### ការប្រើប្រាស់ដី

- ដីលំនៅឋានភូមិ
- ដីលំនៅឋានទីប្រជុំជន
- ដីស្រែវស្សា
- ទន្លេ

## ប្រព័ន្ធកូអរដោនេ:

ចំណោលផែនទី: UTM

តំបន់ទី: 48N

ទិន្នន័យយោង: WGS 1984

អេលីបសូអ៊ីត: WGS 1984

## ប្រភពទិន្នន័យ:

- ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាល ប្រភពពីនាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(២០១៩)
- ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធថ្នាក់ខេត្ត។

## បញ្ជាក់:

- ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងនៅថ្នាក់ជាតិ និងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
- ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
- ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................. ឆ្នាំ ២០.....

លេខ: ៥៩៣/២០

បានឃើញ និងឯកភាពសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ

ធ្វើនៅខេត្តព្រៃវែង ថ្ងៃ............ ខែ............ ឆ្នាំ............ ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី............ ខែ............ ឆ្នាំ ២០............

អភិបាលនៃគណៈអភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តព្រៃវែង

ជា សុមេធី

លេខ: ២៧៦៩/២០

បានឃើញ និងពិនិត្យត្រឹមត្រូវ

គោរពជូនអភិបាលនៃគណៈអភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តព្រៃវែងជ្រាបនិងសម្រេច

ធ្វើនៅស្រុកព្រះស្តេច ថ្ងៃ............ ខែ............ ឆ្នាំ............ ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី............ ខែ............ ឆ្នាំ ២០............

អភិបាលនៃគណៈអភិបាលស្រុក និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកព្រះស្តេច

គុន សម្បត្តិ

លេខ: ១៣២៧/២០

បានឃើញ និងឯកភាព

គោរពជូនអភិបាលនៃគណៈអភិបាលស្រុក និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកព្រះស្តេច

ធ្វើនៅឃុំបន្ទាយចក្រី ថ្ងៃ............ ខែ............ ឆ្នាំ............ ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី............ ខែ............ ឆ្នាំ ២០............

មេឃុំបន្ទាយចក្រី

នូ សារឿន

គាំទ្រដោយ: ADB GAFSP

អនុវត្តដោយ:

### ៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

ផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី ដូចខាងក្រោម÷

**ក. ដីលំនៅឋានភូមិ**

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ។ នៅក្នុងឃុំដីលំនៅឋាន ភូមិ មាន០៥ តំបន់ប្រមូលផ្តុំភូមិគឺ តំបន់ទី១ ស្ថិតនៅតាមផ្លូវលំត្រង់ចំណុចមានចេញពីឃុំពីងពង់ ភូមិឬស្សីផុក ភូមិអំពិល ភូមិមុន្នីសិលា តំបន់ទី២ មានចំនួន ស្ថិតនៅអមផ្លូវជាតិកៅស៊ូ គឺភូមិប្រពុសរលួយ ភូមិបឹងកំពត ភូមិតាអឹម និងភូមិពោធិ៍ជ្រែក តំបន់ទី ៣ មានចំនួន៧ភូមិគឺ ភូមិម្រេញ ភូមិដៃតាភូមិពោធិរិយំ ភូមិរកាជួរ ភូមិរកាជួរទី២ ភូមិរកាជួរទី៣ និងភូមិងែកងក តំបន់ទី៤ ផ្លូវឆ្ពោះទៅប្រទេសវៀតណាម គឺភូមិប្រោះស្វា និងភូមិកគោ។ ដីលំនៅឋាន ភូមិ គឺជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ(ដីកម្មសិទ្ធឯកជន) មានទំហំផ្ទៃដីសរុបចំនួន ១ ៦៥៩ ដែលជាដីល្បាយខ្សាច់ និងល្បាយខ្សាច់លាយដីខ្មៅ(អាចម៍កណ្តុរ) និងមានស្ថានភាពជាដីខ្ពស់រាបស្មើ។ ដីដែលបានកំណត់ជាដីភូមិនេះពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋាន បានមកពីអណ្តូងស្នប់ប្រឡាយ ដែលមានចម្ងាយ មធ្យមប្រមាណ ១ ៦០០ ម៉ែត្រពី លំនៅឋានទៅប្រភពទឹក ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយ ម៉ូទ័របូម និងស្នប់សប់ដៃ។ នៅពេលអនាគត ទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីលំនៅឋានភូមិដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា ហើយស្ថិតនៅជាប់តាមដងផ្លូវងាយស្រួល ក្នុងការចេញចូលទៅ តំបន់ក្រៅឃុំ សមស្របទៅនឹងការសាងសង់លំនៅឋាន ការដាំដុះដំណាំរួមផ្សំ និង ឈើហូបផ្លែ ដែលបានជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយផាសុកភាព។

**ខ. ដីលំនៅឋាន ទីប្រជុំជន**

ដីលំនៅឋានទីប្រជុំជន គឺជាដីលំនៅឋានប្រមូលផ្តុំគ្នាសម្រាប់ជាជម្រក និងជាមជ្ឈមណ្ឌលផ្តល់សេវាកម្មនៅក្នុងឃុំ ដូចជាលក់ដូរទំនិញ ជាងជួសជុល អាហារដ្ឋាន ភេសជ្ជៈដ្ឋាន សេវាសុខភាព សេវាអប់រំ ។ល។ ហើយក្នុងនោះក៏នៅមានផ្សារណាត់លក់ដូរ ចែកចាយទំនិញទៅវិញទៅមកទៀតផងដែរ ។ ដីលំនៅឋាន ទីប្រជុំជននេះមាននៅក្នុងភូមិបឹងដោលមួយកន្លែងប៉ុណ្ណោះ។ ដីលំនៅឋាន ទីប្រជុំជននេះមិនសំដៅដល់ទី ប្រជុំជនដែលបានកំណត់ដោយក្រសួងផែនការនោះឡើយ ដោយគ្រាន់តែកំណត់សម្គាល់ជាទីតាំងដីដែល ប្រជាជនបានទៅតាំងលំនៅឋានច្រើនកុះករជាងគេនៅក្នុងឃុំប៉ុណ្ណោះ ។ ដីលំនៅឋានទីប្រជុំជនជាដីដែលបានកាន់ កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) មានទំហំផ្ទៃដីប្រមាណ ៧៣ ហិកតា ដែលបច្ចុប្បន្នដីនេះ បានប្រើប្រាស់សម្រាប់លំនៅឋានទីប្រជុំជនដដែល មានទំហំ ៤២ ហិកតា និងដីស្រែ

វស្សាទំហំ ៣១ ហិកតាបន្ថែម ជាប្រភេទដីល្បាយខ្សាច់ និងត្រូវមានស្ថានភាពជាដីខ្ពស់។ ដីដែលបានកំណត់ជាដីលំនៅឋាន ទីប្រជុំជននេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃបានមកពី អណ្ដូងស្នប់ ប្រឡាយ ដែលមានចម្ងាយមធ្យមប្រមាណ ១ ៦០០ ម៉ែត្រ ពីលំនៅឋានទៅប្រភពទឹក ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ។ នៅពេលអនាគតទីតាំងដីនេះនឹងត្រូវបានកំណត់ប្រើប្រាស់ជាដីលំនៅឋាន ទីប្រជុំជន ដោយសារទីតាំងដីនេះមានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា ហើយស្ថិតនៅតាមដងផ្លូវជាតិលេខ៣១២ លើកលែងតែដីស្រែមានស្ថានភាពជាដីទាបដែលត្រូវចាក់បំពេញបន្ថែម បំពេញតម្រូវការចាំបាច់ សមស្របទៅនឹងការសាងសង់លំនៅឋាន សំណង់ផ្ដល់សេវាកម្ម និងបរិក្ខាសាធារណៈផ្សេងៗ សម្រាប់ជួយដល់ការដោះស្រាយលំនៅឋាន និងទីកន្លែងផ្ដល់សេវាកម្មឆ្លើយតបទៅនឹងកំណើនប្រជាជន និងការរីកចម្រើនលូតលាស់របស់ឃុំ ។

### គ. ដីស្រែប្រាំង និងស្រែវស្សា

ដីស្រែប្រាំង និងស្រែវស្សាមានវិសាលភាពគ្របដណ្ដប់ស្ទើរតែពេញដែនដីរបស់ឃុំ ដែលបច្ចុប្បន្នប្រើ ប្រាស់ជាដីស្រែវស្សា (ធ្វើស្រែតែម្ដងគត់ក្នុងមួយឆ្នាំ) លើកលែងតែដីតិចតួចប្រើប្រាស់ សម្រាប់ជាដីលំនៅឋានភូមិ ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះ។ ដីស្រែប្រាំងនិងស្រែវស្សា គឺជាដី ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធឯកជន) មានទំហំផ្ទៃដីចំនួន ៦ ៥៤២ហិកតា ជាប្រភេទដីរាបស្មើ ហើយជាប្រភេទដីល្បាយខ្សាច់និងដីខ្មៅ និងស្ថានភាពជាដីវាលទំនាប។ ដីដែលបានកំណត់ជាដីស្រែប្រាំង និងស្រែវស្សានេះនាពេលអនាគតត្រូវពឹងផ្អែកលើប្រភពទឹកភ្លៀង និងប្រឡាយមេ៣ខ្សែរ គឺប្រឡាយទី១គឺប្រឡាយអូរស្វាត មានចម្ងាយប្រមាណ ៧ ៥០០ម៉ែត្រ និងប្រឡាយទី២ គឺប្រឡាយអន្លង់ចារ មានចម្ងាយ ៣ ៦០០ម៉ែត្រ ដែលប្រឡាយ នេះមានប្រភពទឹកមកពីដៃ ទន្លេសីហា និង ប្រឡាយទី៣ គឺប្រឡាយទួលធាតុ មានចម្ងាយប្រមាណ ៦ ៥០០ ម៉ែត្រ ប្រឡាយនេះមានប្រភពទឹកមកពីប្រឡាយបឹង កំពក ដែលមានបណ្ដាញតភ្ជាប់មកពីបឹងព្រីង កាត់តាមឃុំព្រះស្ដេច ចម្ងាយប្រមាណ០៨ គីឡូម៉ែត្រនៅក្នុងឃុំបន្ទាយចក្រី មានការប្រើប្រាស់តាមរយៈអណ្ដូងស្នប់ សម្រាប់ស្រោចស្រព និងសម្រាប់ការប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតែប៉ុណ្ណោះ។នៅពេលអនាគត ទីតាំងដីនេះនឹងត្រូវរក្សា ទុកជាដីស្រែដដែលដោយសារទីតាំងដីនេះមានស្ថានភាពជា ដីវាលរាប សមស្របទៅនឹងដំណាំស្រូវ ដែល ផ្ដល់ផលផ្គត់ផ្គង់ការហូបចុកសម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុង និងក្រៅប្រទេសបានចំណូលបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។

### ឃ. ទន្លេ

ឃុំបន្ទាយចក្រី មានទំហំផ្ទៃដីបឹងធម្មជាតិមួយឈ្មោះបឹងកំពង់ទូក ដែលមានទំហំ ៣៩ ហិកតា ជាដីសាធារណៈរបស់រដ្ឋស្ថិតនៅភូមិសំនយ។ បច្ចុប្បន្នមានទឹកនៅរដូវវស្សា បានផ្ដល់ទឹកសម្រាប់ការស្រោចស្រព

នៅពេលមានភាពរាំងស្ងួតនៅរដូវវស្សា និងផ្តល់ធនធានជល ផលសម្រាប់ការនេសាទតិចតួចជាលក្ខណៈគ្រួសារផ្គត់ផ្គង់ជាម្ហូប និងអាចលក់បានខ្លះ ចំណែកនៅរដូវប្រាំង បានរីងនៅសល់តែទឹកតាមថ្លុកតិចតួចប៉ុណ្ណោះ។

## ៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិត បច្ចុប្បន្នយើងបានរកឃើញនៅក្នុងឃុំបន្ទាយចក្រីមានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅ ឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ២៨ គ្រួសារ ដូចបានរកឃើញនៅក្នុងជំពូក ទី១ នៃរបាយការណ៍នេះ ដែលបច្ចុប្បន្នមួយចំនួនកំពុងរស់នៅលើចិញ្ចើមផ្លូវ លើដីចំណីប្រឡាយ និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់ត្រូវស៊ីឈ្នួលឱ្យគេដើម្បីចិញ្ចឹមជីវិត។ ដូច្នេះ ដើម្បីដោះស្រាយដីសម្រាប់សាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រករស់នៅសមរម្យ និងបង្កើតឱកាសការងារដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំបន្ទាយចក្រី។ ដីធ្លីដែលត្រូវ ដោះស្រាយជូនពួកគាត់ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូកទី២ ត្រង់ចំណុច ២.១.៣ ខាងលើគឺ ដីសម្រាប់លំនៅឋានមានទំហំ ១២,០៤ ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំ ៥៦ហិកតា ។

## ៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ហើយការធានាទាំងអស់នេះត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូតដោយពុំមានឈប់ឈរ។ និរន្តរភាពគឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាឱ្យមាននិរន្តរភាព។

### ៣.៤.១. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។ ដោយធានាបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងបន្តដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀតត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់ទាំងអស់ នៅក្នុងឃុំដែលបានកំណត់រួចតាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម÷

### ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងឃុំបន្ទាយចក្រី ដែលក្រុមការងារ បានធ្វើការសិក្សាស្រាវជ្រាវរកឃើញបានកំណត់ច្បាស់ថា ឃុំនេះមានគោលដៅអភិវឌ្ឍន៍ទៅថ្ងៃអនាគតពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលក្នុងនោះបានផ្តោត សំខាន់ទៅលើដំណាំស្រូវ។ ដូចនេះឃុំបន្ទាយចក្រីនឹងមានតួនាទីសំខាន់មួយ ក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្ម ស្រូវនិងនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្ម ក្នុងឃុំឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល អាចមានលទ្ធភាពនាំស្រូវចេញបាន ច្រើនសល់ ពីការហូបចុកឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ឃុំបន្ទាយចក្រី ដូចខាងលើត្រូវមានការគ្រប់គ្រងដីស្រែក្នុងឃុំឱ្យបានគត់មត់ ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដីពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀតត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបដោយតម្លាភាព ដោយអនុលោមតាមច្បាប់លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាចំហ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ត្រូវគិតគូរពីទឹកស្រោចស្រពដំណាំស្រូវ ដោយធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំ តាមរយៈការស្តារប្រព័ន្ធ ប្រឡាយចាស់ៗដែលមានស្រាប់អាចនាំទឹកទៅស្រោចស្រពដីស្រែបានគ្រប់គ្រាន់ព្រមទាំង ត្រូវកំណត់ប្រភពទឹកពីទន្លេមេគង្គ ដែលឃុំនេះមានប្រភពទឹកភ្លៀង និងប្រឡាយមេពាខ្សែរ គឺប្រឡាយអូរស្នាត ប្រឡាយអន្លង់ចារ និងប្រឡាយទួលធាតុ។ បន្ទាប់ពីកត្តាដី និងទឹកនៅមានកត្តា បច្ចេកទេសដាំដុះថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែបែបប្រពលវប្បកម្មទំនើបដូចមានលើកឡើងតាមការវិភាគក្នុងជំពូកទី ២ ត្រង់ចំណុចការផ្តល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួម ក្នុងការងារកសិកម្មបានច្រើនផងដែរ ពីព្រោះយុវជនតែងគិតថាការធ្វើស្រែ នាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូសដីភក់ មិនស្អាតបាតដែលជាការយល់ខុសគឺតាមពិតការធ្វើស្រែតាមបែបប្រពលវប្បកម្មទំនើប កសិករក៏អាចពាក់ក្រវាត់ករប្រើប្រាស់កុំព្យូទ័រក្នុងបន្ទប់ម៉ាស៊ីន ត្រជាក់បានដូចគ្នា។ ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំបន្ទាយចក្រី មិនមែនយកចិត្តទុកដាក់តែនៅ លើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍កសិករ ដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិ ក្នុងការចចារ រកទីផ្សារក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើស្រែបានផល ស្រូវមានគុណភាព តាមស្តង់ដារតម្រូវទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ។

តាមការគណនាដែលផ្អែកលើការការគិតគូរក្នុងជំពូក២ ត្រង់ចំណុច ១.៣.២ អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ **១៩ ៣៣២នាក់**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែទំហំប្រមាណ **៦ ៥៤២ហិកតា**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវ ៤ តោន ក្នុងមួយហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែបាន៣ដងក្នុងមួយឆ្នាំ

**-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំ (២០១៧-២០៣២) ផលិតផលស្រូវទទួលបានក្នុងមួយឆ្នាំជាមធ្យមៈ**

**៦ ៥៤២ហិកតា x ៤តោន/ហិកតា x ៣ដង = ៧៨ ៥០៤តោន/ឆ្នាំ**

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន **២២៤ គីឡូក្រាម** *(ផ្អែកតាមផែនការអភិវឌ្ឍន៍វិស័យកសិកម្មខេត្តព្រៃវែង)*

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យមៈ

១៩ ៣៣២នាក់ x ២២៤ គីឡូក្រាម= **៤ ៣៣០ ៣៦៨គីឡូក្រាម/ឆ្នាំ**

ស្មើប្រហាក់ប្រហែល **៤ ៣៣០ តោន**/ឆ្នាំ

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យមៈ

៦ ៥៤២ ហិកតា x ៣០០ គីឡូក្រាម x ៣ដង= **៥ ៨៨៧ ៨០០ គីឡូក្រាម/ឆ្នាំ**

ស្មើប្រហាក់ប្រហែល **៥ ៨៨៨ តោន/ឆ្នាំ**

-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យមៈ

៧៨ ៥០៤តោន/ឆ្នាំ - ៤ ៣៣០ តោន/ឆ្នាំ - ៥ ៨៨៨តោន/ឆ្នាំ = **៦៨ ២៨៦តោន/ឆ្នាំ**

**-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ**

**៦៨ ២៨៦តោន/ឆ្នាំ x ៦០% = ៤០ ៩៧២តោន/ឆ្នាំ**

**ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត**

ទោះបីបច្ចុប្បន្ននេះនៅក្នុងឃុំបន្ទាយចក្រីពុំមានព្រៃឈើធម្មជាតិក៏ដោយក៏ឃុំនៅមានដីទំនេរ ដែលសមស្របអាចដាំដើមឈើបាន ដូចជាដីនៅតាមទីសាធារណៈ តាមដងផ្លូវ ប្រឡាយទឹក ទីទួល ទីធ្លា សាលាឃុំ ទីធ្លាសាលារៀនទីធ្លា មណ្ឌលសុខភាព ទីធ្លានៅតាមវត្តអារាម និងនៅតាម លំនៅឋាន ជាដើម ។ល។ ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំបម្រើផលប្រយោជន៍ ដូចបានលើកឡើងនៅក្នុងជំពូកទី ២ នៃរបាយការណ៍នេះហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្ស និងលូតលាស់បានល្អ។

ចំណែកធនធានជលផលនៅក្នុងឃុំវិញ បច្ចុប្បន្នមានតែតាមបែបធម្មជាតិនៅតាមបឹង អូរ និងក្នុងស្រែនារដូវវស្សា ដែលអាចឱ្យប្រជាពលរដ្ឋក្នុងឃុំអាចទទួលផលសម្រាប់ហូបជា លក្ខណៈគ្រួសារ និងមានលក់បានតិចតួចតែប៉ុណ្ណោះ។ តែទៅថ្ងៃអនាគតក៏ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីថែមទៀត ដើម្បីបានផលគ្រប់គ្រាន់ផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់ សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំ។ ចំពោះស្ថាន

ភាពសមស្របក្នុងឃុំ គួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះ ចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋាន ចិញ្ចឹមត្រីក្នុងស្រែ ដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើន ផលិតភាពជលផលតាម ប្រពលវប្បកម្ម (តាមវាលស្រែ) ហើយមានប្រយោជន៍ ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវ ហ្វូងក្នុងស្រែ ដែលបំផ្លាញផលដំណាំដូចបានលើកឡើងជាអនុសាសន៍នៅក្នុងជំពូកទី ២ នៃរបាយការណ៍នេះ ផងដែរ។

ចំណែកធនធានសំខាន់ៗផ្សេងទៀតលើសពីការរៀបរាប់ខាងលើនេះ ពុំមានឃើញគួរកត់សម្គាល់ ឡើយ។

ទន្ទឹមនិងនេះឃុំបន្ទាយចក្រី ក៏មានផ្លូវគមនាគមន៍សម្រាប់ការដឹកជញ្ជូន និងធ្វើដំណើររបស់ប្រជា-ពលរដ្ឋក្នុងឃុំដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍឃុំផង ដែរដូចជាត្រូវមានការថែរទាំ ដោយតាមលំនៅឋានភូមិ ត្រូវរៀបចំឱ្យមានប្រព័ន្ធលូបង្ហូរទឹកឱ្យបានត្រឹម ត្រូវ ជៀសវាងទឹកហូរកាត់ផ្លូវនាំឱ្យមានការខូចខាតផ្លូវ និងមានការជួស ជុលផ្លូវជាប្រចាំ ...ជាដើម។

### ៣.៤.២. គម្រោងគាំទ្រចាំបាច់សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយអាចធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងធនធានសំខាន់ៗ សម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍន៍ និងអភិរក្ស ដីធ្លីនិងធនធានធម្មជាតិក្នុងឃុំបន្ទាយចក្រី ចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោម÷

- ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ
- ការជួសជុល និងថែរទាំផ្លូវ
- ផ្សព្វផ្សាយ និង បណ្តុះបណ្តាល បច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្តិ៍
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតឱ្យបានដល់គ្រប់ភូមិ
- តបណ្តាញអគ្គិសនីឱ្យបានដល់គ្រប់ភូមិ
- បង្កើតទីតាំងចាក់សំរាម
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ “ភូមិ១ ផលិតផល១”
- ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់គ្នា
- ការផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ

- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជំងឺដល់ស្ត្រីមានផ្ទៃពោះ កុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជំងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ បទដ្ឋានគតិយុត្តនានា ជូនដល់ប្រជាពលរដ្ឋ។

## ៣.៥. សេចក្តីសន្និដ្ឋានរួមលើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី ក្នុងឆ្នាំ២០១៧ នេះបានឱ្យដឹងថា ឃុំបន្ទាយចក្រី ជាឃុំមួយក្នុងចំណោមឃុំ ១១ របស់ស្រុក ព្រះស្ដេច ខេត្តព្រៃវែង មានភូមិចំនួន ២០ និងមានផ្ទៃដីសរុបចំនួន ៨ ៣១៣ហិកតា។ ក្នុងឆ្នាំ២០១៧ ឃុំបន្ទាយចក្រី មានប្រជាពលរដ្ឋរស់នៅ ១៦ ០៩២ នាក់ ក្នុងនោះមានស្ត្រីចំនួន ៨ ២៦០នាក់ គិតជាគ្រួសារ មានចំនួន ៣ ៩១១គ្រួសារ ហើយមានដង់ស៊ីតេប្រជាជនមធ្យម ១៩៤ នាក់/គ.ម²។ ឃុំបន្ទាយចក្រីមានសណ្ឋានភាពដីជាដីរាបស្មើ ហើយជាប្រភេទដីល្បាយខ្សាច់និងដីខ្មៅ ត្រូវបានប្រើប្រាស់ជាដីស្រែវស្សា ដែលបានផ្ដល់នូវមុខរបរសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនប្រមាណ ៧៩% ចំណែកឯមុខរបរសំខាន់លើការផ្ដល់សេវាមានប្រមាណ ២០% ចិញ្ចឹមសត្វមានតិចតួចបំផុត ប្រមាណ ១% និងពុំមានសិប្បកម្មទេ។ ទន្ទឹមនេះឃុំបន្ទាយចក្រី មានប្រឡាយបីខ្សែនាំទឹកពីប្រភពទន្លេតូចដើម្បីមកស្រោចស្រពដីស្រែពេលជួបគ្រោះរាំងស្ងួតនៅរដូវវស្សា។ បន្ថែមពីលើនេះឃុំបន្ទាយចក្រី មានតែប្រព័ន្ធគមនាគមន៍ ផ្លូវគោកតែប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ការដឹកជញ្ជូននិងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលក្នុងនោះមាន ផ្លូវគ្រួសក្រហមឬក្រាលខ្សាច់ភ្នំ ផ្លូវដីសរ ឬផ្លូវលំ ដែលផ្ដល់ឱកាសឱ្យឃុំនេះអាចទាញ យកប្រយោជន៍ពីការអភិវឌ្ឍន៍តាមផ្លូវនេះទៅថ្ងៃអនាគតបាន។ ទន្ទឹមនេះឃុំបន្ទាយចក្រី នៅមានផ្លូវផ្សេងទៀតគ្រប់គ្រាន់ អាចភ្ជាប់ទំនាក់ទនងពីភូមិមួយទៅភូមិមួយមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំនិងស្រុកផ្សេង រួមទាំងទីរួមខេត្តព្រៃវែងបានដោយងាយស្រួល។ ចំពោះកំណើនប្រជាជនវិញ បានរកឃើញថាក្នុងរយៈពេល ១៥ ឆ្នាំទៅមុខរហូតដល់ឆ្នាំ ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ១៩ ៣៣២នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន។ ទន្ទឹមនេះក៏បានរក ឃើញអំពីបញ្ហាប្រឈមមួយចំនួនទៅលើសកម្មភាពនៃការអភិវឌ្ឍន៍ឃុំបច្ចុប្បន្នផងដែរ ដូចជាការធ្វើស្រែដែលមានសក្ដានុពល ក្នុងការអភិវឌ្ឍន៍ឃុំមិនទាន់ទទួលបានផលស្រូវសមស្របអស់លទ្ធភាពនៅឡើយ ដោយសារដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងអំពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសការប្រើប្រាស់ជីគីមីនិងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយ ដែលមានមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារចំណាកស្រុកច្រើនគឺបាត់កម្លាំងពលកម្មជិតពាក់កណ្ដាលនៃកម្លាំងពលកម្ម ដែលមាននិងតម្លៃកសិផលមិនមានស្ថេរភាពដោយឈ្មួញជាអ្នកកំណត់តម្លៃ។ល។ ទន្ទឹមការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍឃុំក៏បានរកឃើញថាជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី បច្ចុប្បន្នបានចំទិសដៅ និង

មានភាពសមស្របដូចជាការប្រើប្រាស់ដីសម្រាប់លំនៅឋាន កសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ប្រព័ន្ធធារាសាស្ត្រ ជាដើមដែលទៅថ្ងៃអនាគត ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែលដោយគ្រាន់តែមានការកែប្រែតិចតួចទៅតាម តម្រូវការដីចាំបាច់ប្រមាណជា ៣១ ហិកតា ពីដីស្រែទៅជាដីលំនៅឋានទីប្រជុំជនសម្រាប់ការពង្រីកដីលំនៅឋានទីប្រជុំជនឱ្យស្របទៅនឹងកំណើនប្រជាសាស្ត្រ និងភាពរីកចម្រើននៅក្នុងឃុំប៉ុណ្ណោះ។ បន្ថែមពីលើនេះក៏បានរកឃើញវិធីដោះស្រាយបញ្ហា ផ្សេងៗទៀតផងដែរសម្រាប់អនាគត ដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែមពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យបានប្រសើរឡើងជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ ជួសជុល ផ្លូវ ស្ពារប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈជំរុញការចិញ្ចឹមត្រីតាមស្រែ។ល។ ជាពិសេសការដោះស្រាយដីសម្រាប់លំនៅឋានក្នុងភូមិដែលមិនតម្រូវឱ្យមានការពង្រីកបន្ថែមទៀតនោះទេ គឺឱ្យប្រើប្រាស់ដីភូមិ ដែលមានស្រាប់ដែលបច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន ជៀសវាងការពង្រីកថែមនាំឱ្យប៉ះពាល់ដល់ដីស្រែ ចំណែកដីស្រែដែលមិនអាចអាចពង្រីកបានដើម្បីដោះស្រាយទៅនឹងកំណើនប្រជាជនត្រូវពង្រឹងការធ្វើស្រែឱ្យបាន ៣ ដងក្នុងមួយឆ្នាំនិងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើន ទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពលដែលមានសម្រាប់ផ្គត់ផ្គង់ការហូបចុក និងនាំស្រូវចេញបានចំនួន **៦៨ ២៨៦ តោន/ឆ្នាំ** ដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានកាន់ តែប្រសើរឡើងសមស្របទៅនឹងកំណើនប្រជាពលរដ្ឋព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងឃុំ។ ការរកឃើញភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រីនាពេលអនាគតនេះ បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវដោយផ្អែកលើធនធាន រយៈកម្ពស់ដី ទីជំរាល ធនធានទឹកដី ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះជាដើម ដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី ទៅអនាគតប្រកបដោយ ចីរភាព និងសមធម៌។

ដូច្នេះដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រីស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយ ចីរភាព និងសមធម៌រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនាពេលអនាគត ដូចបានរកឃើញមានចែងលម្អិតនៅក្នុងរបាយការណ៍បច្ចេកទេស នេះរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំបន្ទាយចក្រី ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំបន្ទាយចក្រី ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រីដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួចដោយបញ្ជ្រាបទៅនឹង ផែនការអភិវឌ្ឍឃុំឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ៕

លេខ÷១៣២៧/២០

បានឃើញ និងឯកភាព

គោរពជូនលោកអភិបាលនៃគណៈអភិបាលស្រុក និងជាប្រធានគណៈកម្មាធិការ
រៀបចំដែនដី និងនគរូបនីយកម្មស្រុកព្រះស្តេច មេត្តាពិនិត្យ និងសម្រេច ។

ធ្វើនៅឃុំបន្ទាយចក្រី, ថ្ងៃ.អង្គារ២កើត ខែមិគសិរ ឆ្នាំជោស័កព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី...១៧...ខែ...វិច្ឆិកា... ឆ្នាំ ២០២០

**មេឃុំ...បន្ទាយចក្រី...**

នូ សាម្ងួន

លេខ÷២៧៦៨/២០

បានឃើញ និងពិនិត្យត្រឹមត្រូវ

គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការ
រៀបចំដែនដី និងនគរូបនីយកម្មខេត្តព្រៃវែង មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។

ធ្វើនៅស្រុកព្រះស្តេច, ថ្ងៃសុក្រ១២កើតខែមិគសិរ ឆ្នាំជូត ទោស័កព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី...១៧...ខែ...វិច្ឆិកា... ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលស្រុក និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុក...ព្រះស្តេច...**

គុន_សម្ងស្ស

លេខ÷៤៩៣/២០លបដ

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ធ្វើនៅខេត្តព្រៃវែង, ថ្ងៃច័ន្ទ៧រោច.ខែមិគសិរ ឆ្នាំជូត ទោស័កព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តព្រៃវែង**

ជា_សុមេធី

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំបន្ទាយចក្រី



# ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំបន្ទាយចក្រី



# ផែនទីការប្រើប្រាស់ដីសាមញ្ញ ឃុំបន្ទាយចក្រី




**ប្រព័ន្ធកូអរដោនេ:**

ចំណោលផែនទី: UTM

តំបន់ទី: 48N

ទិន្នន័យយោង: WGS 1984

អេលីបស្វូអ៊ីត: WGS 1984

**ប្រភពទិន្នន័យ:**

- ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាល ប្រភពពីនាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(២០១៩)
- ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត។

**បញ្ជាក់:**

- ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើង នៅថ្នាក់ជាតិ និងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
- ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
- ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................. ឆ្នាំ ២០.....

គាំទ្រដោយ: ADB GAFSP

អនុវត្តដោយ:

# ផែនទីគម្រោងវិនិយោគ ឃុំបន្ទាយចក្រី




**ប្រព័ន្ធកូអរដោនេ:**

ចំណោលផែនទី: UTM

តំបន់ទី: 48N

ទិន្នន័យយោង: WGS 1984

អេលីបស្វអ៊ីត: WGS 1984

**ប្រភពទិន្នន័យ:**

- ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាល ប្រភពពីនាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(២០១៩)
- ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត។

**បញ្ជាក់:**

- ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើង នៅថ្នាក់ជាតិ និងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
- ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
- ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................... ឆ្នាំ ២០.....

**គាំទ្រដោយ:** ADB GAFSP

**អនុវត្តដោយ:**

# ឯកសារឧបសម្ព័ន្ធ





ក្រុមការងារចាប់ផ្តើមការងារដោយជួបពិភាក្សាជាមួយអ្នកសម្របសម្រួលគម្រោងថ្នាក់ស្រុក
ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨



សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ
ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន
ថ្ងៃ០៦ ខែមិនា ឆ្នាំ២០១៨





កិច្ចប្រជុំកែសម្រួលរបាយការណ៍ផែនការប្រើប្រាស់ដីឃុំបន្ទាយចក្រី
ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨



កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំក្រាំងស្វាយ
ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨





សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំបន្ទាយចក្រី
ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨





សកម្មភាពក្រុមការងារចុះប្រមូលទិន្នន័យអាជ្ញាធរដែនដី និងមន្ត្រីជំនាញថ្នាក់ស្រុក ខេត្ត
ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៨





សកម្មភាពក្រុមការងាររៀបចំផែនទី និងចងក្រងទិន្នន័យ
ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨





អាជ្ញាធរមូលដ្ឋានបំពេញបញ្ជីសំនួរ និងទិន្នន័យរបាយការណ៍
ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩



កិច្ចប្រជុំពិភាក្សាជាមួយអាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធដើម្បីកែសម្រួល
បំពេញបន្ថែមផែនទីប្រើប្រាស់ដីបច្ចុប្បន្ននៅក្នុងឃុំបន្ទាយចក្រី
ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨






សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ
ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)
ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០



កិច្ចប្រជុំថ្នាក់ឃុំ
ដើម្បីពិនិត្យ សម្រេចនិងឯកភាពគ្នាទៅលើសេចក្ដីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី
ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០



កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកព្រះស្ដេច ដើម្បីពិនិត្យ
និងឯកភាពទៅលើសេចក្ដីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំបន្ទាយចក្រី
ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០



កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ខេត្តព្រៃវែង
ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅឃុំបន្ទាយចក្រី
ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០





សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅឃុំបន្ទាយចក្រី
ថ្ងៃទី២១ ខែកញ្ញា ដល់ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

# ឯកសារយោង

# ឯកសារយោង


១. ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត

២. ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត

៣. ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត

៤. ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦របស់មន្ទីរផែនការខេត្ត

៦. ឯកសារព័ត៌មានស្ថានភាពឃុំបន្ទាយចក្រីស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត

៧. ផែនការអភិវឌ្ឍឃុំរយៈពេលប្រាំឆ្នាំ (២០១៨_២០២២) របស់ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង

៨. កម្មវិធីវិនិយោគឃុំបន្ទាយចក្រី ឆ្នាំ២០១៧ របស់ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង

៩. ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣

១០. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្តព្រៃវែង ២០១៦-២០២០ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង

១១. របាយការណ៍សន្និបាទបូកសរុបការងារ យុវជន និងកីឡា ឆ្នាំសិក្សា២០១៥-២០១៦ និងទិសដៅឆ្នាំសិក្សា ២០១៦-២០១៧ របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង

១១. របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ និងទិសដៅបន្ត២០១៤-២០១៧ របស់មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រៃវែង

១២. របាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ_បរិស្ថាន ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង ឆ្នាំ២០១៧

១៣. https://www.cpp.org.kh

១៤. http://moh.gov.kh/